# សាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ

# និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

## ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង នៅកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **មូល ផល្លា**

**តួង សុជានី**

សាស្ត្រាចារ្យណែនាំ

**សាស្ត្រាចារ្យ សាន មន្និយ៉ា**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និង ហិរញ្ញវត្ថុ

ជំនាន់ទី១៤

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំនិស្សិតឈ្មោះ មូល ផល្លា និង និស្សិតឈ្មោះ ភួង សុដានី ដែលជានិស្សិតកំពុងសិក្សាបញ្ចប់ថ្នាក់ បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ឆ្នាំទី៤ ក្រុមB4A2 នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាស្តីពី **ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនៅកម្ពុជា**។

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណ កត្តញ្ញូកត្តវេទី យ៉ាងជ្រាលជ្រៅ ចំពោះគុណូបការៈរបស់លោកឪពុកអ្នកម្តាយ ដែលលោកទាំងទ្វេរ បានចិញ្ចឹមបីបាច់មើលថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅរូបកូនតាំងពីតូចមិនទាន់ដឹងក្តីរហូតដល់រូបកូនធំពេញវ័យមានចំណេះវិជ្ជាដូចសព្វថ្ងៃគឺ កើតចេញពីការអត់ធ្មត់តស៊ូទ្រាំរបស់លោកទាំងពីរទាំងកម្លាំងកាយ និងកម្លាំងចិត្តគ្រប់បែបយ៉ាងដើម្បីអោយកូនបានរៀនសូត្រដូចគេឯង។ កូនសូមសង្រ្គមបួងសួងឲ្យលោកទាំងពីរមានសុខភាពល្អនិងជន្មាយុយឺនយូរដើម្បីទទួលនូវការតបស្នងសងគុណពីរូបកូន។

សូមថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីប្រធាន អនុប្រធាន ដេប៉ាតឺម៉ង់ លោក លោកស្រីប្រធាន អនុប្រធាន ការិយាល័យ លោក លោកស្រីសាស្រាចារ្យ និង បុគ្គលិកទាំងអស់ ដែលបានគ្រប់គ្រងសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច នេះបានយ៉ាងល្អក្លាយជា សាកលវិទ្យាល័យគំរូមួយក្នុងប្រទេសកម្ពុជា។

សូមថ្លែងអំណរគុណចំពោះ **សាស្ត្រាចារ្យ សាន មន្និយ៉ា** ដែលបានចំណាយពេលវេលា ដ៏មានតម្លៃ ក្នុងការ ណែនាំបង្ហាត់បង្ហាញ ផ្តល់នូវដំបូន្មាន ចង្អុលបង្ហាញ កែប្រែនូវចំណុចខ្វះខាតមួយចំនួនដែលកើតមានឡើងនៅក្នុងអត្ថបទ និងវិធីសាស្ត្រល្អៗ ក្នុងការសរសេរ សារណាបញ្ចប់ការសិក្សា នេះឡើង។

សូមថ្លែងអំណរគុណដល់មិត្តនិស្សិតទាំងអស់ ជាពិសេសថ្នាក់B4A2ដែលបានជួយផ្តល់ជាកម្លាំងចិត្តនិងទំនុកចិត្តដល់យើងខ្ញុំក្នុងការសរសេរសារណានេះឡើង។

សូមថ្លែងអំណរគុណ ដល់រៀមច្បងដែលបានបន្សល់ទុកស្នាដៃល្អៗជាច្រើន សម្រាប់ទុកជាគំរូ និងជាពត៌មានដ៏មានតម្លៃដល់នាងខ្ញុំផ្ទាល់ ក៏ដូចជាប្អូនៗនិស្សិតជំនាន់ក្រោយក្នុងការសិក្សាស្រាវជ្រាវបន្តទៀត។

ជាចុងក្រោយនាងខ្ញុំសូមគោរពជូនពរដល់ លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកស្រីសាស្ត្រាចារ្យ បុគ្គលិកសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច និងមិត្តនិស្សិតទាំងអស់ ឲ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ និងទទួលបានជោគជ័យគ្រប់ភារកិច្ចទាំងអស់។

# អារម្ភកថា

របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា ដែលលោកអ្នកកំពុងកាន់នៅក្នុងដៃនេះ គឺជាការខិតខំស្រាវជ្រាវ និងចងក្រងឡើងយ៉ាងយកចិត្តទុកដាក់បំផុត ដោយក្រុមយើងខ្ញុំ ដែលទាក់ទងទៅនឹង ទីផ្សារមូលបត្រនៅកម្ពុជា ជាពិសេសផ្តោតសំខាន់ទៅលើ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនៅកម្ពុជា (IPO) ដោយផ្អែកទៅតាមចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលដែលបានខិតខំបង្កើតឲ្យមាននូវវិស័យមូលបត្រនេះឡើង។

ក្រុមយើងខ្ញុំសង្ឃឹមថា របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សានេះ អាចជាប្រយោជន៍ ដល់ សិស្សនិស្សិត សាធារណៈជន និង អ្នកវិនិយោគិនទាំងអស់ដែលមានចំណាប់អារម្មណ៍ ចង់សិក្សាស្វែងយល់បន្ថែម ពីទីផ្សារមូលបត្រកម្ពុជា ជាពិសេសដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនៅកម្ពុជា (IPO)។ ចំពោះបញ្ហាផ្សេងៗ ដែលមិត្តនិស្សិត និងសាធារណៈជនទាំងអស់ ចង់ដឹងនិងមានចម្ងល់នោះក្រុមនាងខ្ញុំនិងធ្វើការបកស្រាយជូនតាមលទ្ធភាពដែលអាចធ្វើទៅបាន ដូចដែលបានចងក្រងនៅក្នុងអត្ថបទស្រាវជ្រាវនេះ។

របាយការណ៍ស្រាវជ្រាវនេះត្រូវបានចងក្រងឡើង និងដកស្រង់ចេញពីឯកសារផ្សេងៗជាច្រើនទៀត ដែលទាក់ទងទៅនឹង ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង (IPO) នៅកម្ពុជា និងត្រូវបានត្រួតពិនិត្យ កែលំអរជាច្រើនលើកច្រើនសារ តែទោះជាយ៉ាងណាក៏ដោយនាងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវស្តីពី ដំណើរការនៃការបោះផ្សាយលក់មូលបត្រនៅកម្ពុជា នេះពិតជាមានការខ្វះខាតអត្ថន័យ ឬការប្រើពាក្យពេចន៍ខុសឆ្គង ឬកំហុសឆ្គងអក្ខរាវិរុទ្ធកន្លែងណាមួយ ដោយអចេតនាជាក់ជាពុំខាន។ អាស្រ័យហេតុដូចនេះសមាជិកក្រុមយើងខ្ញុំរង់ចាំទទួលនូវការរិះគន់ និងស្ថាបនាកែលម្អរ ពីសំណាក់បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ដោយក្តីសោមនស្សរីករាយ និងជាទីមោទនបំផុត។ នាងខ្ញុំសូមអរគុណទុកជាមុនរាល់ការរិះគន់ស្ថាបនាកែលម្អរ ពីណាក់បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់។

ជាចុងក្រោយនាងខ្ញុំសូមថ្លែងអំណគុណ ដល់មិត្តនិស្សិត អ្នកអានទាំងអស់ និងសូមឲ្យមិត្តនិស្សិតទទួលបានជោគជ័យក្នុងការសិក្សា ក្លាយជាធនធានក្នុងការអភិវឌ្ឍប្រទេសជាតិ និងប្រើប្រាស់ឯកសារមួយនេះឲ្យមានប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីអភិវឌ្ឍវិស័យមូលបត្រនៅកម្ពុជាឲ្យកាន់តែរីកចម្រើនឡើង។

សូមអគុណ

# មាតិកា

ទំព័រ


បញ្ជីអក្សរកាត់ ....................vi
បញ្ជីតារាង ....................vii
បញ្ជីរូបភាព ....................vii


## សេចក្តីផ្តើម


១. លំនាំបញ្ហានៃការស្រាវជ្រាវ ....................១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ....................២
៣. គោលបំណងនៃការស្រាវជ្រាវ ....................៣
៤. ដែនកំណត់នៃការស្រាវជ្រាវ ....................៣
៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ....................៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ....................៤
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ....................៤


## ជំពូកទី១

## រំលឹកទ្រឹស្តីក្នុងវិស័យមូលបត្រ


១.១. ប្រវត្តិទីផ្សារមូលបត្រ ....................៦
១.២. អ្វីទៅជាមូលបត្រ? ....................៧
១.២.១.និយមន័យ ....................៧
១.២.២. ប្រភេទនៃមូលបត្រ ....................៧
១.២.២.១. មូលបត្រកម្មសិទ្ធ ....................៧
១.២.២.២. មូលបត្របំណុល ....................៩
១.២.២.៣. ឧបករណ៍និស្សន្ទ ....................១០
១.៣. ទីផ្សារមូលបត្រ ....................១០
១.៣.១. និយមន័យ ....................១០
១.៣.២. ប្រភេទនៃទីផ្សារមូលបត្រ ....................១១
១.៣.២.១. ទីផ្សារដំបូង ....................១១
១.៣.២.២. ទីផ្សារបន្ទាប់ ....................១២

១.៤. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ......១៣
១.៤.១. ក្រុមហ៊ុនបោះផ្សាយ......១៣
១.៤.២. អន្តរការទីផ្សារមូលបត្រ......១៣
១.៤.៣. វិនិយោគិន......១៣
១.៥. តួនាទីទីផ្សារមូលបត្រនៅក្នុងសេដ្ឋកិច្ច......១៤
១.៦. សារៈសំខាន់នៃទីផ្សារមូលបត្រ......១៤
១.៦.១.សារៈសំខាន់នៃទីផ្សារមូលបត្រសម្រាប់ វិនិយោគិន......១៥
១.៦.២. សារៈសំខាន់នៃទីផ្សារមូលបត្រសម្រាប់ ក្រុមហ៊ុនបោះផ្សាយ......១៦
១.៦.៣. សារៈសំខាន់នៃទីផ្សារមូលបត្រសម្រាប់ សេដ្ឋកិច្ចជាតិ......១៦

## ជំពូកទី២

## ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា

២.១. ប្រវត្តិនៃការបង្កើតនិយ័តករមូលបត្រកម្ពុជា......១៧
២.២. ចក្ខុវិស័យ និងបេសកកម្ម......១៨
២.២.១. ចក្ខុវិស័យ......១៨
២.២.២. បេសកកម្ម......១៨
២.៣. ទីតាំងរបស់និយ័តករមូលបត្រកម្ពុជា......១៨
២.៤. រូបសញ្ញា និងអត្ថន័យ......១៩
២.៤.១. រូបសញ្ញា......១៩
២.៤.២. អត្ថន័យនៃរូបសញ្ញា......១៩
២.៤.៣. ត្រារបស់និយ័តករមូលបត្រកម្ពុជា......២០
២.៥. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា......២០
២.៦. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា......២១
២.៧. មុខងាររបស់និយ័តករមូលបត្រកម្ពុជា......២៥

## ជំពូកទី៣

## ស្ថានភាពទូទៅនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣.១. ប្រវត្តិនៃការបង្កើតទីផ្សារមូលបត្រកម្ពុជា......២៦
៣.២. ចក្ខុវិស័យ និងបេសកកម្មរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា......២៧

៣.២.១. ចក្ខុវិស័យ ....................................................................................................... ២៧
៣.២.២. បេសកកម្ម ....................................................................................................... ២៧
៣.៣. នាមករណ៍ ផ្លាកសញ្ញា ....................................................................................................... ២៧
៣.៤. រចនាសម្ព័ន្ធនៃការគ្រប់គ្រង ....................................................................................................... ២៨
៣.៥. ក្រុមប្រឹក្សាភិបាល ....................................................................................................... ២៨
៣.៦. ពត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ....................................................................................................... ២៩

## ជំពូកទី៤

## ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង

៤.១. តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ ....................................................................................................... ៣០
៤.១.១. ក្រុមហ៊ុនបោះផ្សាយ ....................................................................................................... ៣០
៤.១.២. ប្រតិបត្តិករមូលបត្រ ....................................................................................................... ៣៨
៤.១.២.១. ប្រតិបត្រិករទីផ្សារមូលបត្រ ....................................................................................................... ៣៨
៤.១.២.២. ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ....................................................................................................... ៣៨
៤.១.២.៣. ប្រតិបត្តិកររក្សាទុកមូលបត្រ ....................................................................................................... ៣៨
៤.១.៣. អន្តរការីមូលបត្រ ....................................................................................................... ៣៨
៤.១.៣.១. ក្រុមហ៊ុនធានាទិញមូលបត្រ ....................................................................................................... ៣៨
៤.១.៣.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ....................................................................................................... ៣៩
៤.១.៣.៣. ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ ....................................................................................................... ៣៩
៤.១.៣.៤. ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ....................................................................................................... ៤០
៤.១.៤. ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ....................................................................................................... ៤០
៤.១.៤.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ....................................................................................................... ៤០
៤.១.៤.២. ភ្នាក់ងារបញ្ជីការមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ ....................................................................................................... ៤០
៤.១.៥. វិនិយោគិនមូលបត្រ ....................................................................................................... ៤១
៤.២. លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ....................................................................................................... ៤១
៤.២.១. លក្ខខណ្ឌតម្រូវជាតួលេខ ....................................................................................................... ៤១
៤.២.២. លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ ....................................................................................................... ៤២
៤.២.៣. អភិបាលកិច្ចសាជីវកម្ម ....................................................................................................... ៤២

៤.២.៤. របាយការណ៍ហិរញ្ញវត្ថុ ......................................................................................... ៤៣
៤.២.៥. ឯកសារផ្តល់ពត៌មាន ......................................................................................... ៤៣
៤.៣. ដំណើរការធ្វើIPO ......................................................................................... ៤៤
៤.៣.១. ការរៀបចំខ្លួនរបស់ក្រុមហ៊ុនបោះផ្សាយ ......................................................................................... ៤៥
៤.៣.១.១. ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រ ......................................................................................... ៤៥
៤.៣.១.២. ការជ្រើសរើស និងតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ ......................................................................................... ៤៦
៤.៣.១.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រ ......................................................................................... ៤៦
៤.៣.១.៤. ការត្រួតពិនិត្យការបំពេញការតព្វកិច្ចតាមច្បាប់ ......................................................................................... ៤៧
៤.៣.២. ការពិនិត្យលើលទ្ធភាពចុះបញ្ជី ......................................................................................... ៤៧
៤.៣.២.១. ការដាក់ពាក្យស្នើសុំពិនិត្យលើលទ្ធភាពចុះបញ្ជី ......................................................................................... ៤៧
៤.៣.២.២. ការជូនដំណឹងពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី ......................................................................................... ៤៨
៤.៣.៣. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ ......................................................................................... ៤៩
៤.៣.៣.១. ការដាក់ពាក្យស្នើសុំបោះផ្សាយលក់ជាសាធារណៈ ......................................................................................... ៤៩
៤.៣.៣.២. ការកំណត់ថ្លៃលក់មូលបត្រ ......................................................................................... ៤៩
៤.៣.៣.៣. ការស្នើសុំបញ្ជាក់ការដាក់ថ្លៃលក់មូលបត្រ ......................................................................................... ៥០
៤.៣.៣.៤. ការស្នើរសុំអនុញ្ញាត្តិលើសំណើរលក់មូលបត្រ ......................................................................................... ៥០
៤.៣.៣.៥. ការធ្វើបរិវិសកម្ម ......................................................................................... ៥០
៤.៣.៣.៦. ការរាយការណ៍ពីលទ្ធផលធ្វើបរិវិសកម្ម ......................................................................................... ៥១
៤.៣.៤. ការចុះបញ្ជីជាផ្លូវការនៅន.ម.ក ......................................................................................... ៥១
៤.៣.៤.១.ការដាក់ពាក្យចុះបញ្ជីជាផ្លូវការ ......................................................................................... ៥១
៤.៣.៤.២. ការផ្តល់ការអនុញ្ញាតិនៃការចុះបញ្ជី និងការជួញដូរជាផ្លូវការ ......................................................................................... ៥១
៤.៤. ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់ ......................................................................................... ៥២
៤.៤.១. កាតព្វកិច្ច និងនីតិវិធីផ្តល់ពត៌មាន ......................................................................................... ៥២
៤.៤.២. កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន ......................................................................................... ៥២
៤.៤.៣. ការព្យួរការជួញដូរ និងការចាប់ផ្តើមការជួញដូរសារជាថ្មី ......................................................................................... ៥២
៤.៤.៤. ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធបន្ថែម ......................................................................................... ៥២
៤.៥. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ ......................................................................................... ៥២

៤.៥.១. ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ ................................ ៥២
៤.៥.២. ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ........................................................ ៥៣
៤.៥.៣. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធប្រចាំឆ្នាំ .......................................................... ៥៣
៤.៦.ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ........... ៥៤
៤.៦.១. ចំណុចខ្លាំង ..................................................................................................... ៥៤
៤.៦.២. ចំណុចខ្សោយ.................................................................................................... ៥៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ............................................................................................................ ៥៦
២. ការផ្តល់អនុសាសន៍ ........................................................................................................៥៧

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.ម.ក. | : គណកម្មការមូលបត្រកម្ពុជា |
| ន.ម.ក | : និយ័តករមូលបត្រកម្ពុជា |
| ផ.ម.ក. | : ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា |
| CSX | : Cambodia Securities Exchange ( ផ្សារមូលបត្រកម្ពុជា ) |
| IPO | : ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង |
| T-bill | : Treasury/ Government Bill |
| T-notes | : Treasury/ Government Note |
| T-bond | : Treasury/ Government Bond |
| TIPS | : Treasury Inflation-Protected Securities |

# បញ្ជីតារាង

តារាង១. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPPWSA ............................ ៣១

តារាង២. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ GTI ................................ ៣២

តារាង៣. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPPAP ............................... ៣៣

តារាង៤. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ PPSP ............................... ៣៤

តារាង៥. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPAS ................................ ៣៥

តារាង៦. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ ACLEDA .......................... ៣៦

តារាង៧. តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPEPC ............................... ៣៧

តារាងទី៨. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ ..................................................................... ៥៣

តារាងទី៩. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធប្រចាំឆ្នាំ......................................................... ៥៣

# បញ្ជីរូបភាព


រូបភាពទី១. អាគាររបស់និយ័តករមូលបត្រកម្ពុជា........................................................................១៩
រូបភាពទី២. រូបសញ្ញារបស់និយ័តករមូលបត្រកម្ពុជា.................................................................. ២១
រូបភាពទី៣. ត្រារបស់និយ័តករមូលបត្រកម្ពុជា............................................................................២៣
រូមភាពទី៤. រចនាសម្ព័ន្ធចាត់តាំងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា.............................................. ២៤
រូបភាពទី៥. បេសកកម្មរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា..........................................................២៧
រូបភាពទី៦. ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រ .................................................................. ២៨
រូបភាពទី៧. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា............................................. ២៨
រូបភាពទី៨.ស្លាកសញ្ញាPPWSA ............................................................................................. ៣១
រូបភាពទី៩.ស្លាកសញ្ញា GTI ....................................................................................................៣២
រូបភាពទី១០.ស្លាកសញ្ញា PPAP ...............................................................................................៣៣
រូបភាពទី១១.ស្លាកសញ្ញា PPSP .............................................................................................. ៣៤
រូបភាពទី១២.ស្លាកសញ្ញា PAS ................................................................................................ ៣៥
រូបភាពទី១៣.ស្លាកសញ្ញាACLEDA.......................................................................................... ៣៦
រូបភាពទី១៤.ស្លាកសញ្ញាPEPC...............................................................................................៣៧

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ក្រោយពីបានបញ្ចប់សង្គ្រាមរ៉ាំរ៉ៃ ដែលកើតមានឡើង ជាច្រើនទសវត្សចុងក្រោយនេះមក បច្ចុប្បន្ននេះ ប្រទេសកម្ពុជាបានខិតខំប្រែក្លាយខ្លួនពីប្រទេសកំពុងអភិវឌ្ឍន៍ ដែកមានចំណូលកំរិតទាប ទៅជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានចំណូលកម្រិតមធ្យមវិញ។ ភាពរីកចម្រើនទាំងនេះកើតឡើងបានដោយសារតែប្រទេសកម្ពុជាមានស្ថេរភាពខាងនយោបាយ និងមានទំនាក់ទំនងល្អជាមួយបណ្តាប្រទេសផ្សេងៗទៀតទូទាំងពិភពលោក។ លើសពីនេះទៅទៀត ប្រទេសកម្ពុជាបាននឹងកំពុងតែរក្សាកំណើនសេដ្ឋកិច្ចរបស់ខ្លួនពីចន្លោះ ៧ទៅ៨ភាគរយក្នុងមួយឆ្នាំៗ។ បច្ចុប្បន្ននេះប្រទេសកម្ពុជា បាននឹងកំពុងខិតខំអភិវឌ្ឍន៍ប្រទេសយ៉ាងខ្លាំង ដើម្បីទទួលបាននូវភាពរីកចម្រើន លើគ្រប់វិស័យ។ ស្របពេលជាមួយគ្នានោះ មានវិស័យមួយ ដែលបានលេចឡើង ហើយកំពុងតែរីកចម្រើនគួរឲ្យគាត់សម្គាល់ផងដែរ នោះគឺវិស័យមូលបត្រនៅកម្ពុជា។

វិស័យមូលបត្រនៅកម្ពុជា ជាកម្លាំងចលករមួយសំខាន់ក្នុងការ ជំរុញឲ្យសេដ្ឋកិច្ចមានការរីកចម្រើន។ ទីផ្សារមូលបត្រដើរតួនាទី ជាអន្តរការីហិរញ្ញវត្ថុយ៉ាងសំខាន់ ដែលនាំឲ្យមានការជួបគ្នាដោយផ្ទាល់ រវាងអ្នកដែលមានមូលធននៅទំនេរ និងអ្នកដែលមានតម្រូវការប្រើប្រាស់មូលធន។ វិស័យមូលបត្របានដើរ តួនាទីយ៉ាងសំខាន់ក្នុងការបង្ករលក្ខណៈងាយស្រួល ដល់ក្រុមហ៊ុនសាជីវកម្មឬ នីតិបុគ្គលទាំងឡាយណា ដែលមានតម្រូវការមូលធនបន្ថែម ឬសម្រាប់វិនិយោគិនទាំងឡាយណា ដែលមានមូលធននៅទំនេរ អាចធ្វើការវិនិយោគឬទទួលបានមូលធនបន្ថែម តាមរយៈ ការទិញ បោះផ្សាយលក់ឧបករណ៍ហិរញ្ញវត្ថុ(បណ្ណ័បំណុល បណ្ណ័ភាគហ៊ុន) នៅលើទីផ្សារមូលបត្រ។ ចរន្តនៃលំហូរសេដ្ឋកិច្ចបែបនេះ ជាសកម្មភាពមួយ រួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដោយជំរុញឲ្យសេដ្ឋកិច្ចកាន់តែមានភាពរីកចម្រើនឡើង ដូចបណ្តាលប្រទេសជឿនលឿនមួយចំនួន។

សម្រាប់ប្រទេសកម្ពុជា ទោះបីជាវិស័យមូលបត្រនេះទទួលបានការចាប់អារម្មណ៍យ៉ាងច្រើនពីសំណាក់មហាជន និងវិនិយោគិនក៏ដោយ ប៉ុន្តែយើងអាចនិយាយបានថាកម្ពុជា ពិតជាមានភាពក្មេងខ្ចីមែនទែនចំពោះវិស័យមួយនេះ ។ ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាល បានបង្កើតឲ្យមាន និយ័តករមូលបត្រកម្ពុជា ឡើងដើម្បីដើរតួនាទីយ៉ាងសំខាន់ ក្នុងការតាក់តែងច្បាប់ស្ដីពីការប្រព្រឹត្តទៅនូវទីផ្សារមូលបត្រ នីតិវិធីក្នុងការបោះផ្សាយ និងនីតិវិធីជួញដូរមូលបត្រ លក្ខខណ្ឌក្នុងការចូលរួមរបស់វិនិយោគិន ធ្វើការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់សារធារណៈជន តាមរយៈវិធីសាស្ត្រផ្សេងៗជាច្រើនរួមមានដូចជា តាមរយៈសិក្ខាសាលា ក៏ដូចជាតាមរយៈបណ្តាញសង្គម និងនៅលើគេហទំព័រផ្ទាល់ខ្លួនរបស់និយ័តករមូលបត្រកម្ពុជាផងដែរ។ក្រោយមកទៀតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ក៏ត្រូវបានបង្កើតឡើង ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្រិការរក្សាទុកមូលបត្រ។

តាមរយៈការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល វិស័យថ្មីមួយនេះ កំពុងតែទទួលបានការចាប់អារម្មណ៍ពីសំណាក់ មហាជន វិនិយោគិន និងក្រុមឯកហ៊ុនឯកជន។ ការទាក់ទាញនេះបានធ្វើឲ្យមហាជន មានការចង់ដឹង ពីវិស័យមួយនេះ ជាពិសេសពាក់ព័ន្ធនឹង នីតិវិធីនៃការបោះផ្សាយមូលបត្រ ការជួញដូរនៅលើទីផ្សារ និងទិន្នន័យទីផ្សារដែលកំពុងជួញដូរនាពេលបច្ចុប្បន្ននេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

វិស័យមូលបត្រ ជាកម្លាំងចលករមួយ ក្នុងការជំរុញឲ្យសេដ្ឋកិច្ចកម្ពុជា មានការរីកចម្រើន ប៉ុន្តែទោះបីជាយ៉ាងណាក្តី វិស័យមូលបត្រជាវិស័យមួយដែលមានភាពស្មុកស្មាញ ទាមទារឲ្យវិនិយោគិន ត្រូវមានចំណេះដឹងជំនាញ និងបទពិសោធន៍ខ្ពស់ក្នុងការវិនិយោគ ដើម្បីជៀសវៀងពីហានិភ័យនានា ដែលអាចកើតមានឡើងដោយចៃដន្យ។ ចំពោះវិស័យមូលបត្រ ទើបតែមានវត្តមាននៅក្នុងប្រទេសកម្ពុជា ជិតមួយទស្សវត្សន៍តែប៉ុណ្ណោះ ដូច្នេះហើយ សាធារណៈជនកម្ពុជាទូទៅ និងវិនិយោគិនភាគច្រើនពុំទាន់យល់បានស៊ីជម្រៅនៅឡើយពីវិស័យមួយនេះ ថាតើវាមានដំណើរការយ៉ាងដូចម្តេច។

ដោយមើលឃើញ ពីដំណើរការវិវត្តន៍ សារៈសំខាន់ និងកង្វះខាតនៃវិស័យមូលបត្រ នៅប្រទេសកម្ពុជា ទើបសមាជិកក្រុមរបស់នាងខ្ញុំ សម្រេចចិត្តធ្វើការសិក្សាស្រាវជ្រាវ ពីវិស័យមូលបត្រនៅកម្ពុជា ជាពិសេស ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនៅកម្ពុជា ដើម្បីឲ្យអ្នកសិក្សាស្រាវជ្រាវ មហាជន និងវិនិយោគិន យល់ដឹងកាន់តែច្បាស់ និងទូលំទូលាយពី ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជា សាធារណៈលើកដំបូង និងដើម្បីជាការទាក់ទាញអ្នកវិនិយោគ ឲ្យងាកមកវិនិយោគកាន់តែច្រើនឡើងលើវិស័យមូលបត្រ។

ខាងក្រោមនេះជាចំណោទបញ្ហា លើប្រធានបទ ដែលក្រុមយើងខ្ញុំលើកយកមកសិក្សា៖

- តើទីផ្សារមូលបត្រកម្ពុជា មានតួនាទីអ្វីខ្លះ?
- តើប្រតិបត្តិការនៃការបោះផ្សាយលក់និងជួញដូរមូលបត្រកម្មសិទ្ធនៅកម្ពុជា ធ្វើឡើងដោយមានលក្ខណៈយ៉ាងដូចម្តេច?
- តើគេកំណត់ថ្លៃ មូលបត្រកម្មសិទ្ធបានយ៉ាងដូចម្តេច?
- តើមូលបត្រកម្មសិទ្ធ ត្រូវបានដាក់លក់ និងទិញតាមវិធីសាស្ត្រណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ គឺផ្តោតសំខាន់ទៅលើ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង ដែលគោលបំណងនៃការស្រាវជ្រាវ អាចសង្ខេបបានដូចខាងក្រោម៖

- រំលឹក និងស្វែងយល់ពីទ្រឹស្តីទូទៅទាក់ទងនឹងវិស័យមូលបត្រ

- ការសិក្សាស្វែងយល់ពី ប្រវត្តិនិងស្ថានភាពទូទៅ របស់ និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា
- ស្វែងយល់ពី និតិវិធីក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង នៅកម្ពុជា
- ស្វែងរកចំណុចខ្លាំង និងចំណុចខ្សោយ នៃដំណើរការបោះផ្សាយលក់មូលបត្រ និងផ្តល់ជាអនុសាសន៍ខ្លះៗ ដើម្បីឲ្យវិស័យមូលបត្រនៅកម្ពុជាកាន់តែរីកចម្រើនជាងមុន។

## ៤. ទំហំ និងដែនកំណត់ស្រាវជ្រាវ

វិស័យមូលបត្រនៅកម្ពុជា ជាវិស័យមួយដែលថ្មី ហើយមានលក្ខណៈទូលំទូលាយ និងមានច្រើនបែបច្រើនទំរង់ ហេតុនេះហើយការសិក្សាស្រាវជ្រាវរបស់ក្រុមនាងខ្ញុំ គឺផ្តោតសំខាន់ទៅលើតែ ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងតែប៉ុណ្ណោះ។

## ៥.វិធីសាស្ត្រស្រាវជ្រាវ

❖ ទិន្នន័យចម្បង

ទិន្នន័យនេះទទួលបានពីការចុះដោយផ្ទាល់ នៅនិយ័តករមូលបត្រកម្ពុជា និងនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា តាមរយៈការសាកសួរព័ត៌មាន និងចម្លល់ផ្សេងៗ ផ្ទាល់ជាមួយនឹងមន្រ្តីជំនាញ ដែលទាក់ទងនឹងប្រធានបទដើម្បីបានជាព័ត៌មាននិងទិន្នន័យលម្អិត ច្បាស់លាស់ សម្រាប់យកមកធ្វើការសិក្សា។

❖ ទិន្នន័យបន្ទាប់បន្សំ

ទិន្នន័យនេះគឺជា ទិន្នន័យដែលទទួលបានពីឯកសារផ្សេងៗ ដែលមានស្រាប់នៅក្នុងគ្រឹះស្ថានពាក់ព័ន្ធនៅតាមបណ្ណាល័យ គេហទំព័រ និងឯកសារដ៏ទៃជាច្រើនទៀតដែលទាក់ទងទៅនឹង ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវអំពីប្រធានបទដែលស្តីអំពី ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង គឺពិតជាមានសារៈសំខាន់ និងផ្តល់ផលប្រយោជន៍យ៉ាងច្រើន ដូចជា៖

❖ ចំពោះខ្លួននាងខ្ញុំផ្ទាល់

- បង្កើនចំនេះដឹងផ្ទាល់ខ្លួនកាន់តែច្រើន និងការយល់ដឹងថ្មីៗតាមរយៈការប្រមូលឯកសារ និងព័ត៌មានជាក់ស្តែង
- ទទួលបានចំនេះដឹងនិង យល់ដឹងកាន់តែច្បាស់ពី ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង នៅកម្ពុជា និងទទួលបានបទពិសោធន៍ថ្មីៗជាច្រើន។
- អាចចាប់ផ្តើម វិនិយោគលើវិស័យមូលបត្របាន។

❖ ចំពោះវិស័យមូលបត្រ

- ចាត់ទុកជាការផ្សព្វផ្សាយដល់សាធារណៈជន ឲ្យស្គាល់ច្បាស់ពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធនៅកម្ពុជា ។
- ផ្តល់ជាពត៌មានបន្ថែមដល់ វិនិយោគិនស្តីពីប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធនៅកម្ពុជា។
- អាចទាក់ទាញវិនិយោគិន ឲ្យងាកមកវិនិយោគក្នុងវិស័យមូលបត្រកាន់តែច្រើន។
- អាចធ្វើឲ្យវិស័យមូលបត្រមានការរីកចម្រើនជាងមុន។

❖ ចំពោះអ្នកសិក្សាស្រាវជ្រាវ

- ជំនួយជាស្មារតីសំរាប់អ្នកដែលមាន បំណងចង់ស្វែងយល់បន្ថែមពីវិស័យមូលបត្រនៅកម្ពុជា។
- អាចទុកជាឯកសារ សម្រាប់សិស្សនិស្សិតជំនាន់ក្រោយ ដែលមានគោលបំណងស្វែងយល់ពីដំណើរការបោះផ្សាយលក់ មូលបត្រកម្មសិទ្ធនៅកម្ពុជា និងធ្វើការសិក្សាស្រាវជ្រាវបន្ត។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជំនួយដល់អ្នកអាន ឲ្យមានភាពងាយស្រួលយល់ពីអត្ថន័យ និងគំនិតសំខាន់ៗក្នុងរបាយការណ៍ស្រាវជ្រាវនេះ ការសិក្សាស្រាវជ្រាវស្តីពី ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង ត្រូវបានបែងចែកទៅតាមផ្នែក តាមជំពូក ដូចខាងក្រោម៖

❖ សេចក្តីផ្តើម

❖ ជំពូក១៖ រំលឹកទ្រឹស្តីទូទៅស្តីពីវិស័យមូលបត្រ

- និយមន័យមូលបត្រ
- ប្រភេទនៃមូលបត្រ
- ទីផ្សារមូលបត្រ
- អ្នកចូលរួមក្នុងទីផ្សារមូលបត្រ

❖ ជំពូកទី២៖ ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា

- ប្រវត្តិ និងស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា
- និមិត្តសញ្ញា និងអត្ថន័យ
- ចក្ខុវិស័យ បេសកម្ម និងគោលដៅការងារ
- រចនាសម្ព័ន្ធនៃការគ្រប់គ្រង

❖ ជំពូក៣៖ ទិដ្ឋភាពទូទៅនៃក្រុមហ៊ុនផ្សារមូលបត្រ

- ប្រវត្តិ និងស្ថានភាពទូទៅរបស់ក្រុមហ៊ុនផ្សារមូលបត្រ

- និមិត្តសញ្ញា និងអត្ថន័យ
- ចក្ខុវិស័យ បេសកម្ម និងគោលដៅការងារ
- រចនាសម្ព័ន្ធនៃការគ្រប់គ្រង

❖ ជំពូក៤៖ ដំណើរការបោះផ្សាយលក់ មូលបត្រកម្មសិទ្ធជាលើកដំបូង

- ការរៀបចំខ្លួនរបស់ក្រុមហ៊ុនបោះផ្សាយ
- ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជី
- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ
- ការចុះបញ្ជីជាផ្លូវការនៅផ.ម.ក

❖ សេចក្តីសន្និដ្ឋាន និងការផ្តល់អានុសាសន៍

- សេចក្តីសន្និដ្ឋាន
- ការផ្តល់អនុសាសន៍

# ជំពូកទី១

# រំលឹកទ្រឹស្តីក្នុងវិស័យមូលបត្រ

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. ប្រវត្តិទីផ្សារមូលបត្រ

នាពេលបច្ចុប្បន្ន ទីផ្សារមូលបត្រកំពុងមានការពេញនិយមយ៉ាងខ្លាំងនៅតាមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន ខណៈនៅកម្ពុជាក៏មានការចូលរួមគួរឲ្យកត់សម្គាល់ផងដែរ ប៉ុន្តែតើអ្នកដឹងទេថា ទីផ្សារមូលបត្រនេះមានប្រវត្តិកកើតឡើងតាំងពីពេលណា ហើយនៅកន្លែងណា?

ទីផ្សារភាគហ៊ុន មានប្រវត្តិកកើតឡើងដំបូងនៅលើទឹកដីអឺរ៉ុប ចាប់តាំងពីដើមសតវត្សរ៍ទី១៧ ដោយនៅគ្រិស្តសរាជ ១៦០២ មានអ្នកជំនួញពាណិជ្ជកម្មជាច្រើននៅទីក្រុងអាំស្ទែដាំ ក្នុងប្រទេសសាធារណៈរដ្ឋហូឡង់បានចាប់ផ្តើមចេះបង្កើតសហគ្រាសធំៗ និងប្រកបអាជីវកម្មខ្នាតធំដែលត្រូវការដើមទុនជាច្រើន ប៉ុន្តែពួកគេបែរជាជួបប្រទះនូវបញ្ហាខ្វះដើមទុន ក្នុងការពង្រីកសហគ្រាស និងអាជីវកម្មរបស់ខ្លួន។ ពួកគេក៏ចាប់ផ្តើមមានគំនិតបើកឲ្យមានការសន្សំដើមទុនរួមតែមួយ ហើយអ្នកជំនួញទាំងអស់នោះក៏បានប្រមូលយកប្រាក់សន្សំទាំងនោះទៅធ្វើការវិនិយោគទុនរួម ដើម្បីសហការធ្វើជាដៃគូពាណិជ្ជកម្មជាមួយគ្នា ដែលមានចំណែកភាគហ៊ុនរៀងៗខ្លួននៅក្នុងអាជីវកម្មខ្នាតធំនោះ។

ចំណែកក្រុមហ៊ុនវិនិយោគទុនរួមដំបូងគេបង្អស់គឺមានដើមកំណើតនៅ ប្រទេសហូឡង់ ដោយក្រុមហ៊ុននេះបានចូលរួមដោះស្រាយនូវវិបត្តិហិរញ្ញវត្ថុជូនដល់ម្ចាស់អាជីវកម្មទាំងអស់។ បន្ទាប់មក ក្រុមហ៊ុនហូឡង់ឥណ្ឌាបូព៌ា (The Dutch East India) បានចាប់ផ្តើមបោះផ្សាយក្រដាសដែលតំណាងឲ្យ ភាគហ៊ុនជាលើកដំបូងដើម្បីជួញដូរទិញលក់ ជាមួយម្ចាស់អាជីវកម្មផ្សេងៗទៀត ហើយវាបានរីករាលដាលទៅដល់ ប្រទេសព័រទុយហ្កាល់ ប្រទេសអេស្ប៉ាញ បារាំង ចក្រភពអង់គ្លេសជាដើម។ ពួកគេបានចាប់ផ្តើមបង្កើតឲ្យមានការលក់ភាគហ៊ុនដើម្បីជាឧបករណ៍ក្នុងការប្រមូលដើមទុន យកទៅពង្រីកមុខជំនួញរបស់គេ រហូតធ្វើឲ្យមានចរន្តនៃបដិវត្តន៍ឧស្សាហកម្មលើកដំបូងនាសតវត្សរ៍ទី១៨។ ការហូរចូលនៃមូលធននេះបានបន្តឲ្យមានការរកឃើញ និងការអភិវឌ្ឍនៃពិភពលោកថ្មី ( The New World ) និងការរីកលូតលាស់នៃឧស្សាហកម្មសម័យទំនើប។

រហូតដល់គ្រិស្តសករាជ១៧៧៣ ការជួញដូរភាគហ៊ុនកាន់តែរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ ការកើនឡើងនូវបរិមាណជួញដូរភាគហ៊ុន បានជំរុញឲ្យមានការបង្កើតឡើងនូវ ទីកន្លែងច្បាស់លាស់មួយសម្រាប់ឲ្យពួកគេជួញដូរ។ ជាលទ្ធផល ពាណិជ្ជករភាគហ៊ុនដែលមកពីគ្រប់ទីកន្លែង ក៏បានសម្រេចចិត្តមកជួបជុំគ្នា ក្នុងហាងកាហ្វេមួយដែលស្ថិតនៅក្នុងទីក្នុងឡុងដ៍ ចក្រភពអង់គ្លេស ហើយក្រោយមកពួកគេក៏បានសម្រេចចិត្តទិញយកនិងបានកែប្រែឈ្មោះខាងកាហ្វេនោះទៅជាទីផ្សារភាគហ៊ុន ដែលមានឈ្មោះថា The London Stock Exchange ដោយបានរៀបចំឲ្យមានការគ្រប់គ្រងយ៉ាងល្អត្រឹមត្រូវ។

ទីផ្សារភាគហ៊ុនទីក្រុងឡុង (The London Stock Exchange )ជាទីផ្សារជួញដូរភាគហ៊ុនផ្លូវការមុនដំបូងគេបង្អស់។ រហូតមកដល់គ្រិស្តសករាជ១៧៩០ គំនិតនៃការបង្កើតទីផ្សារមូលបត្រនេះ ក៏បានរីករាលដាលដល់សហរដ្ឋអាមេរិក ហើយបន្តសាយភាយទៅដល់ប្រទេសផ្សេងៗជាច្រើន នៅលើពិភពលោក រហូតដល់ពេលបច្ចុប្បន្ន។[១]

## ១.២. អ្វីទៅជាមូលបត្រ?

### ១.២.១.និយមន័យ

មូលបត្រ គឺជាឧបករណ៍ហិរញ្ញវត្ថុទាំងឡាយណា (មូលបត្របំណុល និង មូលបត្រកម្មសិទ្ធ ឧបករណ៍និស្សន្ទ)ដែលគេអាចជួញដូរបាន ដែលអាចមានរយៈពេលវែង និងរយៈពេលខ្លី។

### ១.២.២. ប្រភេទនៃមូលបត្រ

#### ១.២.២.១. មូលបត្រកម្មសិទ្ធ

មូលបត្រកម្មសិទ្ធិ គឺជាមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាធារណៈ (ក្រុមហ៊ុនសាជីវកម្ម) ក្នុងគោលបំណងគៀងគរមូលធនពីសាធារណៈជន ដើម្បីជាមូលធនក្នុងការពង្រីកអាជីវកម្មបន្ថែមទៀត។ការទិញយកមូលបត្រកម្មសិទ្ធនេះ អាចធ្វើឲ្យវិនិយោគិនទទួលបានភាពជាម្ចាស់ និងអាចមានសិទ្ធទទួលបានភាគលាភនៅក្នុងអង្គភាពមួយ។ ភាពជាម្ចាស់នៃទ្រព្យកម្មសិទ្ធិ នឹងផ្តល់សិទ្ធិដល់ភាគហ៊ុនិកនូវចំណែកនៃប្រាក់ចំណេញរបស់ក្រុមហ៊ុនតាមរយៈភាគលាភ ហើយវិនិយោគិនដែលបានទិញនូវមូលបត្រកម្មសិទ្ធរបស់អង្គភាពមួយ ត្រូវព្រមទទួលយកនូវការចែករំលែក ទាំងភាពជោគជ័យនិងការបរាជ័យរបស់ក្រុមហ៊ុន។ លទ្ធផលដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនចុះបញ្ជី ជាធម្មតាអាចវាយតម្លៃបាន តាមរយៈភាគលាភដែលភាគហ៊ុនិកបានទទួល និងតាមរយៈថ្លៃភាគហ៊ុនដែលបានដាក់កំណត់ថ្លៃនៅលើទីផ្សារ។ ប្រភេទផ្សេងៗនៃមូលបត្រកម្មសិទ្ធរួមមាន[២]៖

- **ភាគហ៊ុនធម្មតា** ( **Common stock** )

ភាគហ៊ុនធម្មតា គឺជាមូលបត្រទ្រព្យដែលមិនមានរយៈពេលកំណត់ គឺតាមការស្ថិតថេររបស់ក្រុមហ៊ុន ដែលត្រូវបានបែងចែកភាគលាភនៅចុងឆ្នាំ។ ភាគហ៊ុនធម្មតា ជាភាគហ៊ុនដែលទទួលបានការលើកទឹកចិត្តដោយផ្ទាល់ ដល់អ្នកកាន់កាប់ភាគហ៊ុនតាមរយៈភាគលាភ ដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុន នៅពេលដែលក្រុមហ៊ុនសម្រេចក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន។ តម្លៃបច្ចុប្បន្នរបស់ភាគហ៊ុនធម្មតា អាចប្រែប្រួល ទៅតាមការរីកចម្រើនរបស់ក្រុមហ៊ុន។

[១] https://khmerpostasia.com/archives/62791 បានចូលទស្សនា ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១

[២]មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ, បៀន សាំង, ២០១១, ទំព័រ ៣៥.៣៦

លក្ខណៈពិសេសរបស់វាគឺ៖

- ភាគលាភមិនកំណត់៖ គឺអាស្រ័យលើផលចំណេញជាក់ស្តែងរបស់ក្រុមហ៊ុនដែលទទួលបានរាល់ឆ្នាំ និងគោលការណ៍បែងចែកផលចំណេញរបស់ក្រុមហ៊ុន។ ប្រសិនបើក្រុមហ៊ុនចំណេញច្រើនពីប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន នោះបណ្តាម្ចាស់ភាគហ៊ុនធម្មតាក៏ទទួលបានភាគលាភច្រើនដែរ តែបើក្រុមហ៊ុនខាតបង់ពីប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួន វិញនោះម្ចាស់ភាគហ៊ុនក៏មិនអាចទទួលបានភាគលាភដែរ។
- បណ្តាម្ចាស់ភាគហ៊ុនធម្មតា ( Common stock ) ភាគច្រើនទទួលបាននូវសិទ្ធមួយចំនួនដូចជាត្រូវបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល ចូលរួមបោះឆ្នោតក្នុងការសម្រេចចិត្តលើទិសដៅនិងគោលនយោបាយរបស់ក្រុមហ៊ុនជាដើម។
- នៅពេលក្រុមហ៊ុនដួលរលំ ឬពេលក្រុមហ៊ុនក្ស័យធន ម្ចាស់ភាគហ៊ុនទាំងនោះនឹងត្រូវបានចែកប្រាក់ដែលនៅសល់ ក្រោយពេលដែលបានទូទាត់បណ្តាបរិមាណបំណុល និងទូទាត់ឲ្យម្ចាស់ភាគហ៊ុនបុរិមា ( Preferred Stock ) រួចរាល់។

❖ **ភាគហ៊ុនបុរិមា ( Preferred Stock )**

ក្រៅពីភាគហ៊ុនមានសិទ្ធបោះឆ្នោត ក្រុមហ៊ុនខ្លះក៏អាចមានសិទ្ធបោះផ្សាយភាគហ៊ុនបុរិមាផងដែរ។ ភាគហ៊ុនបុរិមាផ្តល់ឲ្យអ្នកវិនិយោគ នូវហានិភ័យនៃការខាតបង់ប្រាក់វិនិយោគតិចជាង ការកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោត ប៉ុន្តែក៏ផ្តល់នូវចំណូលសរុបមានកម្រិតផងដែរ។ ចំណូលដែលអាចទទួលបានពីការវិនិយោគលើភាគហ៊ុនបុរិមា រួមមាន ចំណូលដែលទទួលបានពីការវិនិយោគជាភាគលាភ បូកជាមួយការប្រែប្រួលតម្លៃណាមួយរបស់ភាគហ៊ុននៅលើទីផ្សារ។

ជាទូទៅអ្នកកាន់កាប់ភាគហ៊ុនបុរិមាមានលក្ខណៈដូចគ្នានឹងអ្នកកាន់កាប់ភាគហ៊ុនធម្មតាដែរ ប៉ុន្តែខុសគ្នាត្រង់ អ្នកកាន់ភាគហ៊ុនបុរិមា អាចមានសិទ្ធទទួលបានភាគលាភមុខគេនៅពេលបែងចែក ហើយភាគលាភត្រូវបានកំណត់ជាក់លាក់ពីដំបូងនៅលើទឹកប្រាក់កំណត់មួយ បន្ថែមពីនេះអ្នកកាន់កាប់ភាគហ៊ុនបុរិមា ពុំមានសិទ្ធក្នុងការបោះឆ្នោតផ្សេងៗនោះទេ។ ម៉្យាងទៀតភាគហ៊ុនបុរិមា មានលក្ខណៈពិសេសដែលអាចប្តូរទៅជាភាគហ៊ុនធម្មតាវិញបាន នៅពេលវាបំពេញទៅតាមលក្ខខណ្ឌដែលបានចុះក្នុងប័ណ្ណភាគហ៊ុនបុរិមានោះ។

❖ **សក្ខីបណ្ណទទួលប្រាក់បញ្ញើ**

ជាប្រភេទមូលបត្រហិរញ្ញវត្ថុ ដែលត្រូវបានគេជួញដូរនៅលើទីផ្សារមូលបត្រក្នុងតំបន់ ដែលវាតំណាងឲ្យមូលបត្រ ដែលបានចុះបញ្ជីនៅទីផ្សារមូលបត្របរទេស។[៣]

[៣]Michael Simmons, Securities Operation LA Guide to Trade And Position Management

### ១.២.២.២. មូលបត្របំណុល

មូលបត្របំណុល ឬសញ្ញាប័ណ្ណ គឺជាមូលបត្រដែលបញ្ជាក់ពីបំណុលរយៈពេលវែងរបស់អ្នកបោះផ្សាយ ហើយអ្នកបោះផ្សាយត្រូវមានមុខងារ សងការប្រាក់ និងតម្លៃសញ្ញាបណ្ណដល់ម្ចាស់កម្មសិទ្ធសញ្ញាប័ណ្ណ នៅពេលដល់កាលកំណត់សងរបស់សញ្ញាប័ណ្ណ។ សម្រាប់អ្នកវិនិយោគលើប័ណ្ណបំណុលនេះ នឹងទទួលបាននូវអត្រាការប្រាក់ថេរមួយ អាស្រ័យទៅលើចំនួនមួយដែលបានកំណត់ជាស្រេច ទោះបីជាអត្រាការប្រាក់នៅលើទីផ្សារមានការប្រែប្រួលយ៉ាងណាក៏ដោយ។

សញ្ញាប័ណ្ណត្រូវបានបែងចែក ជាច្រើនប្រភេទខុសៗគ្នា ដោយផ្អែកទៅតាមអ្នកបោះផ្សាយ តាមកាលកំណត់សងជាដើម ប៉ុន្តែប្រសិនបើយើងធ្វើការបែងចែកសញ្ញាប័ណ្ណដោយផ្អែកទៅលើអ្នកបោះផ្សាយវិញ នោះយើងអាចចែកសញ្ញាប័ណ្ណជាពីរប្រភេទធំៗដាច់ដោយឡែកពីគ្នាគឺ ៖

❖ **សញ្ញាប័ណ្ណរដ្ឋ**

សញ្ញាប័ណ្ណរដ្ឋ គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយរដ្ឋាភិបាល ដើម្បីប្រមូលថវិការចូលរដ្ឋ ក្នុងគោលបំណង កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈផ្សេងៗដូចជា សាលារៀន មន្ទីពេទ្យ ស្ពាន ថ្នល់ជាដើម។ ជាទូទៅ សញ្ញាប័ណ្ណ ឬ ប័ណ្ណបំណុលដែលបោះផ្សាយដោយរដ្ឋាភិបាល ធានាបាននូវសុវត្ថិភាពបំផុត(គ្មានហានិភ័យ) ពីព្រោះមូលធនត្រូវបានរដ្ឋាភិបាលជាអ្នកធានា ហើយវិនិយោគិនភាគច្រើនត្រូវបានរួចពន្ធលើប្រាក់ចំណូល។ សញ្ញាប័ណ្ណរដ្ឋ អាចបោះផ្សាយតាមរយៈពេលនៃប្រភេទសញ្ញាប័ណ្ណដូចខាងក្រោម៖

- Treasury/ Government Bill ( T-bill) ៖ មានរយៈពេលស្មើ ឬតិចជាង៥២សប្តាហ៍
- Treasury/ Government Note (T-notes) ៖ មានរយៈពេលស្មើ ឬតិចជាង១០ឆ្នាំ
- Treasury/ Government Bond (T-bond) ៖ មានរយៈពេលស្មើ ឬតិចជាង៣០ឆ្នាំ
- Treasury Inflation-Protected Securities(TIPS)៖ជាមូលធនការពារអតិផរណារតនាគារ គឺជាសញ្ញាសម្គាល់សន្ធស្សន៍អតិផរណាដែលចេញដោយរតនាគារសហរដ្ឋអាមេរិក។[៤]

❖ **សញ្ញាបណ្ណសាជីវកម្ម**

សញ្ញាបណ្ណសាជីវកម្ម គឺជាប្រភេទមូលបត្របំណុល ដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្ម ក្នុងគោលដៅប្រមូលមូលធនបណ្តោះអាសន្នបន្ថែមលើមូលធនដែលមានស្រាប់ សម្រាប់យកមកធ្វើការពង្រីកអាជីវកម្មបន្ថែមទៀត។ សញ្ញាបណ្ណសាជីវកម្មអាចបោះផ្សាយលក់ជាសាធារណៈក្នុងជាទម្រង់៖ មូលបត្រដាក់បញ្ចាំ( Mortgage Bond ) សញ្ញាប័ណ្ណដែលអាចប្តូរបាន( Convertible Bond ) សញ្ញាប័ណ្ណដែលមានខណ្ឌប័ណ្ណសូន្យ ( Zero Coupon Bond ) មូលបត្រពាណិជ្ជកម្ម(Commercial Paper)...ជាដើម។

[៤]https://en.m.wikipedia.org/wiki/United_States_Treasury_security បានចូលទស្សនា ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១

ជាទូទៅការវិនិយោគលើសញ្ញាប័ណ្ណទទួលបានការចាប់អារម្មណ៍ខ្លាំងដោយសារវាផ្តល់នូវអត្ថប្រយោជន៍ជាច្រើនទាំង ក្រុមហ៊ុន វិនិយោគិនសាធារណៈ និងរដ្ឋ ដូចជា៖

- **ចំពោះក្រុមហ៊ុនៈ** ក្រៅពីការបោះផ្សាយភាគហ៊ុន ដើម្បីប្រមូលមូលធនបន្ថែម ក្រុមហ៊ុននៅអាចបោះផ្សាយសញ្ញាប័ណ្ណដែលអាចធ្វើ ហិរញ្ញបទានរយៈពេលវែងបានដូចគ្នា ប៉ុន្តែសញ្ញាប័ណ្ណមិនបានធ្វើឲ្យប៉ះពាល់ដល់សិទ្ធ និងភាពជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុននោះទេ។ ម៉្យាងវិញទៀតក្រុមហ៊ុន ចំណាយការប្រាក់លើសញ្ញាបណ្ណនេះមានកម្រិតទាប ដែលវាផ្តល់ភាពងាយស្រួល និងផលចំណេញច្រើនដល់ក្រុមហ៊ុនក្នុងការប្រមូលមូលធនបន្ថែម ។
- **ចំពោះវិនិយោគិនសាធារណៈ** ៖ ការវិនិយោគលើសញ្ញាប័ណ្ណ មានកម្រិតហានិភ័យទាប ជាពិសេសលើការវិនិយោគលើបណ្ណរតនាគារជាតិ (ជាសញ្ញាបណ្ណគ្មានហានិភ័យ)។ ជាទូទៅសញ្ញាប័ណ្ណ មានតម្លៃថោកទាប ដែលធ្វើឲ្យមានភាពងាយស្រួលដល់វិនិយោគិនក្នុងការវិនិយោគនិងទទួលបានការប្រាក់ថេរពីសញ្ញាបណ្ណទាំងនោះ។
- **ចំពោះរដ្ឋ** ៖ សញ្ញាប័ណ្ណបានផ្តល់ឲ្យរដ្ឋនូវហិរញ្ញប្បទានរយៈពេលវែងមួយ ក្នុងការវិនិយោគគម្រោងធំៗ (ការសាងសង់សាលារៀន ហេដ្ឋារចនាសម្ព័ន្ធ ផ្សេងៗជាដើម)ដែលផ្តល់ជាប្រយោជន៍ដល់សាធារណៈជនទូទៅ ដោយរដ្ឋធ្វើការចំណាយការប្រាក់ទាប ជាជាងកម្ចីពីធនាគារឬកម្ចីពីបរទេស ។

**១.២.២.៣. ឧបករណ៍និស្សន្ទ** (ឧបករណ៍ដេរីវេទីវ)

ជាឧបករណ៍និទស្សន៍(ឧបករណ៍ដេរីវេទីវ) គឺជាឧបករណ៍ហិរញ្ញវត្ថុ ជាប្រភេទមួយនៃមូលបត្រ ដែលសំដៅដល់កិច្ចសន្យាគម្លាតតម្លៃ នៃឧបករណ៍ហិរញ្ញវត្ថុដើម ដែលមានប្រភពចេញពី មូលបត្រកម្មសិទ្ធ មូលបត្របំណុល សន្ទស្សន៍ទីផ្សារលោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ រួមទាំងរូបិយប័ណ្ណជាដើម ហើយត្រូវបានជួញដូរក្នុងទីផ្សារឧបករណ៍និទស្សន៍។

## ១.៣. ទីផ្សារមូលបត្រ

### ១.២.១. និយមន័យទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ត្រូវគេទទួលស្គាល់ថា គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀត។ តាមនិយមន័យ ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន “សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ ផ្ទេរ ឬស្នើការទិញ-លក់មូលបត្រ”។ ឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរលើទីផ្សារនេះ រួមមានមូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទ ជាដើម។[៥]

[៥] www.secc.gov.kh/khmer/m75.php?pn=2 បានចូលទស្សនា ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១

### ១.៣.២. ប្រភេទនៃទីផ្សារមូលបត្រ

ជាទូទៅទីផ្សារមូលបត្រ ត្រូវបានគេចែងចែកជាច្រើនប្រភេទផ្សេងៗដាច់ដោយឡែកពីគ្នា។ ដោយហេតុថាមូលបត្រមានច្រើនប្រភេទ គេអាចធ្វើចំណាត់ថ្នាក់ទីផ្សារមូលបត្របានជាច្រើនប្រភេទ ដោយយោងទៅតាមឥណប្រតិទាន( ទីផ្សារមូលធនសម្រាប់មូលបត្ររយៈពេលវែង និងទីផ្សាររូបិយវត្ថុសម្រាប់មូលបត្ររយៈពេលខ្លី) យោងតាមប្រភេទនៃមូលបត្រ (ទីផ្សារមូលបត្រកម្មសិទ្ធិ ទីផ្សារមូលបត្របំណុល និងទីផ្សារឧបករណ៍ដេរីវេទីវ) យោងតាមចរិតលក្ខណៈគតិយុត្តនៃទីផ្សារ (ទីផ្សារប្រតិស្រុត និងទីផ្សាររំលងបញ្ជា) និងយោងតាមដំណាក់កាលនៃការដាក់លក់មូលបត្រនៅលើទីផ្សារ គេអាចចែកទីផ្សារមូលបត្របានជាពីរទីផ្សារធំៗទៀតគឺ ទីផ្សារដំបូង និងទីផ្សារបន្ទាប់។

#### ១.៣.២.១. ទីផ្សារដំបូង

ការដាក់លក់មូលបត្រជាលើកដំបូង ដោយក្រុមហ៊ុនបោះផ្សាយទៅឲ្យវិនិយោគិន ត្រូវបានហៅថា ជាការលក់ជាលើកដំបូង នៅលើទីផ្សារដំបូង។ នៅក្នុងន័យនេះ វិនិយោគិនដែលជាអ្នកទិញ នឹងត្រូវធ្វើការទិញមូលបត្រផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ ដែលក្រុមហ៊ុនបោះផ្សាយដើរតួនាទីជាអ្នកលក់។ តាមរយៈសៀវភៅ មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ របស់លោក បៀន សាំង(២០១១) បានបញ្ជាក់ថា៖ ទីផ្សារដំបូងគឺជាកន្លែងដែលមូលបត្រត្រូវបានលក់ជាលើកទីមួយឲ្យទៅសាធារណៈជន ហើយអ្នកទិញបានទិញនូវមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលអាចជា ក្រុមហ៊ុនសារជីវកម្ម ឬអង្គភាពរដ្ឋាភិបាលមួយ ដែលបានបោះផ្សាយលក់មូលបត្រ។ ដើម្បីទិញ មូលបត្រពីទីផ្សារដំបូង វិនិយោគិនត្រូវធ្វើការបញ្ជាទិញមូលបត្រ ដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយ នៅក្នុងដំណាក់កាល Book Building ឬក៏ក្នុងដំណាក់កាល Subscription។ សាច់ប្រាក់សម្រាប់ទូទាត់មូលបត្រ ត្រូវបង់ទៅឲ្យក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនេះក្លាយជាអ្នកកាន់កាប់ភាគហ៊ុនដំបូងគេ។ ភាគហ៊ុននិកដំបូងគេ អាចកាន់កាប់ភាគហ៊ុនទាំងនេះ ឬអាចលក់ភាគហ៊ុនទាំងអស់ឲ្យទៅអ្នកដ៏ទៃបន្តទៀតបាននៅលើទីផ្សារបន្ទាប់។

ដំណើរការនៃការលក់ភាគហ៊ុន ទៅឲ្យសាធារណៈជន ជាលើកដំបូងត្រូវគេស្គាល់ថាជា ការនាំក្រុមហ៊ុនទៅកាន់សាធារណៈ មានន័យថា ក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគគិនដំបូង ឬស្ថាបនិកទៀតហើយ។ ក្រុមហ៊ុនដែលបានលក់ភាគហ៊ុនរបស់ខ្លួន ទៅកាន់សធារណៈជនត្រូវបានគេសន្មត់ថាជា សំណើលក់មូលបត្រជាសាធារណៈ កើតមានឡើង។ ចំពោះដំណើរការនៃការបោះផ្សាយលក់ភាគហ៊ុន ទៅកាន់សាធារណៈជន ជាលើកដំបូង របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ត្រូវបានគេហៅថាជាសំណើរបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង "IPO"។[៦]

[៦] មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ របស់លោក បៀន សាំង(២០១១)

### ១.៣.២.២. ទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់( Secondary Market )គឺជាទីផ្សារ ដែលធ្វើការជួញដូរមូលបត្រទាំងឡាយណា ដែលធ្លាប់បានធ្វើការជួញដូរម្តងរួចមកហើយ នៅក្នុងទីផ្សារដំបូង មានន័យថាវិនិយោគិនដែលបានទិញមូលបត្ររួចហើយ អាចធ្វើការលក់មូលបត្រនោះវិញបាននៅលើទីផ្សារបន្ទាប់។នេះមានន័យថា ភាពជាម្ចាស់កម្មសិទ្ធលើមូលបត្រ អាចផ្លាស់ប្តូរដោយសេរី ពីអ្នកលក់ម្នាក់ទៅអ្នកទិញម្នាក់ទៀត (ពីវិនិយោគិនទៅវិនិយោគិន)ដោយតំលៃកំណត់មួយ ដែលមានការព្រមព្រៀង និងពេញចិត្តដោយភាគីទាំងពីរ(ភាគីអ្នកលក់ និងអ្នកទិញ) តាមរយៈការផ្តល់ភាពជាម្ចាស់កម្មសិទ្ធលើមូលបត្រទៅឲ្យអ្នកទិញ។ ការកំណត់តម្លៃនិងការផ្តល់កម្មសិទ្ធលើមូលបត្រ កើតឡើងនៅកន្លែងណាមួយ ដែលគេស្គាល់ថាទីផ្សារបន្ទាប់ (Secondary Market)។

ទីផ្សារបន្ទាប់ ជាកន្លែងដែលការជួញដូរ មូលបត្រត្រូវបានកើតឡើងជាប្រចាំ រវាងអ្នកលក់ និងអ្នកទិញមូលបត្រ (វិនិយោគិន និង វិនិយោគិន)។ ទឹកប្រាក់ដែលកើតចេញពីសកម្មភាពជួញដូរ នេះ ត្រូវបង់ឲ្យទៅភាគហ៊ុននិកដែលបានលក់ មិនមែនបង់ឲ្យទៅក្រុមហ៊ុនបោះផ្សាយដំបូងនោះទេ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រមិនទទួលបានផលចំណេញជាហិរញ្ញវត្ថុពីការជួញដូរមូលបត្រ ដែលបានកើតឡើងនៅទីផ្សារបន្ទាប់នោះទេ ហើយមូលបត្រទាំងអស់ដែលជួញដូរ នៅលើទីផ្សាបន្ទាប់ អាចត្រូវបានជួញដូរនៅក្នុងទីផ្សារមូលបត្រ( Organized Exchange ) ឬនៅក្រោមផ្សារមូលបត្រ ដែលគេហៅថា ទីផ្សាររំលងបញ្ជារ ( Over The Counter ) ។ យើងអាចនិយាយបានថា ទីផ្សារបន្ទាប់នេះជាទីផ្សារមួយដែលមានមុខងារនៃទីផ្សារមូលបត្រ និងជាទីផ្សាររំលងបញ្ជារ ( Over The Counter ) ក្នុងការផ្តល់ទីកន្លែងមួយក្នុងការកំណត់តម្លៃភាគហ៊ុន ព្រមទាំងការផ្តល់មូលបត្រទៅឲ្យអ្នកទិញ។ នាពេលបច្ចុប្បន្ននេះ ទីផ្សារបន្ទាប់ត្រូវបានគេបែងចេកជាពីរធំៗដាច់ពីគ្នានោះគឺ៖

- ទីផ្សារមូលបត្រ ( Organized Exchange ) ៖ សំដៅលើការជួញដូរមូលបត្រតាមរយៈទីផ្សារមូលបត្រដែលមានទីកន្លែងសម្រាប់ជួញដូរមូលបត្រជាក់លាក់មួយ មានវិធានការទីផ្សារ និងមានប្រព័ន្ធជួញដូរមួយច្បាស់លាស់ក្នុងការជួញដូរ ដើម្បីគ្រប់គ្រងដំណើរការជួញដូរ ឲ្យប្រកបទៅយ៉ាងរលូន ហើយនឹងមានសណ្តាប់ធ្នាប់ត្រឹមត្រូវ។
- ទីផ្សារមូលបត្រក្រៅប្រព័ន្ធ ( Over-The-Counter – OCT ) ៖ សំដៅលើការជួញដូរមូលបត្រ ក្រៅប្រព័ន្ធទីផ្សារមូលបត្រ ដែលពុំមានទីកន្លែងសម្រាប់ជួញដូរជាក់លាក់ និងមិនត្រូវបានចាត់ទុកជាប្រព័ន្ធផ្លូវការសម្រាប់ជួញដូរមូលបត្រនោះទេ។ នៅក្នុងទីផ្សារនេះ វិនិយោគិនអាចជួញដូរមូលបត្របានតាមរយៈ ការចរចារតាមរយៈទូរសព្ទ័ អ៊ីម៉ែល និងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនណាមួយ។ ភាគច្រើននៃទីផ្សារនេះ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ជាអ្នកដាក់នូវការកំណត់ថ្លៃទិញលក់ មូលបត្រជូនអតិថិជន និងក្រុមហ៊ុនពាណិជ្ជករមូលបត្រដ៏ទៃផ្សេងទៀត។

## ១.៤. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ

### ១.៤.១ក្រុមហ៊ុនបោះផ្សាយ ( Issuer )

ក្រុមហ៊ុនបោះផ្សាយគឺជាអង្គភាពមួយដែលបានធ្វើ ការបោះផ្សាយមូលបត្រនៃក្រុមហ៊ុនរបស់ខ្លួន ហើយដាក់លក់ឲ្យវិនិយោគិនសាធារណៈ ដើម្បីស្វែងរកដើមទុនបន្ថែមដល់ក្រុមហ៊ុន។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាតួអង្គដ៏សំខាន់មួយនៅក្នុងទីផ្សារមូលបត្រ ពីព្រោះបើគ្មានវត្តមានរបស់ក្រុមហ៊ុនបោះផ្សាយនោះទេ ក៏គ្មានមូលបត្រសម្រាប់លក់នៅលើទីផ្សារដែរ។ ជាទូទៅក្រុមហ៊ុនដែលអាចបោះផ្សាយមូលបត្រជាសាធារណៈបាន លុះត្រាតែជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬជានីតិបុគ្គលប្រតិស្រុត ដែលបានបំពេញត្រឹមត្រូវគ្រប់ទៅតាមលក្ខខណ្ឌតម្រូវផ្សេងៗ ស្របទៅតាមច្បាប់ និងបទបញ្ញត្តិនានា ដែលបានរៀបចំនិងអនុម័តដោយអាជ្ញាធរមូលបត្រនៃប្រទេសនិមួយៗ។

### ១.៤.២. អន្តរការីទីផ្សារមូលបត្រ ( Intermediary )

អន្តរការីសំដៅដល់អង្គភាព ឬបុគ្គលដែលជាជំនួយការនៅក្នុងដំណើរការទាំងអស់ដែលពាក់ព័ន្ធនឹងមូលបត្រ។ អន្តរការីមានតួនាទី ជួយសម្របសម្រួលផ្តល់ប្រឹក្សាជូនដល់ក្រុមហ៊ុនដែលមាន បំណងចង់បោះផ្សាយលក់មូលបត្រ ព្រមទាំងធានាឲ្យបាននូវការបោះផ្សាយលក់មូលបត្រ ដែលប្រកបដោយប្រសិទ្ធភាព និងទទួលបាននូវភាពជោគជ័យ។ ជាពិសេសអន្តរការី ធ្វើការទំនាក់ទំនង ផ្តល់ប្រឹក្សារ ក៏ដូចជាផ្តល់មធ្យោបាយជួញដូរដល់វិនិយោគិនផងដែរ។ បើគ្មានអន្តរការីនោះទេ នោះពុំមានស្ពានតភ្ជាប់ រវាងក្រុមហ៊ុនបោះផ្សាយទៅនិយ័តករ និងតភ្ជាប់ទៅកាន់ទីផ្សារមូលបត្រនោះឡើយ។

ជាទូទៅអន្តរការីទីផ្សារមូលបត្រ មានដូចជា ធនាគារពាណិជ្ជ ធនាគារវិនិយោគ ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនជើងសារមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ។

### ១.៤.៣. វិនិយោគិន ( Investor )

វិនិយោគិនមូលបត្រគឺ ជាអ្នកដែលទិញ ឬលក់មូលបត្រ ពីទីផ្សារមូលបត្រក្នុងគោលបំណងដើម្បីស្វែងរកនូវប្រាក់ចំណេញពីការវិនិយោគលើមូលបត្រ។ វិនិយោគិនមូលបត្រ អាចជាសាធារណៈជនទូទៅ ឬក៏អាចជាស្ថាប័ននានា ដែលវិនិយោគិនទាំងនេះជាអ្នកដើរតួយ៉ាងសំខាន់នៅក្នុងវិស័យមូលបត្រ ព្រោះវិនិយោគិនជាអ្នកធ្វើឲ្យមាននូវ ចរន្តជួញដូរ នៅលើទីផ្សារមូលបត្រកើតមានឡើង(មានតែអ្នកលក់តែគ្មានអ្នកទិញ) ។ វិនិយោគិនទាំងអស់ អាចធ្វើការទិញមូលបត្រ ពីក្រុមហ៊ុនបោះផ្សាយមូលបត្រ នៅលើទីផ្សារដំបូងបាន ដោយអាចធ្វើការបញ្ជាទិញតាមរយៈការធ្វើ ប៊ុកបៀលឌីង( Book Building) ឬក៏ ដំណាក់កាល បរិវិសកម្ម( Subscription ) ហើយអ្នកវិនិយោគិនក៏អាចទិញ ឬយកមូលបត្រដែលទិញបានពីទីផ្សារដំបូង យកទៅជួញដូរ បន្តឲ្យទៅវិនិយោគិនផ្សេងទៀត បាននៅលើទីផ្សារទីពីរ។

## ១.៥. តួនាទីទីផ្សារមូលបត្រនៅក្នុងសេដ្ឋកិច្ច

ទីផ្សារមូលបត្រ គឺជាកត្តាមូលដ្ឋានមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ច រហូតគេនិយាយថា ទីផ្សារមូលបត្រគឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់បម្រែបម្រួលនៃបរិបទជាតិនិង អន្តរជាតិ (សេដ្ឋកិច្ច-សង្គមនិងនយោបាយ) វានឹងធ្វើឲ្យមានផលប៉ះពាល់ទៅដល់ទីផ្សារមូលបត្រភ្លាម ដោយគ្រាន់តែមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ចយ៉ាងណា ព្រោះសន្ទស្សន៍ហ៊ុនរបស់ផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។

ហេតុនេះ គ្រប់បណ្តាប្រទេសអភិវឌ្ឍទាំងអស់ ទីផ្សារមូលបត្រ បានដើរតួនាទីយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាតិ៖

- ទីផ្សារមូលបត្រ ជួយជំរុញឲ្យមហាជនបង្កើននូវទំលាប់ក្នុងការសន្សំ និងកៀងគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច។
- ទីផ្សារមូលបត្រ គឺជាមធ្យោបាយមួយក្នុងប្រមែប្រមូលកៀងគរ នូវប្រភពមូលធនដែលនៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ ពូនផ្តុំជាមូលធនធំមួយដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ទីផ្សារមូលបត្រ ជួយសម្រួលដល់រដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវកម្មវិធី អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម។
- ទីផ្សារមូលបត្រគឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបយកនូវមូលធនពីបរទេស។
- ទីផ្សារមូលបត្រជាកម្លាំងចលករជួយជំរុញឲ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយមានប្រសិទ្ធភាព និងមានតម្លាភាព។
- ទីផ្សារមូលបត្រជួយជំរុញឲ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក ។
- ទីផ្សារមូលបត្រជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។

## ១.៦. សារៈសំខាន់នៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រគឺជា សរសៃឈាមយ៉ាងសំខាន់សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិទាំងមូលដែល ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងវិនិយោគិនជាអ្នកដើរតួនាទីស្នូល។ គ្រប់បណ្តាលប្រទេសទាំងអស់នៅលើសកលលោកតែងតែផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង ក្នុងការបង្កើតនិងអភិវឌ្ឍន៍ទីផ្សារនេះ ដើម្បីធានាបាននូវការអភិវឌ្ឍន៍ ប្រពន្ធ័ហិរញ្ញវត្ថុប្រកបដោយភាពរឹងមាំ និងចីរភាពក្នុងទិសដៅរក្សាឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ វិស័យនេះបានធ្វើឲ្យ មាននូវជំនួបរវាងអ្នកដែលមានមូលធនដែលនៅទំនេរ និងអ្នកដែលមានតម្រូវការមូលធនដែលអាចឲ្យអ្នកដែលមានមូលធននៅទំនេរអាចមានឱកាសទាញយកផលចំណេញពីមូលធន ដែលនៅទំនេរជាមួយនឹងកម្រិតហានិភ័យទាបហើយអ្នកដែលមានតម្រូវការមូលធន អាចទទួលបានមូលធនយកទៅប្រើប្រាស់ជាមួយនឹងកម្រិតការប្រាក់ទាបជាងទីផ្សារ។លំនាំទាំងអស់នេះបានធ្វើឲ្យ ការប្រមូលផ្តុំមូលធនដែលនៅ

ទំនេរតូចៗ និងបែងចែកមូលធនកាន់តែមានប្រសិទ្ធ និងកាន់តែសម្បូរបែប សម្រាប់គម្រោងវិនិយោគនានា ដែលជាចលករនៃកំណើនសេដ្ឋកិច្ចជាតិ។

### ១.៦.១. សារៈសំខាន់នៃទីផ្សារមូលបត្រសម្រាប់វិនិយោគិន

វិនិយោគិនជាអ្នកជួញដូរ ឬវិនិយោគលើវិស័យមូលបត្រ។ វិស័យមូលបត្រ ជាវិស័យមួយដែលទទួលបានការចាប់អារម្មណ៍ និងមានភាពពេញនិយមយ៉ាងខ្លាំង សម្រាប់វិនិយោគិននៅលើសកលលោក។ ហេតុផលដែលវិស័យមូលបត្រ អាចទទួលបាននូវភាពពេញនិយមខ្លាំងនៅក្នុងការវិនិយោគ ដោយសារតែ វិនិយោគិនអាចទទួលបានអត្ថប្រយោជន៍ផ្សេងៗ ជាច្រើនពីការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រដូចជា៖

- ការធ្វើពិពិធកម្ម( Diversification )៖ វិនិយោគិនអាចធ្វើការវិនិយោគ និងជួញដូរបានទៅលើឧបករណ៍ហិរញ្ញវត្ថុផ្សេងៗជាច្រើនដូចជា មូលបត្រកម្មសិទ្ធ(ភាគហ៊ុន) មូលបត្របំណុល(សញ្ញាប័ណ្ណសាជីវកម្ម ប័ណ្ណរតនាគារជាតិ) គម្រោងវិនិយោគរួម កិច្ចសន្យាគម្លាតថ្លៃរូបិយប័ណ្ណ លោហធាតុមានតម្លៃ ប្រេងឆៅ និងកិច្ចសន្យាគម្លាតថ្លៃខុម៉ូឌីធី(ផលិតផលកសិកម្ម) និងសន្ទស្សន៍ទីផ្សារជាដើម។
- ផលត្រឡប់មកវិញ( Return )៖ វិនិយោគិនមូលបត្រអាចទទួលបានផលតបស្នងមកវិញនូវ ប្រាក់ចំណេញមូលធន( Capital gain ) ភាគលាភ( Dividend ) ការប្រាក់( Interest ) ទៅតាមប្រភេទឧបករណ៍ហិរញ្ញវត្ថុដែលពួកគេបានវិនិយោគ។
- សន្ទនីយភាពខ្ពស់( High Liquidity )៖ សន្ទនីយភាពខ្ពស់សំដៅដល់ភាពងាយស្រួល ក្នុងការបំលែងទៅជាសាច់ប្រាក់ត្រឡប់មកវិញ។ វិនិយោគិននៅក្នុងទីផ្សារមូលបត្រ ដែលបានទិញភាគហ៊ុន ឬសញ្ញាប័ណ្ណ អាចធ្វើការលក់មូលបត្ររបស់ខ្លួនវិញ បានគ្រប់ពេលនៅក្នុងទីផ្សារបន្ទាប់( Secondary Market ) ដើម្បីទទួលបានជាសាច់ប្រាក់ត្រឡប់មកវិញគ្រប់ពេលដែលវិនិយោគិនត្រូវការ។
- ទទួលបានពត៌មានប្រកបដោយសមធម៌៖ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈទាំងអស់ត្រូវផ្តល់ និងបង្ហាញពត៌មានត្រឹមត្រូវទាន់ពេលដល់សាធារណៈជន ក៏ដូចជាវិនិយោគិនទូទៅនូវរបាយការណ៍ផ្សេងៗដូចជា ពត៌មានអំពីសកម្មភាពអាជីវកម្មផ្សេងៗ អភិបាលកិច្ចសាជីវកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនទៅតាមពេលវេលាកំណត់ ដែលត្រូវមានត្រួតពិនិត្យនិងទទួលស្គាល់ជាផ្លូវការដោយគណៈកម្មការមូលបត្រតាមបណ្តាប្រទេសនិមួយៗ ដែលជាពត៌មានដែលសាធារណៈជននិងវិនិយោគិនអាចជឿទុកចិត្តបាន។
- ឱកាសក្នុងការវិនិយោគជាមួយនិងហានិភ័យទាប៖ ការវិនិយោគនៅក្នុងវិស័យមូលបត្រជាការវិនិយោគមួយដែលមានហានិភ័យទាបបំផុតសម្រាប់វិនិយោគិន។

### ១.៦.២. សារៈសំខាន់នៃទីផ្សារមូលបត្រសម្រាប់ក្រុមហ៊ុនបោះផ្សាយ

- ការពង្រីកប្រតិបត្តិការអាជីវកម្ម៖ តាមរយៈទីផ្សារមូលបត្រ ក្រុមហ៊ុនបោះផ្សាយនឹងមានលទ្ធភាពបង្កើនដើមទុនរបស់ខ្លួន។ ការចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាមធ្យោបាយដ៏ល្អមួយសម្រាប់ក្រុមហ៊ុនអាជីវកម្មណាដែលមានតម្រូវការមូលធន (ទទួលបាននូវដើមទុនតាមតម្រូវការ និងមានរយៈពេលវែង)ក្នុងការពង្រីកអាជីវកម្ម។
- ទទួលបានកេរ្តិ៍ឈ្មោះ៖ ក្រុមហ៊ុនបោះផ្សាយនឹងត្រូវបានសាធារណៈជនទូទៅទទួលស្គាល់បានយ៉ាងទូលំទូលាយ តាមរយៈការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (IPO) ពីព្រោះនិយ័តករមូលបត្រ ផ្តល់ការអនុញ្ញាតឲ្យចុះបញ្ជីចំពោះតែក្រុមហ៊ុនណាដែលមានរឹងមាំផ្នែកហិរញ្ញវត្ថុ និងមានគុណវុឌ្ឍិគ្រប់គ្រាន់តែប៉ុណ្ណោះ ដែលនេះជាហេតុធ្វើឲ្យ សាធារណៈជនទទួលស្គាល់នូវកេរ្តិ៍ឈ្មោះកិត្យានុភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងបានល្អប្រសើររបស់ក្រុមហ៊ុន។
- ការទាក់ទាញបុគ្គលិកដែលមានសមត្ថភាពខ្ពស់៖ ក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនដែលមានភាពខ្លាំង និងរឹងមាំ ព្រមទាំងមានការទទួលស្គាល់ពីសារធារណៈជនទូទៅតាមរយៈការធ្វើ IPO ដែលមានភាពទាក់ទាញដល់នាយកប្រតិបត្តិឆ្នើមៗ និងបុគ្គលិកដែលមានសមត្ថភាពខ្ពស់ឲ្យចូលរួមជាមួយក្រុមហ៊ុនបានច្រើន។

### ១.៦.៣. សារៈសំខាន់នៃទីផ្សារមូលបត្រសម្រាប់សេដ្ឋកិច្ចជាតិ

- កំណើនសេដ្ឋកិច្ចជាតិ៖ ក្រុមហ៊ុនបោះផ្សាយអាចជំរុញការវិនិយោគបន្ថែមរបស់ខ្លួនបានតាមរយៈការបង្កើនទុនពីទីផ្សារមូលបត្រ សម្រាប់អនុវត្តគម្រោងវិនិយោគដែលមានផលិតកម្មខ្ពស់ដែលអាចឈានទៅដល់ការបង្កើនមូលធន និងជំរុញឲ្យមាននូវកំណើនសេដ្ឋកិច្ច។
- ការប្រមូលផ្តុំទុន៖ ទីផ្សារមូលបត្រជាមធ្យោបាយមួយយ៉ាងមានប្រសិទ្ធភាព ក្នុងការប្រមូលផ្តុំដើមទុនតូចៗដែលនៅទំនេរយកមកប្រើប្រាស់បាន។ ដូច្នេះអ្នកដែលមានដើមទុននៅទំនេរតិច ត្រូវបានកៀងគរប្រមូលផ្តុំគ្នា ដោយការវិនិយោគលើទីផ្សារមូលបត្រ ដើម្បីយកមូលធនទាំងនោះទៅប្រើប្រាស់នៅក្នុងសេដ្ឋកិច្ច ដែលលំនាំនេះបានធ្វើឲ្យចរន្តសាច់ប្រាក់មានភាពរស់រវើកជាជាងការទុក សាច់ប្រាក់នៅមួយកន្លែង ឬការវិនិយោគជាមួយទ្រព្យដែលគ្មានផលិតកម្ម ដូចជាមាស ពេជ្រជាដើម។
- បង្កើនការងារ៖ ទន្ទឹមនឹងក្រុមហ៊ុនបោះផ្សាយ ទទួលបានទុនបន្ថែមសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួនតម្រូវការបុគ្គលិកសម្រាប់បំពេញការងារបន្ថែមគឺពិតជាមិនអាចខ្វះបាន ដែលជាផ្នែកមួយជម្រុញឲ្យមានកំណើនឱកាសការងារក្នុងស្រុកកើនឡើង ។[៧]

---

[៧] https://m.postkhmer.com បានចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១

# ជំពូកទី២

# ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា

# ជំពូកទី២

# ស្ថានភាពទូទៅនៃនិយ័តករមូលបត្រកម្ពុជា

## ២.១. ប្រវត្តិនៃការបង្កើតនិយ័តករមូលបត្រកម្ពុជា




រូបភាពទី១. អាគាររបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងដំបូងដោយមានឈ្មោះពេញជាអក្សរខ្មែរថា គណៈកម្មការមូលបត្រកម្ពុជា ដែលហៅកាត់ថា **គ.ម.ក.** និងអក្សរកាត់ជាភាសាអង់គ្លេសថា **SECC** ក្រោមបញ្ញាតិនៃច្បាប់ស្តីពី "ការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន" ដែលត្រូវបានដាក់សម្ភោធឲ្យប្រើប្រាស់ជាផ្លូវការ កាលពីថ្ងៃទី ២៩ ខែមេសា ឆ្នាំ២០០៩។ ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណកម្មកាមូលបត្រកម្ពុជា ត្រូវបានធ្វើឡើងដោយអនុលោមតាមអនុក្រឹតស្តីពី "ការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈកម្មការមូលបត្រកម្ពុជា" ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។

គណៈកម្មការមូលបត្រកម្ពុជា នៅថ្ងៃទី២ ខែមិនា ឆ្នាំ២០២១ នេះបានចេញសេចក្តីជូនដំណឹងស្តីពីការផ្លាស់ប្តូរឈ្មោះអង្គភាពរបស់ខ្លួនពី"**គណកម្មការមូលបត្រកម្ពុជា**"ទៅជា "**និយ័តករមូលបត្រកម្ពុជា**"វិញ ដោយមានអក្សរកាត់ថា **ន.ម.ក**។សេចក្តីជូនដំណឹងបញ្ជាក់ថា គណៈកម្មការមូលបត្រកម្ពុជា(គ.ម.ក) ត្រូវបានប្រែក្លាយជានិយ័តករមូលបត្រកម្ពុជា អនុលោមតាមច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលត្រូវបានប្រកាសឲ្យប្រើ ដោយព្រះរាជក្រម លេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១។ដូច្នេះឈ្មោះរបស់"**គណកម្មការមូលបត្រកម្ពុជា**"ទៅជា "**និយ័តករមូលបត្រកម្ពុជា**" ហើយនិយ័តករមូលបត្រកម្ពុជា នៅតែបន្តការប្រើប្រាស់នូវនិមិត្តសញ្ញា និងត្រារបស់គណៈកម្មការមូលបត្រកម្ពុជា រហូតដល់មានការជូនដំណឹងជាថ្មី។

យោងទៅតាមអនុក្រឹតលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ កក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឳវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានធ្វើការផ្លាស់ប្តូរនិមិត្តសញ្ញារបស់និយ័តករកម្ពុជា ដោយបានកែសម្រួលផ្នែកព័ទ្ធជារង្វង់នៅផ្នែកខាងលើជាអក្សរខ្មែរថា "និយ័តករមូលបត្រកម្ពុជា" និងបានកែផ្នែកព័ទ្ធជារង្វង់នៅផ្នែកខាងក្រោមជាភាសារអង់គ្លេសថា "SECURITIES AND EXCHANG REGULATOR OF CAMBODIA"។

## ២.២. ចក្ខុវិស័យ និងបេសកកម្ម

### ២.២.១. ចក្ខុវិស័យ

និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្រោយពីច្បាប់មូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជនបានអនុម័តរួច។ និយ័តករមូលបត្រកម្ពុជា មានគោលដៅគ្រប់គ្រងវិស័យមូលបត្រក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងចូលរួមចំណែក ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិនិងសង្គមតាមរយៈការកៀរគរមូលធនពីសាធារណៈជនទូទៅ ឬអ្នកវិនិយោគមូលបត្រ ដើម្បីឆ្លើយតបទៅនឹងតម្រូវការហិរញ្ញវត្ថុនៅកម្ពុជា។

### ២.២.២. បេសកកម្ម

- បង្កើត និងរក្សាឲ្យមានទំនុកចិត្ត ពីអ្នកវិនិយោគទុន នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈ ការការពារសិទ្ធស្របច្បាប់របស់អ្នកវិនិយោគ និងធានាឲ្យមានការបោះផ្សាយ និងការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវ។
- លើកកម្ពស់ការគ្រប់គ្រងទីផ្សារមូលបត្រឲ្យមានប្រសិទ្ធភាព និងជំរុញលើការអភិវឌ្ឍទីផ្សារនេះឲ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ។
- ជំរុញឲ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជំរុញផ្សមានការធ្វើវិនិយោគទុនពីបរទេស និងការចូលរួមនៅក្នុងទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ២.៣. ទីតាំងរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា មានទីតាំងនៅ អគារលេខ១១៦៨ ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ ភ្នំពេញ រាជធានីភ្នំពេញ។

- លេខទូរសព្ទ: (៨៥៥) ២៣ ៨៨ ៥៦ ១១/ (៨៥៥) ១៦ ៨១ ៩៩ ៩១
- លេខទូរសារ: (៨៥៥) ២៣ ៨៨ ៥៦ ២២
- អ៊ីម៉ែល: INFO@SECC.GOV.KH
- គេហៈទំព័រ: www.secc.gov.kh

## ២.៤. រូបសញ្ញា និងអត្ថន័យ

### ២.៤.១. រូបសញ្ញា

និយ័តករមូលបត្រកម្ពុជាមានរូបសញ្ញាដូចខាងក្រោម៖

- រូបហង្សពណ៌មាស នៅចំកណ្ដាល
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេង មានការរំលេចស្រមោលពណ៌មាស ហើយខាងស្ដាំរំលេចស្រមោលពណ៌ប្រផេះ
- រូបរង្វង់ថាស ដែលពាក់កណ្ដាលមានពណ៌មាស និងពាក់កណ្ដាលទៀតមានពណ៌ប្រផេះ
- មានអក្សរពណ៌ទឹកប៊ិច ព័ទ្ធជុំវិញជារង្វង់ ដែលនៅផ្នែកខាងលើមានអក្សរខ្មែរថា “និយ័តករមូលបត្រកម្ពុជា” និងពាក់កណ្ដាលនៃរង្វង់នៅផ្នែកខាងក្រោមជាអក្សរអង់គ្លេសថា “SECURITIES AND EXCHANG REGULATOR OF CAMBODIA”។

រូបភាព២. រូបសញ្ញារបស់និយ័យករមូលបត្រកម្ពុជា

### ២.៤.២. អត្ថន័យនៃរូបសញ្ញា

- **រូបហង្សពណ៌មាស** តំណាងឲ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យនិងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឲ្យដំណើរការនៃទីផ្សារប្រកបដោយ ប្រសិទ្ធភាព មានសណ្ដាប់ធ្នាប់ និងមានតម្លាភាព។
- **រូបរង្វង់ថាស ដែលពាក់កណ្ដាលមានពណ៌មាស និងពាក់កណ្ដាលទៀតមានពណ៌ប្រផេះ** គឺតំណាងឲ្យភាពចំណេញខាត នៃដំណើរការទីផ្សារ។
- **រូបហង្សពណ៌មាសឈរលើរង្វង់ថាស ដែលមានជើងម្ខាងជាន់លើផ្ទៃរង្វង់ពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃពណ៌ប្រផេះ** ចង់បង្ហាញពីភាពចំណេញខាត ឬភាពឡើងចុះនៃកិចដំណើរការទីផ្សារ ដោយស្ថិតនៅក្រោមការត្រួតពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរ ជានិយ័តករមូលបត្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព សណ្ដាប់ធ្នាប់ និងតម្លាភាពគ្នាជានិច្ច។
- **រូបស្លឹកឈើ** តំណាងឲ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែក របស់វិស័យមូលបត្រក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។

❖ **មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា**

- រូបហង្សពណ៌មាសជាប់ពាក់ពន្ធ័ទៅនឹង ដំណើរការអភិវឌ្ឍន៍នៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើប្រាក់ប្រាសាទ ក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក **សំអាង ហង្ស** ដែលព្រះបាទអង្គឌួងបានបញ្ជូនឲ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានចូលរួមចំណែកយ៉ាងខ្លាំង ក្នុងការធ្វើឲ្យរូបិយវត្ថុមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ចេញឲ្យប្រើប្រាស់នៅក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាដំណាងឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម ក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ និងនៅក្នុងសម័យសាធារណៈរដ្ឋក្រោមការដឹកនាំដោយឈ្លាសវៃរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលនៅពេលនោះត្រូវគ្នា នឹងនិយ័តករមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុ ហើយមានប្រធានជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ។

## ២.៤.៣.ត្រារបស់និយ័តករមូលបត្រកម្ពុជា



ត្រារបស់និយ័តករមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់ អាជ្ញាធរឬស្ថាប័នដ៏ទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "**ព្រះរាជាណាចក្រកម្ពុជា**" ផ្នែកកណ្តាលមានសញ្ញា "ប្រាសាទអង្គរវត្ត" និង ផ្នែកខាងក្រោមមានសេសេរអក្សរថា "**គណៈកម្មការមូលបត្រកម្ពុជា**"។

រូបភាព៣. ត្រារបស់និយ័តករមូលបត្រកម្ពុជា

## ២.៥. សមាសភាពរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រកម្ពុជា ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពី "ការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន" ដែលមានប្រធានមួយរូប ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងមានសមាជិក៨រូបទៀតដែលមានសមាសភាពដូចជា៖

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១រូប
- តំណាងក្រសួងពាណិជ្ជកម្ម ១រូប
- តំណាងធនាគារជាតិនៃកម្ពុជា ១រូប
- តំណាងក្រសួងយុត្តិធម៌ ១រូប

- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី ១រូប
- អគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា ១រូប
- អ្នកជំនាញដែលបទពិសោធន៍ក្នុងវិស័យមូលប័ត្រ ២រូប

❖ សមាជិកនិយ័តករមូលបត្រកម្ពុជា អាណត្តិទី២ (២០១៣ - ២០១៨)

និយ័តករមូលបត្រកម្ពុជាដែលមានឯកឧត្តមបណ្ឌិត អូន ពន្ធ័មុនីរ័ត្ន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន និងមានសមាជិកចំនួន៨រូបទៀតដែលមានអាណត្តិរយៈពេល៥ឆ្នាំ ដែលសមាជិកទាំងនោះរួមមាន៖

- លោកជំទាវ ងួន សុខា ជារដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លោកជំទាវ នាវ ច័ន្ទថាណា ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- លោកជំទាវ តឹករ៉េត កំរង ជារដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម
- ឯកឧត្តម កើត រិទ្ធ ជារដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម កឹម រ័ត្នវិសិដ្ឋ ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណរដ្ឋមន្ត្រី
- ឯកឧត្តម ស៊ូ សុជាតិជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា
- លោកសាស្ត្រាចារ្យបណ្ឌិត សំ ឃង្វី និងលោកសាស្ត្រាចារ្យបណ្ឌិត សំ សុខុម ជាអ្នកជំនាញមកពីវិស័យឯកជនដែលមានបទពិសោធក្នុងវិស័យមូលបត្រ

## ១.៦.រចនាសម្ព័ន្ធអង្គការចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា

និយ័តករមូលបត្រមានរចនាសម្ព័ន្ធអង្គការចាត់តាំងដូចខាងក្រោម៖




រូបភាព៤. រចនាសម្ព័ន្ធចាត់តាំងរបស់និយ័តករមូលបត្រកម្ពុជា

❖ និយ័តករមូលប័ត្រកម្ពុជាមានមាននាយកដ្ឋានចំណុះ ចំនួន៦នាយកដ្ឋាន ដែលត្រូវគ្រប់គ្រងដោយអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា៖

**១.នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ:** មានមុខងារតួនាទីដូចជា៖

- រៀបចំផែនការ និងថវិការរបស់ ន.ម.ក
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គត់ផ្គង់ និងជួសជុលសម្ភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយគ្រប់គ្រងនិងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថមនានា ដល់មន្ត្រី ន.ម.ក
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន។

**២.នាយកដ្ឋានគ្រប់គ្រងនិងបោះផ្សាយលក់មូលបត្រ:** មានមុខងារតួនាទីដូចជា៖

- រៀបចំលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាត ឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- រៀបចំ និងត្រួតពិនិត្យ លក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាប្រចាំ
- ត្រួតពិនិត្យការអនុវត្តតាមស្តង់ដាគណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ត្រួតពិនិត្យនិងផ្តល់យោបល់ លើការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ ផ្តល់យោបល់ និងចុះបញ្ជី លើការស្នើសុំចុះបញ្ជីឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងការនានា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ពត៌មាន ឯកសារផ្តល់ពត៌មានបន្ថែម ឯកសារផ្តល់ពត៌មានជំនួស និងសេចក្តីថ្លែងការនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិច ឬ/និងតាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ
- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ និង/ឬ របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ
- បញ្ជូនសុំណុំរឿង សង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីស៊ើបអង្កេតបន្ត។

**៣.នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រៈ** មានតួនាទីដូចជា៖

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួម ដ៏ទៃទៀតក្នុងទីផ្សារ ដើម្បីដាក់ការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកន.ម.ក.
- ពិនិត្យនិងផ្តល់យោបល់ដល់ការស្នើសុំអាជ្ញាប័ណ្ណដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួម ដ៏ទៃទៀតក្នុងទីផ្សារ
- ត្រួតពិនិត្យ តាមដាន និងត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងបើមានការចាំបាច់ នូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួម ដ៏ទៃទៀតក្នុងទីផ្សារ
- បញ្ជូនសុំណុំរឿងសង្ស័យថា មានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួម ដ៏ទៃទៀតក្នុងទីផ្សារ។

**៤.នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**

- រៀបចំបទបញ្ញត្តិ និងលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការជាមួយប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់ពាក្យសុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយក ន.ម.ក
- ពិនិត្យ និងផ្តល់យោបលលើពាក្យស្នើសុំការអនុញ្ញាតដើម្បីធ្វើជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិការផ្សេងៗទៀត របស់ប្រតិបត្តិករទីផ្សារមូលបត្រ
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការ នៃ ប្រតិបត្តិកររក្សាទុកមូលបត្រ ប្រតិបត្តិករជាត់ទាត់និងទូទាត់

- ត្រួតពិនិត្យ ជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ចំពោះ ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សារទុកមូលបត្រ
- បញ្ជូនសុំណុំរឿង សង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិ ពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សារទុកមូលបត្រ ទៅនាយកដ្ឋានគតិយុត្ត ដើម្បីសើបអង្កេតបន្ត។

**៥.នាយកដ្ឋានកិច្ចការគតិយុត្ត**

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការ របស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករផាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សារទុកមូលបត្រ ដើម្បីដាក់ពាក្យសុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយក ន.ម.ក
- ពិនិត្យនិងផ្តល់យោបល់លើ វិធានប្រតិបត្តិការ ដែលស្នើដោយស្ថាប័ននិយ័តករ
- រៀបចំបទបញ្ញត្តិចាំបាច់នានា និងលើកសំណើរធ្វើវិសោធនកម្មច្បាប់ និងបទបញ្ញត្តិផ្សេងៗដើម្បីគាំទ្រ ដល់ការអភិវឌ្ឍវិស័យមូលបត្រ
- ពង្រឹងការអនុវត្តច្បាប់ ឬបទបញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ
- ទទួលពាក្យបណ្តឹង និងធ្វើការសើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិការបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូងនិងទីផ្សារបន្ទាប់
- ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការដាក់ពិន័យនានា ពាក់ព័ន្ធនឹងបុគ្គលប្រព្រឹត្តិល្មើសនឹងច្បាប់ និងបទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ
- សម្រុះសម្រួលដោះស្រាយវិវាទ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ
- រៀបចំសំណុំរឿង ពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ជូនរបស់អគ្គនាយក ន.ម.ក.។

**៦.នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សាមូលបត្រ និងទំនាក់ទំនងអន្តរជាតិ**

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍវិស័យមូលបត្រ។
- គ្រប់គ្រង រៀបចំយុត្តិសាស្ត្រ ដើម្បីជម្រុញឲ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ជាសាធារណៈ
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មី មុននឹងអនុញ្ញាតឲ្យបោះផ្សាយលក់នៅលើទីផ្សារ
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណៈជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ
- ធ្វើទំនាក់ទំនង ជាមួយនិយ័តករមូលបត្រ តាមបណ្តាប្រទេសក្នុងតំបន់ និងក្នុងពិភពលោក ។

- **អង្គភាពសវនកម្មផ្ទៃក្នុង** ( **ស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាននិយ័តករមូលបត្រ** )
  - ត្រួតពិនិត្យលើមុខងារ សកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ ន.ម.ក. ក្នុងកាលបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តិឲ្យបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទបញ្ញត្តិផ្សេងៗ និងការត្រួតពិនិត្យ ដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងស្របតាមគោលដៅរបស់ ន.ម.ក
  - កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្អែកគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានា របស់ន.ម.ក.
  - ពិនិត្យលើភាពដែលអាចជឿជាក់បាន ភាពពេញលេញនៃពត៌មាន ទិន្នន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍ អំពីពត៌មាន និងទិន្នន័យផ្សេងទៀតក្នុងពេលសមស្រប
  - ធ្វើសវនកម្មផ្ទៃក្នុង ពេលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចដែលជាប្រធានន.ម.ក
  - រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃន.ម.ក. ។

## ២.៧. មុខងាររបស់និយ័តករមូលបត្រកម្ពុជា

ដើម្បីធានាឲ្យបាន នូវការជួញដូរមូលបត្រមួយដែលប្រកបទៅដោយ យុត្តិធម៌ តម្លាភាព មានសណ្តាប់ធ្នាប់និងមានភាពត្រឹមត្រូវ នៅក្នុងវិស័យមូលបត្រកម្ពុជា និយ័តករមូលបត្រកម្ពុជាមានមុខងារមួយចំនួនដូចខាងក្រោម[៨]៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ដាក់ឲ្យអនុវត្តន៍នូវគោលនយោបាយ ដែលពាក់ពន្ធ័និងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតិ ជូនប្រតិបត្តិករទីផ្សាមូលបត្រ ប្រតិបត្តិករប្រព័ន្ធទូទាត់និងផាត់ទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់សញ្ញាប័ណ្ណជូនក្រុមហ៊ុន និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់និង ជម្រុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ
- ដើរតួជាស្ថាប័ណ្ណពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះ សេចក្តីសម្រេចរបស់នីតិបុគ្គល មានអាជ្ញាប័ណ្ណ
- ពិគ្រោះយោបល់ជាមួយបុគ្គល ដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍទីផ្សាមូលបត្រនៅកម្ពុជា។

[៨] ច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ,ភ្នំពេញ ២០០៧

# ជំពូកទី៣

# ស្ថានភាពទូទៅនៃក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា

# ជំពូកទី៣

# ស្ថានភាពទូទៅនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.១. ប្រវត្តិនៃការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ដើម្បីសម្រេចបាននូវការអភិវឌ្ឍ ប្រទេសកម្ពុជាដោយឈរលើគោលដៅក្នុងការជំរុញឲ្យមានកំណើនសេដ្ឋកិច្ច តាមរយៈលំហូរមូលធន ការវិនិយោគ និង ការវិភាជន៍ជាថ្មីនូវមូលធនតាមយន្តការទីផ្សារមូលធន នៅខែ វិច្ឆិកា ឆ្នាំ ២០០៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េបានចុះ ហត្ថលេខាលើអនុស្សរណៈយោគយល់ ស្តីអំពី "ការអភិវឌ្ឍផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"។ ដោយផ្អែកលើអនុស្សរណៈយោគយល់នេះ **សម្តេចអគ្គសេនាបតីតេជោហ៊ុនសែននាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសបើកអោយដំណើរការគម្រោងបង្កើតទីផ្សារមូលបត្រនៅប្រទេសកម្ពុជា នៅ ខែកញ្ញា ឆ្នាំ ២០០៧។ នៅឆ្នាំ ២០០៨ អនុស្សរណៈយោគយល់មួយទៀតស្តីអំពី "ការបង្កើតផ្សារមូលបត្រនៅព្រះរាជាណាចក្រកម្ពុជា"ត្រូវបានចុះហត្ថលេខាដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ នៅខែ មីនា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ បានចុះកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ ( Joint Venture ) ដើម្បីបង្កើតផ្សារមូលបត្រ ( "ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា" )ស្របតាមច្បាប់ស្តីអំពីសហគ្រាសសាធារណៈ។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានចុះក្នុងបញ្ជីពាណិជ្ជកម្មនៅថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០១០។ ស្របតាមកិច្ចព្រមព្រៀង ក្រុមហ៊ុនចំរុះ ( Joint Venture ) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាន់កាប់ភាគហ៊ុនចំនួន៥៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាហើយ ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េកាន់កាប់ភាគហ៊ុនចំនួន ៤៥%នៃភាគហ៊ុនសរុបរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាប័ណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា ( គ.ម.ក. ) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។ ផ្សារមូលបត្រកម្ពុជាត្រូវបានសម្ពោធដាក់អោយដំណើរការ កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១១ ក្រោមអធិបតីភាពរបស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ជាលទ្ធផលនៃការខិតខំប្រឹងប្រែង នៅថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង៩:០៩នាទីព្រឹក ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បានអនុវត្តន៍ការជួញដូរមូលបត្រកម្មសិទ្ធជាលើកដំបូង ដែលប្រកាសបើកជាផ្លូវការ តាមរយៈសារវីដេអូដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គសេនាបតីតេជោហ៊ុន សែន និងមានវត្តមានតំណាងដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់។[៩]

[៩] http://csx.com.kh ( ទិដ្ឋទូទៅរបស់ ផ.ម.ក. )

## ៣.២. ចក្ខុវិស័យ និងបេសកកម្ម របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

### ៣.១.២. ចក្ខុវិស័យ

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានចក្ខុវិស័យ៖ ដើម្បីកសាងនូវ “មហាវិថី”ហិរញ្ញវត្ថុសម្រាប់កម្ពុជា។

### ២.១.៣.បេសកកម្ម




រូបភាព៥ បេសកកម្មរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.៣. នាមករណ៍ និងផ្លាកសញ្ញា

➢ នាមករណ៍

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាមានឈ្មោះពេញជាភាសារខ្មែរថាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលមានអក្សរកាត់ថា **ផ.ម.ក.** និងជាភាសារអង់គ្លេសថា Cambodia Securities Exchange និងមានអក្សរកាត់ជាភាសារអង់គ្លេសថា CSX ។

➢ ផ្លាកសញ្ញា

រូបភាពទី៦. ផ្លាកសញ្ញាក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ផ្លាកសញ្ញារបស់ក្រុមហ៊ុនផ្សារមូលបត្រ មានសរសេរជាអក្សរខ្មែរពណ៌ខៀវ នៅផ្នែកខាងលើថា **"ផ្សារមូលបត្រកម្ពុជា"** ដែលជាឈ្មោះរបស់ក្រុមហ៊ុន។ ចំណែកនៅខាងក្រោមអក្សរ ផ្នែកខាងឆ្វេងវិញមានសរសេរជាអក្សរកាត់ពណ៌ខៀវ ដែលជាភាសាអង់គ្លេសថា **CSX** ដែលមានន័យពេញថា Cambodia Securities Exchange និងនៅផ្នែកខាងស្តាំមានរូបហង្សពណ៌មាសឈរបែរមុខទៅស្តាំ។

## ៣.៤.រចនាសម្ព័ន្ធនៃការគ្រប់គ្រង

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានរចនាសម្ព័ន្ធគ្រប់គ្រងដូចខាងក្រោម៖




រូបភាពទី៧. រចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

## ៣.៥.ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃនិយ័តករមូលបត្រកម្ពុជា រួមមានសមាជិកចំនួន ៧រូប ដោយរាប់បញ្ចូលទាំងប្រធានក្រុមប្រឹក្សាភិបាល អនុប្រធានក្រុមប្រឹក្សាភិបាល(ដែលជាអគ្គនាយករងផងដែរ) និងអគ្គនាយក។ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយកជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា។ចំណែក អនុប្រធានក្រុមប្រឹក្សាភិបាលគឺជាតំណាងរបស់ក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ សមាជិកចំនួន ៤រូបផ្សេងទៀតគឺជាអភិបាលមិនអចិន្ត្រៃយ៍ ដោយក្នុងនោះ២រូបត្រូវបានតែងតាំងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង២រូបទៀតត្រូវបានតែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។

## ៣.៦.ពត៌មានទំនាក់ទំនងរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានអាសយដ្ឋានស្ថិតនៅ អគារ ផ.ម.ក វិថីព្រះមហាក្សត្រីយានី កុសុមៈ (ផ្លូវ១០៦) សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។
- ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៥៨ ៨៨៨
- ទូរសារ ៖ (៨៥៥) ២៣ ៩៥៥ ៥៥៨
- ក្រសួងនិងស្ថាប័នពាក់ពន្ធ ៖ infor@csx.com.kh
- គេហទំព័រ ៖ www.csx.com.kh
- គេហទំព័រពាក់ព័ន្ធ
  - http://www.secc.gov.kh
  - http://www.mef.gov.kh
  - http://www.moc.gov.kh
  - http://www.nbc.org.kh

# ជំពូកទី៤

## ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ
## លើកដំបូង

# ជំពូកទី៤
# ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូង

## ៤.១. តួអង្គពាក់ព័ន្ធក្នុងវិស័យមូលបត្រ

### ៤.១.១.ក្រុមហ៊ុនបោះផ្សាយ

ក្រុមហ៊ុនមួយ ដើម្បីអាចបោះផ្សាយលក់មូលបត្រជាសាធារណៈបានលុះត្រាតែក្រុមហ៊ុននោះ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬជានីតិបុគ្គលប្រតិស្រុត ដែលទទួលបានការអនុញ្ញាតិពីនិយ័តករមូលបត្រកម្ពុជា ក្នុងការបោះផ្សាយលក់មូលបត្រ ត្រឹមត្រូវទៅតាមផ្លូវច្បាប់។ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ជាតួអង្គមួយយ៉ាងសំខាន់នៅក្នុងវិស័យមូយបត្រ ព្រោះថាបើគ្មានក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនោះទេ ក៏គ្មានមូលបត្រសម្រាប់ជួញដូរនៅលើទីផ្សារដែរ។

បើយោងតាមគេហទំព័ររបស់ក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជាបានឲ្យដឹងថា គិតត្រឹមខែកក្កដា ឆ្នាំ២០២១ នេះ ក្រុមហ៊ុនដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈនៅកម្ពុជាសរុបទាំងអស់មានចំនួន១៣ក្រុមហ៊ុន រួមមាន៖

- ក្រុមហ៊ុនបោះផ្សាយលក់មូលបត្របំណុលចំនួន៦
    - ធនាគារ ហត្ថា ម.ក
    - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ភីអិលស៊ី
    - ធនាគារ អេប៊ីអេ
    - ធនាគារភ្នំពេញពាណិជ្ជ “ភីភីស៊ីប៊ែង” ម.ក
    - អ អិម អេ (ខេមបូឌា) ម.ក
    - គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ម.ក
- ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្មសិទ្ធចំនួន៧
    - ផេសចិក (ខេមបូឌា) ម.ក
    - ធនាគារ អេស៊ីលីដា ភីអិលស៊ី
    - កំពង់ផែស្វយ័តក្រុងព្រះសីហនុ
    - ក្រុមហ៊ុន ភ្នំពេញ អេស៊ីហ្សិត ភីអិលស៊ី
    - កំពង់ផែស្វយ័តក្រុងភ្នំពេញ
    - ក្រុមហ៊ុន ហ្គ្រេនធ្វីន អិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី
    - រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

❖ **ក្រុមហ៊ុនបោះផ្សាយមូលបត្រកម្មសិទ្ធ**

**ក. រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ត្រូវបានបង្កើតឡើងជាគ្រឹស្ថានសារធារណៈ ដែលមានលក្ខណៈសេដ្ឋកិច្ច ស្ថិតក្រោមច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។ នាថ្ងៃទី ១៨ ខែមេសា ឆ្នាំ២០១២ រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានចុះបញ្ជីជាផ្លូវការនៅ ផ.ម.ក ដោយបានបោះផ្សាយលក់មូលបត្រជាសាធារណៈ ចំនួន ១៣,០៤៥,៩៧៥ ភាគហ៊ុន ដែលស្មើនឹង ១៥ភាគរយ នៃចំនួនភាគហ៊ុនសរុប។[១៦]

រូបភាពទី៨. ស្លាកសញ្ញាPPWSA

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ |
| និមិត្តសញ្ញា | រ.ទ.ស.ភ |
| លេខកូដស្តង់ដា | KH 1000010004 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនធម្មតា |
| ភាគហ៊ុនបោះផ្សាយ | ១៣.០៤៥.៩៧៥ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ២៩/០២/២០១២ ដល់ ១៣/០៣/២០១២ |
| ចន្លោះក្នុងការធ្វើប៊ុកបៀលឌីង | ពី៤.០៥០រៀល ដល់៦.៣៥០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ២៩/០៣/២០១២ ដល់០៤/០៤/២០១២ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៦.៣០០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | តុងយ៉ាង ស៊ីយូរីធី(ខេមបូឌា) ភីអិលស៊ី |

តារាងទី១.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធP P WS A

[១៦] http://csx.com.kh/data/Istcom/listPosts.do?MNCD=50101 ស្តីពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ខ. ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណាល

ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណាល គឺជា ក្រុមហ៊ុនផលិតសម្លៀកបំពាក់ ដែលបានបង្កើតឡើង ក្នុងឆ្នាំ២០០៧ ។នៅឆ្នាំ២០០៨ក្រុមហ៊ុន ហ្គ្រេនធ្វីន បានទិញយកក្រុមហ៊ុន QMI Industrial Co., Ltd ដែលជារោងចក្រកាត់ដេរដ៏ធំមួយ ក្នុងចំណោមរោងចក្រកាត់ដេរធំៗនៅកម្ពុជា។ ក្រុមហ៊ុនហ្គ្រេនធ្វីន គឺជាក្រុមហ៊ុនម៉ៅការបន្ត និងជារោងចក្រផលិតសម្លៀកបំពាក់ផ្ទាល់សម្រាប់នាំចេញ។ សព្វថ្ងៃផលិតផលរបស់ក្រុមហ៊ុន ហ្គ្រេនធ្វីន រួមមានម៉ាកសម្លៀកបំពាក់កីឡាល្បីៗ ដូចជា Adidas, Reebok, Taylor made, Salomon, New Balance (NB), Kohls, Nautica and North Face។ក្រុមហ៊ុន ហ្គ្រេនធ្វីន បានចុះបញ្ជីក្នុងផ្សារមូលបត្រកម្ពុជា និងធ្វើ Book building នៅថ្ងៃទី ១៧ ដល់ ២៨ មិនា ឆ្នាំ២០១៥ ហើយចន្លោះថ្លៃក្នុងការធ្វើ Book building គឺ ៧,៤០០រៀល ដល់ ១៤,០០០រៀល។

រូបភាពទី៩ ស្លាកសញ្ញាGTI

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុន ហ្គ្រេនធ្វីន អ៊ិនធើណេសិនណាល |
| និមិត្តសញ្ញា | ហ្គ្រេនធ្វីន |
| លេខកូដស្តង់ដា | KH 1000020003 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនធម្មតា |
| ភាគហ៊ុនបោះផ្សាយ | ៨.០០០.០០០ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ១៧/០៣/២០១៤ ដល់ ២៨/០៣/២០១៤ |
| ចន្លោះក្នុងការធ្វើប៊ុកបៀលឌីង | ពី៧.៤០០រៀល ដល់១៤.០០០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ០២/០៦/២០១៤ ដល់២៨/០៦/២០១៤ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៩.៦៤០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី |

តារាងទី២.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធGTI

[១៧] http://csx.com.kh/data/Istcom/listPosts.do?MNCD=50101 ស្តីពីក្រុមហ៊ុនហ្គេន ធ្វីនអ៊ិនធើណេសិនណាល

**គ. កំពង់ផែស្វយ័តភ្នំពេញ**( PPAP)

កំពង់ផែស្វយ័តក្រុងភ្នំពេញគឺជាប្រតិបត្តិករកំពង់ផែទន្លេធំជាងគេ និងជាកំពង់ផែអន្តរជាតិមួយក្នុងចំណោម ប្រតិបត្តិករកំពង់ផែអន្តរជាតិទាំងពីនៅប្រទេសកម្ពុជា។ ក្នុងនាមជាប្រតិបត្តិករផែក.ស.ភ. មានផ្តល់សេវាកម្មដូចជា លើកដាក់ក្រោមដងយោង លើកដាក់លើទីលាន ឃ្លាំងស្តុកទំនិញ កណ្តាកិច្ច ទីលានស្តុកទុកសំបកកុងតឺនឺ រើរៀបទំនិញ ទូកុងតឺន័រត្រជាក់ វាស់ស្ទង់និងបូមស្ពា ជួសជុលនិងថែទាំកុងតឺន័រ ប្រមូលផ្តុំនិងចែកចាយទំនិញ និងសេវារថយន្តដឹកជញ្ជូនក្រៅចំណតផែរ។

រូបភាពទី១០.និមិត្តសញ្ញាPPAP

កំពង់ផែរស្វយ័តភ្នំពេញ បានបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង និងបានធ្វើ Book building នៅថ្ងៃទី ១៩ ដល់ ២២ តុលា ឆ្នាំ ២០១៥ ហើយចន្លោះថ្លៃក្នុងការធ្វើ Book building គឺ ៤,៤០៥រៀល ដល់ ៦,៣២០រៀល។[១៩]

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | កំពង់ផែរស្វយ័តភ្នំពេញ |
| និមិត្តសញ្ញា | ក.ស.ភ. |
| លេខកូដស្តង់ដា | KH 1000040001 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៤.១៣៦.៨៧៣ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ១៩/១០/២០១៥ ដល់ ២២/១០/២០១៥ |
| ចន្លោះក្នុងការធ្វើប៊ុកបៀលឌីង | ពី៤.៤០៥រៀល ដល់៦.៣២០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ១២/១១/២០១៥ ដល់១៧/១១/២០១៥ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៥.១២០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី |

តារាងទី៣.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPPAP

[១៩] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 ស្តីពីកំពង់ផែស្វយ័តក្រុងភ្នំពេញ

### ឃ. ក្រុមហ៊ុនភ្នំពេញ អេសស៊ីហ្សិត ភីអិលស៊ី (PPSP)

ក្រុមហ៊ុនភ្នំពេញ អេសស៊ីហ្សិត ភីអិលស៊ី គឺជាអ្នកអភិវឌ្ឍ និងប្រតិបត្តិករនៃ តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ (PPSEZ) និងប៉ោយប៉ែត ភីភី អេសអីហ្សិត (Poipet PPSEZ) ។ នាថ្ងៃទី១៩ មេសាឆ្នាំ២០០៦ ក្រុមហ៊ុនទទួលបានការអនុញ្ញាតិពីរាជរដ្ឋាភិបាលកម្ពុជា ដើម្បីក្លាយខ្លួនជាអ្នកអភិវឌ្ឍ តំបន់សេដ្ឋកិច្ចពិសេសដែលអាចធ្វើប្រតិបត្តិការអាជីវកម្មច្រើនប្រភេទ។ បច្ចុប្បន្ននេះជាតំបន់សេដ្ឋកិច្ចពិសេស ដែលកំពង់ធ្វើប្រតិបត្តិការនៅជិតទីប្រជុំជននៃរាជធានីភ្នំពេញ ដែលមានអាជីវកម្មចំបងក្នុងការអភិវឌ្ឍដីឧស្សាហកម្មសម្រាប់លក់និងជួល។ ក្រុមហ៊ុនភ្នំពេញ អេសស៊ីហ្សិត ភីអិលស៊ី បានបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង នៅក្នុងផ្សារហ៊ុនកម្ពុជា ហើយកាលបរិច្ឆេទនៃការធ្វើ Book building ( ការស្ទាបស្ទង់តម្លៃមូលបត្រជាសាធារណៈ ) ធ្វើឡើងរយៈពេល៥ថ្ងៃ ចាប់ពីថ្ងៃទី ១៨ ដល់ ២២ មេសា ឆ្នាំ២០១៦។[១៩]

រូបភាពទី១១.និមិត្តសញ្ញាPPSP

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុនភ្នំពេញ អេសស៊ីហ្សិត ភីអិលស៊ី |
| និមិត្តសញ្ញា | ភីភីអេសភី |
| លេខកូដស្តង់ដា | KH 1000050000 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ១១.៥៧៥.000 |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ១៨/០៤/២០១៦ ដល់ ២៥/០៤/២០១៦ |
| ចន្លោះក្នុងការធ្វើប៊ុកបៀលឌីង | ពី២.៨00រៀល ដល់៤.000រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ០៩/០៦/២០១៦ ដល់១២/០៦/២០១៦ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ២.៨៦០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អេសប៊ីអាយ រ៉ូយាល់ ស៊ីឃ្យូរីធី កម្ពុ ស៊ីឃ្យូរីធី |

តារាងទី៤.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPPSP

[១៩] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 ស្តីពីក្រុមហ៊ុនភ្នំពេញ អេសស៊ីហ្សិត ភីអិលស៊ី

### ខ. កំពង់ផែស្វយ័តក្រុងព្រះសីហនុ (PAS)

កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាក្រុមហ៊ុនរដ្ឋដែលបង្កើតឡើងដើម្បីធ្វើអាជីវកម្ម សេវាកម្មមូលដ្ឋានលើការងារៈ កណ្តាធាកិច្ច នាំនាវាចេញចូលនិងផ្តល់ភស្តុភាដល់នាវា លើកដាក់ ផ្ទេរ ផ្ទុកទំនិញ ស្តុកទំនិញនៅឃ្លាំង និងទីលាន ព្រមទាំងដឹកជញ្ជូនទំនិញ។ បច្ចុប្បន្ន កំពង់ផែស្វយ័តក្រុងព្រះសីហនុ មានផ្តល់សេវាកម្មផ្សេងទៀតដូចជាៈ សេវាក្នុងតំបន់សេដ្ឋកិច្ចពិសេសដូចជាជួលឃ្លាំង និងថែរក្សាទំនិញ លើកដាក់និងដឹកជញ្ជូនទំនិញ រួមទាំងសេវាសន្តិសុខក្នុងកំពង់ផែ និងតំបន់សេដ្ឋកិច្ចពិសេស។ កំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាក្រុមហ៊ុន ដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រ នៅក្រុមហ៊ុនទីផ្សារមូលបត្រ នៅដើមខែមិថុនា ឆ្នាំ២០១៧ បន្ទាប់ពីរកមូលនិធិបាន ២៧លានដុល្លារពីការបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង។[២០]

រូបភាពទី១២. និមិត្តសញ្ញាPAS

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | កំពង់ផែស្វយ័តក្រុងព្រះសីហនុ |
| និមិត្តសញ្ញា | ក.ស.ស |
| លេខកូដស្តង់ដា | KH 1000060009 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ២១.៤៤២.៩៩២ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ២៥/០៤/២០១៧ ដល់ ០២/០៥/២០១៧ |
| ចន្លោះក្នុងការធ្វើប៊ុកបៀលឌីង | ពី៣.៥២០រៀល ដល់៥.១៨០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ១៧/០៥/២០១៧ ដល់២២/០៥/២០១៤ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៥.០៤០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី |

តារាងទី៥.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPAS

[២០] http://csx.com.kh/data/Istcom/listPosts.do?MNCD=50101 ស្តីពីកំពុងផែស្វយ័តក្រុងព្រះស៊ីហនុ

**ច. ធនាគារអេស៊ីលីដា** (ACLEDA Plc )

ធនាគារអេស៊ីលីដា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៩៣ ដែលស្ថិតក្រោមគំរោងអង្គការពលកម្មអន្តរជាតិ ក្នុងយុគសម័យក្រោយសង្គ្រាមនៅកម្ពុជា។ ជាច្រើនឆ្នាំមកនេះធនាគារអេស៊ីលីដា បានឆ្លងកាត់នូវការផ្លាស់ប្តូរជាច្រើនលើកច្រើនសារមកហើយ។ បច្ចុប្បន្ននេះធនាគារអេស៊ីលីដា មានទីស្នាក់ការកណ្តាលនៅក្នុងរាជធានីភ្នំពេញ ហើយគឺជាធនាគារឈានមុខនិងធំជាងគេផ្នែកឥណទានដុល និងមានសាខាគ្រប់ខេត្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារអេស៊ីលីដា ក៏ជាធនាគារកម្ពុជាដំបូងដែលបានពង្រីកប្រតិបត្តិការរបស់ខ្លួនទៅក្រៅប្រទេសដែលរួមមានប្រទេសឡាវនិងមីយ៉ាន់ម៉ា ហើយថ្មីៗនេះធនាគារបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈនៅក្នុងទីផ្សារមូលបត្រកម្ពុជាផងដែរ។ទោះបីជាធនាគារទើបតែបានបោះផ្សាយលក់ក៏ដោយតែ សន្ទុះនៃការជួញដូរមូលបត្ររបស់ធនាគារ នេះមានភាពខ្លាំងខ្លាជាងគេ។[២១]

រូបភាពទី១៣.និមិត្តសញ្ញាACLEDA Plc

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ធនាគារអេស៊ីលីដា ភីអិលស៊ី |
| និមិត្តសញ្ញា | ធ.អ.ក. |
| លេខកូដស្តង់ដា | KH 1000100003 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនចុះបញ្ជី | ៤៣៣,១៦៣,០១៩ |
| កាលបរិច្ឆេទធ្វើប៊ុកបៀលឌីង | ០៣/០៣/២០២០ ដល់ ១៤/០៣/២០២០ |
| ចន្លោះក្នុងការធ្វើប៊ុកបៀលឌីង | ពី១៥.០០០រៀល ដល់១៧.៤០០រៀល |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ២៤/០៣/២០២០ ដល់២៤/០៤/២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ១៦.២០០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | យ៉ាន់តា ស៊ីឃ្យូរីធី ភីអិលស៊ី |

តារាងទី៦.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធACLEDA Plc

[២១] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 ស្តីពីធនាគារអេស៊ីលីដា

**ឆ. ក្រុមហ៊ុនផេសថិក (ខេមបូឌា)**

ក្រុមហ៊ុន ផេសថិកបានចុះបញ្ជីក្នុងឆ្នាំ២០១០ ជាក្រុមហ៊ុនបច្ចេកទេសថាមពលអគ្គិសនី ដែលបានផ្តល់សេវាសំខាន់ៗ លើការផ្តល់ជូនវិស្វករប្រព័ន្ធថាមពល និងដំណោះស្រាយបច្ចេកទេសផ្សេងៗ ដូចជា៖ ការគូសប្លង់លទ្ធកម្ម ការសាងសង់និងការដំឡើង ការដាក់ឲ្យប្រើប្រាស់នូវស្ថានីមានតង់ស្យុងខ្ពស់ និងតង់ស្យុងខ្ពស់ខ្លាំង និងបណ្តាញបញ្ជូលអគ្គិសនីដែលមានតង់ស្យុងខ្ពស់និងខ្ពស់ខ្លាំង ក៏ដូចជាប្រព័ន្ធថាមពលខ្សែកាបក្រោមដីសម្រាប់បញ្ជូន និងចែកចាយអគ្គិសនី និងការជួញដូរបង្គុំ និងបរិក្ខាប្រព័ន្ធថាមពល ដែលជាកម្មសិទ្ធនិងមិនមែនជាកម្មសិទ្ធ។ ក្រុមហ៊ុន ផេសថិក ជាក្រុមហ៊ុនមួយដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រ ចុងក្រោយគេ ដែលបានចុះបញ្ជីនៅថ្ងៃទី ១២ ខែ សីហា ឆ្នាំ២០២០ ។ ក្រុមហ៊ុននេះ បានបោះផ្សាយលក់ មូលបត្រចំនួន ៣,៩៤៥,០០០ ហ៊ុន ហើយមានតម្លៃ ៣,១២០រៀលក្នុងមួយហ៊ុន។ [២២]

រូបភាពទី១៤. ស្លាកសញ្ញាក្រុមហ៊ុនPEPC

| តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាលើកដំបូង | |
|---|---|
| ឈ្មោះក្រុមហ៊ុន | ក្រុមហ៊ុន ផេសថិក ខេមបូឌា |
| និមិត្តសញ្ញា | ផ.ថ.ខ (PEPC) |
| លេខកូដស្តង់ដា | KH 1000140009 |
| ប្រភេទភាគហ៊ុន | ភាគហ៊ុនមានសិទ្ធបោះឆ្នោត |
| ភាគហ៊ុនបោះផ្សាយ | ៣,៩៤៥,០០០ |
| កាលបរិច្ឆេទធ្វើបរិវិសកម្ម | ២៧/០៧/២០២០ដល់០៤/០៨/២០២០ |
| តម្លៃបោះផ្សាយលក់ជាសាធារណៈលើកដំបូង | ៣.១២០រៀល |
| ក្រុមហ៊ុនធានាទិញមូលបត្រ | អអេចប៊ី ស៊ីយូរីធី |

តារាងទី៧.តារាងសង្ខេបលទ្ធផលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធPEPC

[២២] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 ស្តីពីក្រុមហ៊ុនផេសថិក ខេមបូឌា

### ៤.១.២. ប្រតិបត្តិករមូលបត្រ

ប្រតិបត្តិករមូលបត្រ គឺសំដៅដល់ទីផ្សារមូលបត្រកម្ពុជា (ផ.ម.ក.) ដែលត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ដែលតំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានភាគហ៊ុន៥៥%នៃភាគហ៊ុនសរុបរបស់ផ្សារមូលបត្រកម្ពុជា និង៤៥%ទៀតកាន់កាប់ដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ។ ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជាបានទទួលអាជ្ញាប័ណ្ណជា ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ព្រមទាំងប្រតិបត្តិកររក្សាទុកមូលបត្រ ពីគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ស្របតាមច្បាប់ស្តីអំពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

#### ៤.១.២.១. ប្រតិបត្តិករទីផ្សារមូលបត្រ

ផ.ម.ក.ផ្តល់នូវប្រព័ន្ធជួញដូរ និងជាទីផ្សារក្នុងការទិញលក់មូលបត្រ ដែលអ្នកទិញនិងអ្នកលក់អាចធ្វើការទិញលក់មូលបត្រជាមួយគ្នា នូវតម្លៃនិងទីតាំងដាក់លាក់ណាមួយ។ ការជួញដូរមូលបត្រនេះ ដំណើរការទៅដោយមានជំនួយពីក្រុមហ៊ុនជើងសារមូលបត្រ។

#### ៤.១.២.២.ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ

ផ្សារមូលបត្រកម្ពុជា មិនត្រឹមតែដើរតួនាទីជា ប្រតិបត្តិករទីផ្សារមូលបត្រទេ ប៉ុន្តែ ផ.ម.ក. ក៏ដើរតួនាទីជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់ផងដែរ។ផ.ម.ក ដើរតួនាទីជាអ្នកជាត់ទាត់និងទូទាត់ ដើម្បីធានាបានថាអ្នកលក់នឹងទទួលបានការទូទាត់ហើយអ្នកទិញនឹងទទួលបានភាពជាម្ចាស់លើមូលបត្រកម្មសិទ្ធ។

#### ៤.១.២.៣.ប្រតិបត្តិកររក្សាទុកមូលបត្រ

ប្រតិបត្តិកររក្សាទុកមូលបត្រ សំដៅដល់កន្លែងសម្រាប់ដាក់ផ្ញើរមូលបត្រ ដែលបានជួញដូររួច រវាងវិនិយោគិន និងវិនិយោគិន។ រាល់មូលបត្រដែលជួញដូររួចហើយទាំងអស់ត្រូវបានគេរក្សារទុកក្នុងប្រព័ន្ធអេឡិចត្រូនិចយ៉ាងមានប្រសិទ្ធភាព។

### ៤.១.៣. អន្តរការីមូលបត្រ

#### ៤.១.៣.១. ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយសម្របសម្រួល និងសហការជាមួយសមាជិកក្រុមការងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារដែលពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការចុះបញ្ជីទាំងស្រុង រួមទាំងតំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ។ យោងទៅតាមប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ តួនាទីរបស់ក្រុមហ៊ុនធានាទិញមូលបត្រ រួមមាន៖

- ទិញមូលបត្រទាំងអស់ ឬទិញមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ក្នុងគោលបំណងទៅចែកចាយបន្ត។

- ផ្តល់ប្រឹក្សាសំខាន់ទៅលើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាការដាក់តម្លៃមូលបត្រ ការកំណត់ទំហំទឹកប្រាក់និងចំនួនមូលបត្រនៃសំណើរបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈជាដើម។
- ទិញមូលបត្រដែលលក់មិនអស់ ក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។
- រៀបចំនូវដំណើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយ ឫចូលរួមដោយផ្ទាល់ ឫមិនផ្ទាល់ក្នុងដំណើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

❖ ក្រុមហ៊ុនធានាទិញមូលបត្រ( Securities Underwriter )នៅក្នុងទីផ្សារមូលបត្រកម្ពុជារួមមាន៖

- ក្រុមហ៊ុន យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (Yuanta Securities Cambodia Plc)
- ក្រុមហ៊ុនអ អេស ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក. (RHB Indochina Securities Plc)
- ក្រុមហ៊ុនកាណា ស៊ីឃ្យូរីធី អិលឌីធី (Cana Securities Ltd)
- ក្រុមហ៊ុន កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (Campu Securities Plc)
- ក្រុមហ៊ុនអេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរិធី(SBI Royal Securities Plc)
- ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (Phnom Penh Securities Plc)

#### ៤.១.៣.២. ក្រុមហ៊ុនពាណិជ្ជករមូលបត្រ

ក្រុមហ៊ុនពាណិជ្ជករមូលបត្រ អាចធ្វើការជួញដូរនូវមូលបត្រក្នុងទីផ្សារមូលបត្របាន ហេតុដូចនេះហើយ ទើបតម្រូវឲ្យពាណិជ្ជករមូលបត្រ ត្រូវមានគណនីជួញដូរផ្ទាល់ខ្លួនសម្រាប់ជួញដូរមូលបត្រ។ ក្នុងការជួញដូរនេះ ក្រុមពាណិជ្ជករមូលបត្រអាចទទួលបានផលចំណេញពីមូលបត្រដែលជួញដូរ ហើយក៏អាចរងនូវហានិភ័យខាតបង់ផងដែរ។[២៣] បច្ចុប្បន្នក្រុមហ៊ុនពាណិជ្ជករមូលបត្រនៅកម្ពុជាមានតែក្រុមហ៊ុន ហ្គោលដែន ហ្វ៍រឈូន (ខេមបូឌា) ភីអិលស៊ី តែមួយគត់ប៉ុណ្ណោះ។

#### ៤.១.៣.៣. ក្រុមហ៊ុនជើងសារមូលបត្រ

ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ (B r o k e r ) ជាឈ្មួញកណ្តាលដែលមានតួនាទី ជួយសម្រួលដល់កិច្ចការជួញដូរមូលបត្រ រវាងពាណិជ្ជករ ឫអ្នកដែលមានបំណងចង់ទិញមូលបត្រពីផ្សារមូលបត្រកម្ពុជា តាមរយៈការផ្តល់នូវព័ត៌មាន និងការផ្គូផ្គង បញ្ជាទិញលក់។តួនាទីរបស់ឈ្មួញជើងសារមូលបត្រមានដូចជា ផ្តល់សេវាក្នុងការទិញលក់មូលបត្រជូនអតិថិជននិងផ្តល់សេវាកម្មប្រឹក្សាក្នុងការធ្វើវិនិយោគ ជាដើម។

[២៣] ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ លេខ ០០៩ គ.ម.ក.១៩ វិច្ឆិការ ២០០៩

❖ ក្រុមហ៊ុនឈ្មួញជើងសារនៅកម្ពុជាមានចំនួន៤៖

- ក្រុមហ៊ុន ខេមបូឌា វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី
- ក្រុមហ៊ុន អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី
- ក្រុមហ៊ុនខេប ស៊ីឃ្យូរីធី លីមីតធីត
- ក្រុមហ៊ុន ភីភី លីង ស៊ីឃ្យូរិធី ឯ.ក

#### ៤.១.៣.៤. ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ

ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ មានតួនាទីជាអ្នកផ្តល់ប្រឹក្សារ អំពីការវិនិយោគលើមូលបត្រ និងការបោះផ្សាយ ការវិភាគនៃការវិនិយោគលើមូលបត្រ សម្រាប់វិនិយោគិនសារធារណៈ។ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ មានតែមួយគត់គឺ ក្រុមហ៊ុន អេ ភី អិម (ខេមបូឌា) ស៊ីឃ្យូរិធី ឯ.ក ដែលមានទីតាំងនៅ អគារវីត្រាស់ ប្លុកអេ ផ្លូវលេខ ១៦៧ សង្កាត់វាលវង់ ខណ្ឌប្រាំពីរមករា។

### ៤.១.៤. ភ្នាក់ងារក្រុមហ៊ុនមូលបត្រ

#### ៤.១.៤.១. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ភ្នាក់ងារទូទាត់សាច់ប្រាក់ ពាក់ព័ន្ធនឹងមូលបត្រ គឺជាធនាគារពាណិជ្ជដែលធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រជូនអតិថិជនរបស់ខ្លួន ដោយសំដៅដល់ការគ្រប់គ្រង និងការធានាឲ្យបានថាវិនិយោគិនដែលជាអ្នកលក់ នឹងទទួលបាននូវការទូទាត់ជាសាច់ប្រាក់ ជាថ្នូរនឹងការផ្ទេរនូវមូលបត្រកម្មសិទ្ធដល់អ្នកទិញវិញ។ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ រួមមាន៖

- ធនាគារអេស៊ីលីដា ភីអិលស៊ី
- ធនាគារវិនិយោគ និងអភិវឌ្ឍន៍កម្ពុជា ភីអិលស៊ី
- ធនាគារកាណាឌីយ៉ា
- ធនាគារកម្ពុជាសាធារណៈ ភីអិលស៊ី

#### ៤.១.៤.២. ភ្នាក់ងារបញ្ជីការមូលបត្រ ចុះបញ្ជីផ្ទេរមូលបត្រ និងទូទាត់មូលបត្រ

➢ **ភ្នាក់ងារបញ្ជីការមូលបត្រ៖** មានតួនាទីគ្រប់គ្រងនូវដំណើការបរិវិសកម្ម បែងចែកមូលបត្រឲ្យបានត្រឹមត្រូវ កត់ត្រាបញ្ជីកម្មសិទ្ធមូលបត្រ ធ្វើរបាយការណ៍ឲ្យក្រុមហ៊ុនបោះផ្សាយ និង ន.ម.ក. ស្តីពីការបញ្ចប់ដំណើរការបរិវិសកម្ម និងជូនដំណឹងដល់កម្មសិទ្ធករមូលបត្រជាដើម។

➢ **ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ៖** មានតួនាទី រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធករមូលបត្រ ធ្វើរបាយការណ៍ទាក់ទងទៅនឹងការផ្លាស់ប្តូរកម្មសិទ្ធ បញ្ជូនរបាយការណ៍និងពត៌មានផ្សេងៗរួមមានការបែងចែកភាគលាភ ការបង់ការប្រាក់និងសេវាពាក់ព័ន្ធផ្សេងៗ។

➢ **ភ្នាក់ងារទូទាត់មូលបត្រ៖** ដើរតួនាទីជាអ្នកទូទាត់ភាគលាភ ការប្រាក់និងប្រាក់ដើម ជាដើម ទៅតាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ក្រោយពេលធ្វើការទូទាត់រួចហើយ ភ្នាក់ងារទូទាត់មូលបត្រត្រូវ ធ្វើការទូទាត់ជូនកម្មសិទ្ធករនិងភាគីពាក់ព័ន្ធ និងជាអ្នកបញ្ជូនពត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬពត៌មានផ្សេងៗទៀតដល់ កម្មសិទ្ធករមូលបត្រ ក្រុមហ៊ុនបោះផ្សាយ និងន.ម.ក.។ ភ្នាក់ងារបញ្ជីការមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់មូលបត្រ មានដូចជា៖

- ធនាគារអេស៊ីលីដា ភីអិលស៊ី
- ក្រុមហ៊ុន ត្រាយខ័រ ស៊ីឃ្យូរីធី ស៊ីវីល ភីអិលស៊ី
- ក្រុមហ៊ុនភ្នំពេញ ស៊ីឃ្យូរិធី ភីអិលស៊ី

### ៤.១.៥. វិនិយោគិន

វិនិយោគិន សំដៅទៅលើសាធារណៈជននៅក្នុងប្រទេសកម្ពុជាទាំងអស់ រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធទិញ លក់មូលបត្រដែលបោះលក់ជាសារធារណៈនៅក្នុងប្រទេសកម្ពុជា ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬជានីតិបុគ្គលប្រតិស្រុត ដែលមិនមានជាសហការី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតឬជានីតិបុគ្គលប្រតិស្រុតនោះ។

## ៤.២.លក្ខណៈវិនិច្ឆ័យសម្រាប់ក្រុមហ៊ុនបោះផ្សាយមូលបត្រ

### ៤.២.១. លក្ខខណ្ឌតម្រូវជាតួលេខ

**ក.លក្ខខណ្ឌសម្រាប់ទីផ្សារគោល**

➢ ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០,០០០,០០០,០០០ (សាមសិបពាន់លាន)រៀលគិតត្រឹមថ្ងៃស្នើសុំចុះបញ្ជីនៅផ.ម.ក។

➢ ត្រូវមានប្រាក់ចំណេញសុទ្ធចំនួនយ៉ាងតិចចំនួន ២,០០០,០០០,០០០ (ពីរពាន់លាន) រៀលសម្រាប់រយៈពេលពីឆ្នាំចុងក្រោយ។

➢ ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតតិចជាង ១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី១០ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច២០០នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ ន.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក។

➢ ភាគហ៊ុនមានសិទ្ធបោះឆ្នោតរបស់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតតិចជាង ១% ត្រូវមានចំនួនសរុបយ៉ាងតិច ៧%នៃចំនួនភាគហ៊ុនមានសិទ្ធបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ ន.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក។

**ខ.លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន**

- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២,០០០,០០០,០០០ (ពីរពាន់លាន)រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅផ.ម.ក។
- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយដូចខាងក្រោម៖
  - ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ
  - ត្រូវមានលំហូរសាច់ប្រាក់ មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ភាគរយ។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតតិចជាង ១% ដែលកាន់កាប់ភាគហ៊ុនចាប់ពី១០ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច១០០នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ ន.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក។
- ភាគហ៊ុនមានសិទ្ធបោះឆ្នោតរបស់ភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតតិចជាង ១% ត្រូវមានចំនួនសរុបយ៉ាងតិច ១០%នៃចំនួនភាគហ៊ុនមានសិទ្ធបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ ន.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក។

### ៤.២.២. លក្ខខណ្ឌតម្រូវមិនមែនជាតួរលេខ

- **ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោត៖** មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតច្រើនជាងគេ ក្នុងរយៈពេលមួយឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីជាផ្លូវការ។
- **ការរក្សាទុកមូលបត្រ៖** មូលបត្រទាំងអស់ដែលបានបោះផ្សាយត្រូវ ដាក់ផ្ញើរនៅប្រតិបត្តិកររក្សាទុកមូលបត្រនៃផ្សារមូលបត្រកម្ពុជា។
- **ចំនួនភាគហ៊ុន៖** ១ឆ្នាំសម្រាប់ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោត មានចំនួនច្រើនលើសលប់(អនុញ្ញាតិឲ្យលក់ភាគហ៊ុនក្នុងកម្រិត ៥០% សម្រាប់រយៈពេល៦ខែចុងក្រោយ)។ ៦ខែទៀត សម្រាប់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចាប់ពី១៥% និងភាគហ៊ុនិកយុទ្ធសាស្ត្រ។

### ៤.២.៣. អភិបាលកិច្ចសាជីវកម្ម

ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធជាសាធារណៈ ត្រូវតែអនុវត្តតាមលក្ខខណ្ឌ អភិបាលកិច្ចសាជីវកម្មដែលបានកំណត់ដោយ និយ័តករមូលបត្រកម្ពុជាដូចមានខាងក្រោម៖

**ក.ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត**

- ត្រូវមានក្រុមប្រឹក្សាភិបាល ពី៥ ទៅ១៥នាក់។
- ត្រូវមានអភិបានឯករាជ្យ ច្រើនជាងឬស្មើ១ភាគ៥នៃអភិបាលសរុប។
- ប្រសិនបើអភិបាលឯករាជជាជនបរទេស ត្រូវតែមានបទពិសោធន៍ការងារក្នុងប្រទេសកម្ពុជាច្រើនជាងឬស្មើនឹង៦ខែ។

**ខ.សហគ្រាសសាធារណៈ**

- ត្រូវមានក្រុមប្រឹក្សាភិបាលច្រើនជាងឬស្មើ ៧នាក់ ។
- ត្រូមានអភិបាលឯករាជ្យ យ៉ាងតិច១នាក់។
- អភិបាលមិនប្រតិបត្តិ (តំណាងឲ្យភាគហ៊ុននិកឯកជន) យ៉ាងតិច១នាក់។

**គ.គណកម្មាធិការនៃក្រុមប្រឹក្សារភិបាល**

- គណកម្មាធិការសវនកម្ម។
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ សម្រាប់ទ្រព្យសកម្ម ច្រើនជាងឬស្មើនឹង២០០ពាន់លានរៀល
- គណៈកម្មាធិការតែងតាំង ។
- ក្រុមប្រឹក្សាភិបាលអាចពិចារណាបង្កើត គណៈកម្មាធិការដ៏ទៃទៀត ប្រសិនបើចាំបាច់និងតាមការស្នើសុំរបស់ន.ម.ក។

### ៤.២.៤.របាយការណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុនដែលចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្រ្ត (Historical Financial Statement) និង/ឬ របាយការណ៍ប្រវត្តិសាស្រ្តរួម(Consolidated Historical Financial Statement) រយៈពេលពីឆ្នាំ នៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេលមួយឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយសម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្រមតាមច្បាប់ និងបទបញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។ នៅក្នុងករណីក្រុមហ៊ុនដាក់ពាក្យស្នើសុំ ដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសទ្ធជាសាធារណៈ នៅក្រោយរយៈពេល ៤៥ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស ក្រុមហ៊ុនដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

### ៤.២.៥. ឯកសារផ្តល់ពត៌មាន

ត្រូវមានឯកសារផ្តល់ពត៌មានដូចកំណត់ខាងក្រោមះ

- ពត៌មានទូទៅពាក់ព័ន្ធនឹងសំណើរបោះផ្សាយ

- ពត៌មានស្តីពីកត្តាហានិភ័យ
- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយមូលបត្រកម្មសិទ្ធជាសាធារណៈ
- ផែនការវិនិយោគ
- ការពិពណ៌នាអំពីធុរកិច្ច
- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការនិងហិរញ្ញវត្ថុ
- ការពិពណ៌អំពីអចលកម្មរូបិយរបស់ក្រុមហ៊ុនបោះផ្សាយ
- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ
- ពត៌មានពាក់ព័ន្ធនឹង អភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក
- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់
- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ
- ប្រាក់បំណាច់ ឬភាគលាភសម្រាប់អភិបាល និងបុគ្គិកជាន់ខ្ពស់
- សិទ្ធទិញមូលបត្រកម្មសិទ្ធដែលផ្តល់ទៅឲ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិក
- ប្រតិបត្តិការណ៍ជាមួយនឹងអភិបាល និងភាគហ៊ុនិក
- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុមមួយឯកតានៃមូលបត្រកម្មសិទ្ធ
- កម្មសិទ្ធនៃមូលបត្រកម្មសិទ្ធរបស់ក្រុមហ៊ុនបោះផ្សាយ
- ការដាក់តម្លៃមូលបត្រកម្មសិទ្ធដើម្បីធ្វើសំណើលក់
- សិទ្ធរបស់កម្មសិទ្ធករលើមូលបត្រកម្មសិទ្ធដែលធ្វើសំណើរលក់
- ពត៌មានហិរញ្ញវត្ថុប្រវត្តិសាស្រ្ត និង/ឬពត៌មានហិរញ្ញវត្ថុប្រវត្តិសាស្រ្តរួម

## ៤.៣.ដំណាក់កាលនៃការធ្វើIPO

### ៤.៣.១. ការរៀបចំខ្លួនរបស់ក្រុមហ៊ុនបោះផ្សាយ

#### ៤.៣.១.១.ការដាក់លិខិតសម្តែខឆន្ទៈបោះផ្សាយលក់មូលបត្រ

បុគ្គលដែលមានបំណងចង់ បោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ អាចធ្វើការដាក់លិខិតសម្តែងឆន្ទៈ បោះផ្សាយមូលបត្រកម្មសិទ្ធជាសាធារណៈជូន ន.ម.ក ដែលលិខិតមានខ្លឹមសារ៣ចំណុចដូចបង្ហាញខាងក្រោមៈ

- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូង(Purpose of IPO)
- គម្រោងពេលរំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង (Expected IPO Timetable)

- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវីឬក្រុមមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

### ៤.៣.១.២. ការជ្រើសរើស និងតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយ នៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រ ក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលអាជ្ញាប័ណ្ណពីន.ម.ក. ។ ក្រុមហ៊ុនធានាទិញមូលបត្រ ក៏អាចជាអ្នកផ្តល់យោបល់ ដល់ក្រុមហ៊ុនបោះផ្សាយ ពីការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដើម្បីបង្កើតជាក្រុមការងារបោះផ្សាយមូលបត្រផងដែរ។

### ៤.៣.១.៣. ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រ

សមាសភាពក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង ជាទូទៅរួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនមេធាវី ក្រុមហ៊ុនគណនេយ្យជំនាញ និងក្រុមហ៊ុនផ្តល់សេវា វាយតម្លៃ។ ក្រៅពីក្រុមការងារបោះផ្សាយលក់មូលបត្រ ក្រុមហ៊ុនក៏អាចស្នើសុំ ន.ម.ក. ដើម្បីជួយក្នុងដំណើរការបោះផ្សាយផងដែរ ដើម្បីប្រាកដថាក្រុមហ៊ុនទទួលបានពត៌មានគ្រប់គ្រាន់ ទាក់ទងទៅនឹងដំណើរការនៃការបោះផ្សាយ និងចុះបញ្ជីមូលបត្រ។ ក្រុមហ៊ុនក៏អាចទទួលបានពត៌មានលម្អិតអំពីក្រុមហ៊ុនដែលទទួលបានការទទួលស្គាល់ និងអាជ្ញាប័ណក្នុងដំណើរការចុះបញ្ជីតាមរយៈ គេហទំព័រផ្លូវការរបស់ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងនិយ័តករមូលបត្រកម្ពុជា។ ខាងក្រោមនេះគឺជាតួនាទី និងការទទួលខុសត្រូវមួយចំនួន របស់ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ៖

#### ក.ក្រុមហ៊ុនធានាទិញមូលបត្រ

ក្រុមហ៊ុនធានាទិញមូលបត្រ ដើរតួយ៉ាងសំខាន់ក្នុងការជួយសម្របសម្រួល និងសហការជាមួយសមាជិកក្រុមការងារបោះផ្សាយលក់មូលបត្រផ្សេងទៀត ក្នុងការរៀបចំឯកសារពាក់ព័ន្ធ និងត្រួតពិនិត្យដំណើរការចុះបញ្ជីទាំងស្រុង រួមទាំងដំណាក់កាលនៃការបំពេញកាតព្វកិច្ចតាមផ្លូវច្បាប់ផងដែរ ដែលតួនាទីរបស់ក្រុមហ៊ុនធានាទិញមូលបត្រទាំងនោះរួមមាន៖

- ផ្តល់ប្រឹក្សាសំខាន់ៗដូចជាការកំណត់ថ្លៃ ការកំណត់ទំហំបោះផ្សាយ និងកំណត់ពេលបោះផ្សាយ។
- ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ ឲ្យក្រុមហ៊ុនបោះផ្សាយលក់ដោយចូលរួមផ្ទាល់ឬមិនផ្ទាល់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ។

- រៀបចំឯកសារផ្តល់ព័ត៌មាន និងធ្វើរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់។
- ធានាទិញមូលបត្រដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង លើសពីនេះក្រុមហ៊ុនធានាទិញមូលបត្រ អាចណែនាំក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ពីការរៀបចំរចនាសម្ព័ន្ធ អភិបាលកិច្ចសាជីវកម្ម គោលនយោបាយ និងយន្តការដែលអនុញ្ញាតឲ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ធ្វើប្រតិបត្តិការធុរៈកិច្ចប្រកបដោយប្រសិទ្ធភាព និងអនុវត្តតាមបទបញ្ញត្តិពាក់ព័ន្ធក្រោយការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈជាលើកដំបូង។

**ខ. ក្រុមមេធាវី ឬមេធាវី**

ក្រុមមេធាវី ឬមេធាវី ជាអ្នកប្រឹក្សាយោបល់លើបញ្ហាផ្លូវច្បាប់ទាំងអស់ ដែលទាក់ទងទៅនឹងពាក្យស្នើសុំ និងឯកសារផ្តល់ព័ត៌មាន ដែលមានដូចជា ផ្តល់យោបល់ផ្នែកច្បាប់ក្នុងការរៀបចំកិច្ចសន្យាធានាទិញ និងផ្តល់យោបល់ជូនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រពីអភិបាលកិច្ចសាជីវកម្ម ជាពិសេសលើការពិនិត្យលើការបំពេញកាតព្វកិច្ចតាមច្បាប់របស់ក្រុមហ៊ុនដែលមានបំណងចុះបញ្ជី និងធ្វើការផ្ទៀងផ្ទាត់ឯកសារផ្សេងៗឲ្យមានត្រឹមត្រូវទៅតាមតម្រូវការរបស់ច្បាប់។

**គ. ក្រុមហ៊ុនគណនេយ្យជំនាញ**

ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដ៏ទៃទៀតដែលធ្វើធុរកិច្ចក្នុងវិស័យមូលបត្រ ត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញដែលមានការទទួលស្គាល់ដោយន.ម.ក. ។ក្រុមហ៊ុនគណនេយ្យជំនាញ នឹងជួយក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងព័ត៌មានតាមលក្ខខណ្ឌតម្រូវ ក្នុងឯកសារផ្តល់ព័ត៌មានរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អនុវត្តតាមស្តង់ដារបាយការណ៍ទាក់ទងនឹង ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ច្បាប់និងបទប្បញ្ញត្តិផ្សេងៗ រៀបចំរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនិងកិច្ចការគណនេយ្យ និងត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុក្នុងឯកសារផ្តល់ព័ត៌មានតាមការព្រមព្រៀង។

**ឃ. ក្រុមហ៊ុនវាយតម្លៃ**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ចាំបាច់ត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ ឬបុគ្គលវាយតម្លៃឯករាជ្យប្រសិនបើក្រុមហ៊ុនកាន់កាប់ ទ្រព្យសម្បត្តិ ដីធ្លី ឬបរិក្ខាដែលត្រូវវាយតម្លៃឡើងវិញ។ ក្រុមហ៊ុនវាយតម្លៃត្រូវ រៀបចំរបាយការណ៍វាយតម្លៃ ដែលជាផ្នែកមួយនៃដំណើរការចុះបញ្ជី។

**៤.៣.១.៤. ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់**

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយត្រូវឆ្លងកាត់ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ និងត្រូវប្រាកដថាគ្រប់ដំណាក់កាលទាំងអស់នៃការធ្វើ IPO ពិតជាត្រឹមត្រូវទៅតាមកាតព្វកិច្ចច្បាប់។ ការងារនេះត្រូវធ្វើឡើងដោយក្រុមការងារ បោះផ្សាយ

លក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូង (IPO Team) ដែលរួមមាន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ និងស្ថិតនៅក្រោមការដឹកនាំរបស់ ក្រុមហ៊ុនធានាទិញមូលបត្រ។

### ៤.៣.២. ការពិនិត្យលើលទ្ធភាពចុះបញ្ជី

ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅនិយ័តករមូលបត្រកម្ពុជា។

#### ៤.៣.២.១.ការដាក់ពាក្យស្នើសុំពិនិត្យលើលទ្ធភាពចុះបញ្ជី

ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់មកជាមួយឯកសារដូចខាងក្រោម មកកាន់និយ័តករមូលបត្រកម្ពុជា៖

១.ព័ត៌មានទូទៅ

- ឈ្មោះរបស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ ជាភាសាខ្មែរនិងអក្សរឡាតាំង។
- អាសយដ្ឋានរបស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ។
- កាលបរិច្ឆេទបង្កើតក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ។
- កម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ។
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។
- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធម៌ពាក់ព័ន្ធ។

២. ព័ត៌មានពីបុគ្គលតំណាងឲ្យក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ។

- អត្តសញ្ញាណបុគ្គលតំណាងនៃក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣. ព័ត៌មានអំពីភាគហ៊ុន

- អត្តសញ្ញាណភាគហ៊ុន។

៤.ព័ត៌មានពីស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន។

- ប្រភេទមូលបត្រកម្មសិទ្ធទាំងអស់របស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ។
- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។
- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ(បើមាន)។
- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មនិងដែលស្រមតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្តីពីការលក់មូលបត្រកម្មសិទ្ធជាសាធារណៈ។

៥.ព័ត៌មានពីស្ថានភាពអាជីវកម្មរបស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន៖

- ព័ត៌មានពីធុរកិច្ច និងអភិបាលកិច្ចល្អ។
- ព័ត៌មានពីហានិភ័យ។

៦. ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧.ពត៌មានផ្សេងៗទៀតដែលពាក់ព័ន្ធនិងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

**៤.៣.២.២. ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី**

អគ្គនាយកនៃ ន.ម.ក. ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការយល់ព្រម ឬមិនយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈជាលើកដំបូង និង ឯកសារផ្តល់ពត៌មានក្នុងរយៈពេល២ខែ គិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

ក្នុងករណី ន.ម.ក.បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ ន.ម.កត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឲ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រអាចស្នើសុំការបំភ្លឺពី ន.ម.ក។ ក្រុមហ៊ុនស្នើសុំចុះបញ្ជីដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក ន.ម.ក ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេចសារជាថ្មីម្តងទៀត។

អគ្គនាយកនៃ ន.ម.ក. អាចបដិសេធលើសំណើរបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយបាន ដោយផ្អែកលើមូលហេតុដូចខាងក្រោមៈ

- ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត និង ប្រកាស។
- ពត៌មានឬឯកសារដែលបានដាក់ជូន ន.ម.កមានលក្ខណៈក្លែងបន្លំ ឬនាំឲ្យយល់ខុស។
- ក្រុមហ៊ុនបោះផ្សាយស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ចប់ធុរកិច្ច ឬការរំលាយ។
- ការមិនអនុវត្តន៍តាមទាំងស្រុង ឬមួយផ្នែកនៃសេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឲ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។
- ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុននិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោញះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយៈ
  - មិនមានលក្ខណៈសម្បត្តិ និងអត្តចរិតល្អស្របតាមអនុក្រឹត
  - បានធ្វើឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត
  - ធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច
  - ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបាន។
  - ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាប័ណ្ណ ឬការអនុញ្ញាតិប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។
- ថ្នាក់ដឹកនាំជាន់ខ្ពស់ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនភាគច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខដំណែងទាំងនេះក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធននៅក្នុងឬក្រៅប្រទេសកម្ពុជា ក្នុងរយៈពេលប្រាំឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

- ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រាប់គ្រាន់ ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្តបាន។

### ៤.៣.៣. ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ

#### ៤.៣.៣.១.ការដាក់ពាក្យស្នើសុំបោះផ្សាយលក់ជាសាធារណៈ

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតិ ជាគោលការណ៍លើសំណើរសុំបោះផ្សាយ លក់មូលបត្រជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើរលក់ជាសាធារណៈបានបន្ទាប់ពី៖

- បានរៀបចំលក្ខខណ្ឌនៃសំណើរលក់ រួមទាំងការកំណត់ថ្លៃមូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។
- ទទួលបានការអនុញ្ញាតិលើលក្ខខណ្ឌលើសំណើរលក់មូលបត្រកម្មសិទ្ធជាសាធារណៈ។
- បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសាផ្តល់ពត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី ន.ម.ក។

#### ៤.៣.៣.២. ការកំណត់ថ្លៃមូលបត្រ

ការកំណត់ថ្លៃមូលបត្រដើម្បីធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ធ្វើទ្បើងតាមរយៈវិធីសាស្ត្រ ប៊ុក បៀលឌីង(Book Building)។ ប៊ុក បៀលឌីង(Book Building) គឺជាដំណើរការស្ទាបស្ទង់ថ្លៃដើម្បីកំណត់ថ្លៃធ្វើសំណើរលក់ជាសាធារណៈជាលើកដំបូង (Initial Public Offering)។ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយ ពីក្រុមហ៊ុនធានាទិញមូលបត្រ ដែលបានធ្វើការកំណត់ចន្លោះថ្លៃមួយ ដើម្បីដាក់ស្នើឲ្យវិនិយោគិនសាធារណៈ ដាក់ថ្លៃទិញមូលបត្រនៅក្នុងចន្លោះថ្លៃដែលបានកំណត់ទុករួចជាស្រេចនោះ។ វិនិយោគិនទាំងឡាយដែលមានបំណងចង់ចូលរួមក្នុងវគ្គ ប៊ុកបៀលឌីង(ធ្វើទ្បើងនៅទីផ្សារដំបូង) នេះត្រូវទៅកាន់ក្រុមហ៊ុនធានាទិញ ឬក្រុមហ៊ុនមូលបត្រដែលពាក់ព័ន្ធ ហើយបំពេញពាក្យស្នើសុំចូលរួមធ្វើ ប៊ុកបៀលឌីង ដោយត្រូវបញ្ជាក់ពីថ្លៃមូលបត្រ និងបរិមាណមូលបត្រដែលខ្លួនចង់ទិញ និងតម្រូវឲ្យតម្កល់ប្រាក់១០% នៃតម្លៃភាគហ៊ុនដែលខ្លួនចង់ទិញ។ នៅក្នុងដំណាក់កាលធ្វើ ប៊ុកបៀលឌីងនេះ ដើម្បីជម្រុញឲ្យមានវិនិយោគិនចូលរួមយ៉ាងសកម្មនោះ ចំនួនមូលបត្រដែលដាក់លក់មានដល់ទៅ ៧០% នៃមូលបត្រសរុប ។ ចំណែក៣០%ទៀត គឺត្រូវបានលែបម្រុងទុក សម្រាប់ការលក់ជូនវិនិយោគិន ដែលមិនបានចូលរួមក្នុងវគ្គ ប៊ុកបៀលឌីង ឬក៏មិនទទួលបានជោគជ័យនៅក្នុងការ ធ្វើប៊ុកបៀលឌីង។

ក្រោយពេលបញ្ចប់ដំណាក់កាលធ្វើប៊ុកបៀលឌីងនេះ ក្រុមហ៊ុនបោះផ្សាយដែលមានជំនួយពីក្រុមហ៊ុនធានាទិញ ត្រូវធ្វើការកំណត់ថ្លៃIPO តាមវិធីរកមធ្យមភាគលើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រ។ រយៈពេលប្រហែលពីសប្តាហ៍ក្រោយ ក្រុមហ៊ុនបោះផ្សាយនឹងប្រកាសលទ្ធផល ប៊ុកបៀលឌីង ជាសាធារណៈ ដែលនៅក្នុងនោះមានការបង្ហាញពីថ្លៃ IPO ។ ក្រុមហ៊ុននឹងធ្វើការជូនដំណឹង ដោយបញ្ជាក់ពីវិនិយោគិនដែលទទួលបានជោគជ័យ ក្នុងដំណាក់កាលប៊ុនបៀលឌីងនេះ។ វិនិយោគិនដែលទទួលបានជោគជ័យ គឺសំដៅដល់វិនិយោគិន ដែលដាក់ថ្លៃ

ខ្ពស់ជាង ឬស្មើថ្លៃមូលបត្រ ដែលត្រូវបានកំណត់ដើម្បីធ្វើសំណើរលក់ ឬថ្លៃIPO ចំណែកវិនិយោគិនដែលមិនបាន ទទួលជោគជ័យ ហើយមិនចង់បន្តទៅដំណាក់កាលបន្តទៀត (ដំណាក់កាលបរិវិសកម្ម) អាចមានសិទ្ធដកប្រាក់របស់ខ្លួន១០%មកវិញបាន។

### ៤.៣.៣.៣. ការស្នើសុំបញ្ជាក់ការដាក់ថ្លៃលក់មូលបត្រ

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រ តាមរយៈការធ្វើប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាលើកដំបូង ដោយមានជំនួញពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនបោះផ្សាយមូលបតត្រកម្ពុជា។ ក្រុមហ៊ុនផ្សាយមូលបត្រកម្ពុជាត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រ តាមរយៈការធ្វើប៊ុកបៀលឌីង អាចធ្វើការដាក់លក់នៅលើទីផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុង ប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

### ៤.៣.៣.៤. ការស្នើសុំការអនុញ្ញាតិលើសំណើរលក់មូលបត្រ

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃ តាមរយៈការធ្វើប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពី ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើរលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ពត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន ន.ម.ក. ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

### ៤.៣.៣.៥. ការធ្វើបរិវិសកម្ម

បន្ទាប់ពីទទួលបានការអនុញ្ញាតិ និងចុះបញ្ជីឯកសារផ្តល់ពត៌មាន ក្រោមជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមឡើងនៅក្នុងកំឡុងពេលដែលឯកសារផ្តល់ពត៌មាននៅមានសុពលភាព ។ ការធ្វើបរិវិសកម្ម ត្រូវកើតឡើងតាមរយៈ ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី ន.ម.ក.។ ក្រុមហ៊ុនមូលបត្រ ត្រូវតែរក្សាទុកប្រាក់ ដែលទទួលបានពីការធ្វើបរិវិសកម្ម ក្នុងគណនីដោយឡែក នៅធនាគារពាណិជ្ជ ហើយចំនួននិងបញ្ជីឈ្មោះ របស់អ្នកធ្វើបរិវិសកម្ម ត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជីការមូលបត្រ។ ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ ន.ម.ក។ ការធ្វើបរិវិសកម្មនិមួយៗ ត្រូវបានចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកវិនិយោគដែលបានធ្វើបរិវិសកម្មបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។

វិនិយោគិនដែលទទួលបានជោគជ័យក្នុងវគ្គ ប៊ុកបៀលឌីង ក៏អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធ លើសពីចំនួនដែលបានដាក់ក្នុងពាក្យស្នើសុំចូលរួមប៊ុនបៀលឌីង ដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីឲ្យគ្រប់ទៅ

តាមទំហំនៃបរិវិសកម្មមូលបត្រកម្មសិទ្ធដែលបានធ្វើ។ វិនិយោគិនដែលមិនបានចូលរួមក្នុងដំណើរប៊ុកបៀលឌីង អាចចូលរួមធ្វើបរិវិសកម្មបាន ដោយត្រូវបំពេញពាក្យស្នើសុំធ្វើបរិវិសកម្ម និងបញ្ជាក់ពីបរិមាណដែលខ្លួនចង់ទិញ ព្រមទាំងត្រូវដាក់តម្កល់ប្រាក់ចំនួន១០០% នៃតម្លៃភាគហ៊ុនដែលខ្លួនចង់ទិញផងដែរ ហើយក្នុងដំណាក់កាលនេះវិនិយោគិនអាចស្នើសុំទិញចាប់ពី១០០ភាគហ៊ុនឡើងទៅ។

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ក្នុងករណីមូលបត្រកម្មសិទ្ធធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ របស់ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើបរិវិសកម្មមូលបត្រដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត ឲ្យទៅក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។

#### ៤.៣.៣.៦. ការរាយការណ៍ពីលទ្ធផលធ្វើបរិវិសកម្ម

នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ ភ្លាមទៅកាន់ ន.ម.ក.។ក្រុមហ៊ុនបោះផ្សាយ ត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធជាសាធារណៈ ដែលត្រូវធ្វើឡើងក្នុងទម្រង់មួយដែលកំណត់ដោយ ន.ម.ក. ដោយត្រូវភ្ជាប់មកជាមួយនូវ លិខិតជាលាយលក្ខណៈអក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

### ៤.៣.៤. ការចុះបញ្ជីជាផ្លូវការនៅ ន.ម.ក

#### ៤.៣.៤.១. ការដាក់ពាក្យចុះបញ្ជីជាផ្លូវការ

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញ ផ.ម.ក. ត្រូវពិនិត្យនិងចុះបញ្ជីលក់ជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ។ មុននឹងត្រូវបានអនុញ្ញាតិ ឲ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការ នៅ ផ.ម.ក ក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀង ចុះបញ្ជីលក់មូលបត្រ តាមគំរូដែលទទួលបានការអនុញ្ញាតពី ន.ម.ក។ រាល់ឯកសារដែលពាក់ព័ន្ធនឹង ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ មិនត្រូវបានប្រគល់ជូនក្រុមហ៊ុនស្នើសុំចុះបញ្ជីលក់មូលបត្រវិញនោះទេ ទោះបីជាពាក្យស្នើសុំនោះត្រូវបានបដិសេធក៏ដោយ។

#### ៤.៣.៤.១. ការផ្តល់ការអនុញ្ញាតិនៃការចុះបញ្ជី និងការជួញដូរជាផ្លូវការ

ក្រោយពេល ត្រួតពិនិត្យត្រឹមត្រូវទៅតាមនីតិវិធីនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង ន.ម.ក និងផ្តល់ការអនុញ្ញាត្តិ ឲ្យក្រុមហ៊ុនចុះបញ្ជី បោះផ្សាយលក់មូលបត្រកម្មសិទ្ធ និងដាក់ឲ្យជួញដូរជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

## ៤.៤. ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

### ៤.៤.១. កាតព្វកិច្ចនិងនីតិវិធីផ្តល់ព័ត៌មាន

បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ជូន ជ.ម.ក. ឲ្យទាន់ពេលវេលានូវឯកសារផ្តល់ព័ត៌មានជាប្រចាំ និងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានរបស់ខ្លួន ដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ៤.៤.២. កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យាដូចខាងក្រោម៖

- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ មិនត្រូវលក់ឬផ្ទេរ ភាគហ៊ុនដែលខ្លួនកាន់កាប់ យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ខែដំបូង នៃរយៈពេលមួយឆ្នាំ។ សម្រាប់រយៈពេលដែលនៅសល់ (៦ខែទៀត) ភាគហ៊ុនិកនេះអាច ធ្វើការលក់ភាគហ៊ុនរបស់ខ្លួន ក្នុងកម្រិតអតិបរមា ៥០%ភាគរយ នៃភាគហ៊ុនដែលខ្លួនកាន់កាប់។
- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោត ចាប់ពី១៥% និងភាគហ៊ុនិកយុទ្ធសាស្ត្រមិនត្រូវលក់ឬផ្ទេរ ភាគហ៊ុនដែលខ្លួនកាន់កាប់ យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ខែ។

### ៤.៤.៣. ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរសារជាថ្មី

ផ្សារមូលបត្រ អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម៖

- ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុងមានការក្លែងបន្លំ។
- ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញ ពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ។
- ករណីមានការបំបែក ឬបង្រួមមូលបត្រកម្មសិទ្ធ ឬតាមសំណើររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

### ៤.៤.៤. ការផ្លាស់ប្តូរទីផ្សារចុះបញ្ជី

បុគ្គលចុះបញ្ជីលក់មូលបត្រ ដែលមានបំណងផ្លាស់ប្តូរទីផ្សារចុះបញ្ជីពីទីផ្សារកំណើន ទៅទីផ្សារគោលត្រូវបំពេញតាមលក្ខខណ្ឌចុះបញ្ជី នៃទីផ្សារដែលបុគ្គលចុះបញ្ជីមានបំណងផ្ទេរទៅ និងត្រូវដាក់ពាក្យស្នើសុំផ្ទេរទីផ្សារទៅកាន់ជ.ម.ក។

## ៤.៥. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

### ៤.៥.១. ថ្លៃសេវាសម្រាប់ពិនិត្យលើលទ្ធភាពចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវបង់ថ្លៃសេវា ជ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រចំនួន ៤,000,000 (បួនលាន)រៀល សម្រាប់ទីផ្សារគោល និង ២,000,000 (លាន)រៀល សម្រាប់ទីផ្សារកំណើន។

### ៤.៥.២. ថ្លៃសេវាសម្រាប់ចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ពី ០៛ ដល់ ១២,០០០,០០០,០០០៛ | ១០,០០០,០០០៛ |
| ពី ១២,០០០,០០០,០០០ ដល់ ៤០,០០០,០០០,០០០៛ | 0.0៣0% |
| ពី ៤០,០០០០,០០០,០០០ ដល់ ២០០,០០០,០០០,០០០៛ | 0.0២៥% |
| ពី ២០០,០០០,០០០,០០០៛ ដល់ ៤០០,០០០,០០០,០០០៛ | 0.0១៥% |
| លើសពី ៤០០,០០០,០០០,០០០៛ | 0.0១0% |

តារាងទី៨. ថ្លៃសេវាបម្រាប់ចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវា ផ.ម.ក សម្រាប់ការចុះបញ្ជីលក់មូលបត្រចំនួន ៤,០០០,០០០ (បួនលាន) រៀល (ថ្លៃអប្បបរមា) ឬចំនួន 0.0២៥% (សូន្យចុចសូន្យម្ភៃប្រាំភាគរយ)នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈដោយយកចំនួនណាមួយធំជាងគេ។

### ៤.៥.៣. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម៖

| មូលធនូបនីយកម្មទីផ្សារសរុប | ថ្លៃសេវា |
|---|---|
| ពី ០៛ ដល់ ១២,០០០,០០០,០០០៛ | ៣,០០០,០០០៛ |
| ពី ១២,០០០,០០០,០០០៛ ដល់៤០,០០០,០០០,០០០៛ | 0.0២0% |
| ពី ៤០,០០០,០០០,០០០៛ ដល់ ២០០,០០០,០០០៛ | 0.0១៥% |
| លើសពី ២០០,០០០,០០០,០០០៛ | 0.00៥% |

តារាងទី៩. ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធប្រចាំឆ្នាំ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤,០០០,០០០(បួនលានរៀល) (ថ្លៃសេវាប្រចាំឆ្នាំអប្បបរមា) ឬចំនួន0.០១៥% (សូន្យចុចសូន្យដប់ប្រាំភាគរយ) នៃមូលធនបូនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយធំជាងគេ។

## ៤.៧.ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយនៃដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ លើប្រធានបទស្តីពីដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនៅកម្ពុជា រួចមកក្រុមនាងខ្ញុំបានមើលឃើញពីចំណុចល្អជាច្រើននៃដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ តែទោះបីជាយ៉ាងណាក៏ដោយក៏នៅតែមានចំណុចខ្វះខាតមួយចំនួនផងដែរ។ ខាងក្រោមនេះជាការយល់ឃើញ និងជាការវិភាគរបស់ក្រុមនាងខ្ញុំផ្ទាល់ ដោយផ្អែកតាមរយៈទិន្នន័យដែលបានបង្ហាញដូចខាងលើ។

### ៤.៧.១. ចំណុចខ្លាំង

- មានការរៀបចំបង្កើត និយ័តករមូលបត្រកម្ពុជាឡើង ដើម្បីធានាឲ្យបាន នូវការជួញដូរមូលបត្រមួយដែលប្រកបទៅដោយ យុត្តិធម៌ តម្លាភាព មានសណ្តាប់ធ្នាប់ និងមានភាពត្រឹមត្រូវ នៅក្នុងវិស័យមូលបត្រកម្ពុជា ។
- មានការបង្កើត ក្រុមហ៊ុនទីផ្សារមូលបត្រឡើង ដោយមានការចូលរួមភាគហ៊ុនពីក្រុមហ៊ុនមូលបត្រគូរ៉េ ដើម្បីជួយសម្រួលដល់ការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ និងដើម្បីឲ្យប្រតិបត្តិការក្នុងទីផ្សារមានលក្ខណៈច្បាស់លាស់ និងកាន់តែងាយស្រួលយល់។
- ការដាក់ឲ្យអនុវត្តនូវច្បាប់ បទបញ្ញត្តិ វិធានការ និងប្រកាសដែលទាក់ទងនឹងវិស័យមូលបត្រ យ៉ាងមានប្រសិទ្ធភាព។
- មានការដាក់បង្ហាញនូវព័ត៌មានទាក់ទងនឹងមូលបត្រ ការបោះផ្សាយលក់មូលបត្រជាលើកដំបូង អ្នកចូលរួមក្នុងទីផ្សារ និងទិន្ន័យទីផ្សារ តាមរយៈគេហទំព័របានយ៉ាងក្បោះក្បាយ ដែលជាហេតុ បង្ករភាពងាយស្រួលដល់វិនិយោគិន ក៏ដូចជាមហាជនក្នុងការស្វែងរកព័ត៌មាន។
- មានការអនុវត្តនូវប្រព័ន្ធបច្ចេកទេសផ្សេងៗ ទាំងក្នុងដំណើរការបោះផ្សាយមូលបត្រ និងដំណើរការជួញដូរមូលបត្របានយ៉ាងល្អ។
- មានការរៀបចំឡើងនូវ សិក្ខាសាលាអប់រំ និងវគ្គបំប៉នខ្លីៗដើម្បីបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទាក់ទងនឹងវិស័យមូលបត្រ។

- មានកំណើននៃការ ចុះបញ្ជីរបស់ក្រុមហ៊ុនបោះផ្សាយនៅ និយ័តករមូលបត្រកម្ពុជា ក៏ដូចជាកំណើន នៃការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រជារៀងរាល់ឆមាស យ៉ាងគួឲ្យគាត់សម្គាល់។
- មានការចូលរួមយ៉ាងច្រើនពីវិនិយោគិន ទាំងក្នុងស្រុកនិងក្រៅស្រុក។
- បុគ្គលិកមានសមត្ថភាព ចំនេះដឹង ការទទួលខុសត្រូវប្រកបដោយសីលធម៌វិជ្ជាជីវៈខ្ពស់ ព្រមទាំងមានរចនាសម្ព័ន្ធមុខងារច្បាស់លាស់។
- បើកឲ្យមានកម្មវិធីប្រកួតប្រជែងដល់សិស្សនិស្សិត និងសាធារណៈជនក្នុងការអនុវត្តទិញលក់មូលបត្រនៅលើទីផ្សារ ក្នុងគោលបំណងបញ្ជ្រាបពត៌មានឲ្យកាន់តែមានភាពទូលំទូលាយ។

### ៤.៧.២. ចំណុចខ្សោយ

ជាការពិតណាស់ ទោះបីជា ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈនៅកម្ពុជា មានចំណុចខ្លាំងជាច្រើនក៏ដោយ ក៏នៅតែមានចំណុចខ្វះខាតបន្តិចបន្តួច ជាក់ជាមិនខាន។ ខាងក្រោមនេះជាចំណុចខ្វះខាត បន្តិចបន្តួចដែលក្រុមនាងខ្ញុំបានសង្កេតឃើញៈ

- ជាក់ស្តែងចំណេះដឹងទាក់ទងនឹង វិស័យមូលបត្រនៅកម្ពុជារបស់សាធារណៈជន ក៏ដូចជាវិនិយោគិនក្នុងស្រុកនៅមានកម្រិតនៅឡើយ។
- ក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រនៅកម្ពុជានៅមានចំនួនតិចនៅឡើយ ដែលជាហេតុធ្វើឲ្យអ្នកវិនិយោគមានជម្រើសតិចក្នុងការវិនិយោគ។
- ទំហំនៃការបោះផ្សាយ និងជួញដូរមូលបត្រនៅមានកម្រិតទាបនៅឡើយ បើទោះបីជាមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំក៏ដោយ។
- កង្វះទំនុកចិត្តពីសំណាក់សាធារណៈជន និងវិនិយោគិន ចំពោះក្រុមហ៊ុនចុះបញ្ជី។

# សេចក្តីសន្និដ្ឋាន

# និង

# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង ការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើ ការសិក្សាស្រាវជ្រាវដែលស្តីអំពី ដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងនៅកម្ពុជា រួចមកយើងសង្កេតឃើញថា រាជរដ្ឋាភិបាលពិតជាមានការយកចិត្តទុកដាក់ខ្ពស់បំផុត ក្នុងការបង្កើត និងអភិវឌ្ឍវិស័យមូលបត្រកម្ពុជាឲ្យមានការរីកចម្រើន។ បើគិតមកដល់ពេលបច្ចុប្បន្ន វិស័យមូលបត្រទើបតែមានវត្តមាននៅកម្ពុជា រយៈពេលប្រមាណ១០ឆ្នាំតែប៉ុណ្ណោះ ក្នុងនោះរាជរដ្ឋាភិបានបានបង្កើតឲ្យមាន នូវនិយ័តករមូលបត្រកម្ពុជា និង ក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា ដែលជួយសម្រួលដល់ការបោះផ្សាយ និងជួញដូរមូលបត្រនៅលើទីផ្សារ។ បើគិតត្រឹមពាក់កណ្តាលឆ្នាំ២០២១នេះ មានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រកម្មសិទ្ធចំនួន ៧ដែលបានចុះបញ្ជីលក់មូលកម្មសិទ្ធនៅ ន.ម.ករួចរាល់ និងមានក្រុមហ៊ុន១ផ្សេងទៀតដែលកំពុងនឹងត្រៀមក្នុងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈផងដែរ និងមានក្រុមហ៊ុនចុះបញ្ជីលក់មូលបត្របំណុលចំនួន៦ផ្សេងទៀត។ យោងតាមរបាយការណ៍ស្ថិតិទីផ្សារមូលបត្រ ត្រីមាសទី១ឆ្នាំ២០២១ ចំនួនដងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងដែលត្រូវបានអនុញ្ញាតិមានចំនួន៧ដង និងការអនុញ្ញាតិឲ្យបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងបន្ថែមចំនួន១ដង ដែលសាច់ប្រាក់ប្រមូលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធទាំងពីនេះដោយគិតចាប់ពីឆ្នាំ២០១២ ត្រីមាសទី១ឆ្នាំ២០២១ មានចំនួន ៤៤៣,៧៧០,០២៤.៩៤០(រៀល) ឬស្មើនឹង ១១០,៨៤០,៤៥៦(ដុល្លារ)។

ម្យ៉ាងទៀតសម្រាប់ក្រុមហ៊ុន ដែលមានបំណងចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈលើកដំបូងនៅ ន.ម.ក ត្រូវតែជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬជានីតិបុគ្គលប្រតិស្រុតដែលទទួលបានការអនុញ្ញាតិពីនិយ័តករមូលបត្រកម្ពុជា ក្នុងការបោះផ្សាយលក់មូលបត្រ ត្រឹមត្រូវទៅតាមផ្លូវច្បាប់។ ក្នុងនោះក្រុមហ៊ុនត្រូវបំពេញទៅតាមលក្ខខណ្ឌតម្រូវផ្លូវច្បាប់មួយចំនួនឲ្យបានត្រឹមត្រូវ ក្នុងដំណាក់ការនៃការធ្វើIPO មុននឹងឈានដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាផ្លូវការ ដែលដំណាក់កាលនៃការធ្វើIPOមានដូចជា ការដាក់លិខិតសម្តែងឆន្ទៈក្នុងការបោះផ្សាយលក់មូលបត្រ ការជ្រើសរើក្រុមហ៊ុនធានាទិញមូលបត្រ ការបង្កើតក្រុមការងារបោះផ្សាយមូលបត្រ ការត្រួតពិនិត្យការបំពេញការតព្វកិច្ចតាមច្បាប់ ការពិនិត្យលើលទ្ធភាពចុះបញ្ជី ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈ និងការចុះបញ្ជីជាផ្លូវការនៅ ន.ម.ក។

សរុបសេចក្តីមកវិស័យមូលបត្រនៅកម្ពុជាកំពុងតែមានការរីកចម្រើនទៅមុខជាលំដាប់ ដោយមានការចូលរួមចុះបញ្ជីបោះផ្សាយមូលបត្រជាសារធារណៈជាបន្តបន្ទាប់ ជាពិសេសក្រុមហ៊ុនដែលចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធ។ ប៉ុន្តែទោះបីជាក្រុមហ៊ុនដែលចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធមានការកើនឡើង

បើធៀបទៅឆ្នាំមុនៗក៏ដោយ ក៏ចំនួនក្រុមហ៊ុនដែលចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធនៅមានកម្រិតនៅឡើយ បើធៀបទៅបណ្តាប្រទេសនានា ដែលជាហេតុធ្វើឲ្យវិនិយោគិនមានជម្រើសតិច ក្នុងការសម្រេចចិត្តធ្វើការវិនិយោគ ជាពិសេសទៅទៀតដោយសារតែវិស័យមូលបត្រជាវិស័យថ្មីមួយនៅកម្ពុជា ទាំងវិនិយោគិន និងក្រុមហ៊ុនបោះផ្សាយនៅមិនទាន់មានចំណាប់អារម្មណ៍ច្រើននៅក្នុងវិស័យនេះនៅឡើយ។

## ២.ការផ្តល់អនុសាសន៍

យោងទៅតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ក្រុមនាងខ្ញុំ អស់មួយរយៈពេលកន្លងមក យើងបានសង្កេតឃើញថា ចំពោះដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធ ជាសាធារណៈជាលើកដំបូងនៅកម្ពុជា មានចំនួនក្រុមហ៊ុន ចុះបញ្ជីបោះផ្សាយលក់មូលបត្រកម្មសិទ្ធ កើនឡើងជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស ប៉ុន្តែទន្ទឹមនឹងការទទួលបានលទ្ធផលវិជ្ជមានបែបនេះ យើងក៏បានរកឃើញកង្វះខាតមួយចំនួនតូចកើតមានឡើង ដែលនិយ័តករមូល បត្រកម្ពុជា និងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា គប្បីធ្វើការពិចារណា។ នាងខ្ញុំសូមការអនុញ្ញាត ដើម្បីផ្តល់ជាគំនិត និងមតិយោបល់ខ្លះៗ ទៅលើចំនុចមួយចំនួនដូចខាងក្រោម ដើម្បីជាជំនួយ ជួយឲ្យវិស័យមូល បត្រនៅ កម្ពុជា ក៏ដូចជាដំណើការបោះផ្សាយលក់មូលបត្រនៅកម្ពុជា កាន់តែមានការីកចម្រើន និងមានដំណើរការទៅមុខយ៉ាងរលូនៈ

- និយ័តករមូលបត្រកម្ពុជា និងក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជា បន្តជំរុញនិងមានយុទ្ធសាស្ត្រទាក់ទាញយ៉ាងណា ដើម្បីឲ្យមានការកើនឡើងនូវចំនួនក្រុមហ៊ុនចុះបញ្ជីបោះផ្សាយលក់មូលបត្រឲ្យកាន់តែមានចំនួនច្រើនឡើង និងសម្បូរបែបទាំងគ្រឹះស្ថានសាធារណៈ និងក្រុមហ៊ុនឯកជន ដើម្បីឲ្យវិនិយោគិនមានជម្រើសច្រើនក្នុងការសម្រេចចិត្តវិនិយោគ។
- បន្តការផ្សព្វផ្សាយ បង្កើតជាវេទិការ កម្មវិធីសិក្ខាសាលា និងតាមរយៈកម្មវិធីផ្សេងៗទៀត ស្តីពីដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធជាសាធារណៈជាលើកដំបូង ជាពិសេសនៅក្នុងដំណាក់កាលធ្វើ ប៊ុកបៀលឌីង និងដំណាក់ការធ្វើបរិវិសកម្ម ដើម្បីឲ្យវិនិយោគិន និងសាធារណៈជន ដែលមានបំណងចង់វិនិយោគក្នុងវិស័យមូលបត្រកាន់យល់ដឹងច្បាស់ និងមានភាពងាយស្រួលក្នុងការបញ្ជាទិញមូលបត្រកម្មសិទ្ធនៅក្នុងទីផ្សារដំបូង។
- ធានាឲ្យបាននូវការអនុវត្ត ការត្រួតពិនិត្យលើលក្ខខណ្ឌនិងនីតិវិធី នៃដំណើរការបោះផ្សាយលក់មូលបត្រឲ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់បំផុត ដើម្បីជាទំនុកចិត្តដល់វិនិយោគិន ។
- បន្តការផ្សព្វផ្សាយ និងធ្វើការជូនដំណឹងឲ្យកាន់តែច្រើននិងមានប្រសិទ្ធភាព ស្តីពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងកំពុងត្រៀមបោះផ្សាយលក់មូលបត្រជាសាធារណៈ ជាពិសេសទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងដំណើរការបោះផ្សាយលក់មូលបត្រ ទៅដល់សាធារណៈជននិងវិនិយោគិន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត


- ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ ពរល ០៧១០.៥៥៥, ១៩ តុលា ២០០៧
- ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ នស/រមក/១០០៧/០២៨,១៨ តុលា ២០០៧
- ប្រកាសស្ដីពីការផ្ដល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ, លេខ ០០៩ គ.ម.ក. ប្រ.ក.,ចុះថ្ងៃទី ១៩ វិច្ឆិការ ២០០៩
- ប្រកាសលេខ ០០៦/១៥ ស្ដីពីការដាក់ឲ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធ,ចុះថ្ងៃទី ១០ កញ្ញា ២០១៥
- ប្រកាសលេខ០១៧/១៧ គ.ម.ក. / ប្រក, ស្ដីពីការដាក់ឲ្យអនុវត្តវិធានប្រតិបត្តិការទីផ្សារមូលបត្ររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- ប្រកាសស្ដីពីការដាក់ឲ្យអនុវត្តន៏វិធានប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ, លេខ០១៨/១៧គ.ម.គ., ២៦ ធ្នូ ២០១៧
- អនុក្រឹតស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន
- អនុក្រឹតស្ដីពី “ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈកម្មការមូលបត្រកម្ពុជា” ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨។
- អនុក្រឹតលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ កក្កដា ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ


## សៀវភៅ


- សៀវភៅមូលដ្ឋានគ្រិះនៃទីផ្សារមូលបត្រ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, បៀនសាំង,២០១១
- ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ១,សួនចំរើន,២០១៧
- សៀវភៅកិច្ចដំណើរការទីផ្សារបន្ទាប់,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ហ៊ លីគារ
- សៀវភៅនីតិទីផ្សារមូលបត្រ, ញៀន វណ្ណៈ ,២០១៥
- សៀវភៅមេរៀន ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ, សម្រាប់ឆ្នាំទី៣, សាស្ត្រាចារ្យ សាន មន្តិយ៉ា

- សៀវភៅមេរៀន ទីផ្សារមូលបត្រកម្ពុជា, សម្រាប់ឆ្នាំទី៤ ឆមាសទី២, សាស្ត្រាចារ្យ ហេង ចាន់ប៉ូលីន

**គេហទំព័រ**

- គេហទំព័រនិយ័តករមូលបត្រកម្ពុជាwww.secc.gov.kh
- គេហទំព័ររបស់ក្រុមហ៊ុនទីផ្សារមូលបត្រកម្ពុជាwww.csx.com.kh
- https://m.postkhmer.com បានចូលទស្សនាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២១
- Michael Simmons, Securities Operation LA Guide to Trade And Position Management
- https://en.m.wikipedia.org/wiki/United_States_Treasury_security បានចូលទស្សនា ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.......០០៥/១៥.........គ.ម.ក/ប្រ.ក.

# ប្រកាស
# ស្តីពី
# ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ/បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជានាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh,
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh,

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងចែងអំពីបែបបទ យន្តការ នីតិវិធី និងការអនុញ្ញាតពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមតាមច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន÷

១-ច្បាប់ សំដៅដល់ច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

២-អនុក្រឹត្យ សំដៅដល់អនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

៣-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចជាការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ឬការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ÷

ក-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មី ឬលើកដំបូងជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលមិនធ្លាប់បានបោះផ្សាយលក់ជាសាធារណៈពីមុនមក ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

ខ-ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមជាសាធារណៈ សំដៅដល់ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដែលធ្វើឡើងដោយក្រុមហ៊ុនធ្លាប់បានបោះផ្សាយលក់មូលបត្រជាសាធារណៈរួចហើយ។

៤-ក្រុមហ៊ុនសក្ដានុពល សំដៅដល់ក្រុមហ៊ុនដែលមានលទ្ធភាពអាចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចជាសហគ្រាសធុនតូចនិងមធ្យម ក្រុមហ៊ុនដែលទើបបង្កើតថ្មី និងក្រុមហ៊ុនដែលមានកំណើនខ្ពស់ ឬអាចមានកំណើនខ្ពស់។

៥-ក្រុមហ៊ុនហូលឌីង (Holding Company) សំដៅដល់ក្រុមហ៊ុនដែលកាន់កាប់បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនពាណិជ្ជកម្ម ឬក្រុមហ៊ុនសម្ព័ន្ធ ដោយមានភាពជាម្ចាស់កម្មសិទ្ធិដោយកាន់កាប់ភាគហ៊ុនចំនួនច្រើន

ឬចំនួនតិចដែលមានសិទ្ធិបោះឆ្នោតគ្រប់គ្រាន់លើក្រុមហ៊ុនដែលកាន់កាប់។

៦-ភាគហ៊ុនបុរិមា (Preference share) សំដៅដល់ភាគហ៊ុនដែលអ្នកកាន់កាប់គ្មានសិទ្ធិបោះឆ្នោត និងមានសិទ្ធិជាអាទិភាពក្នុងការទទួលភាគលាភ។

៧-ភ្នាក់ងារបញ្ជិកាមូលបត្រ (Securities Registrar) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់ជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។

៨-ភ្នាក់ងារវាយតម្លៃ សំដៅដល់ក្រុមហ៊ុនដែលមានសកម្មភាពធុរកិច្ចក្នុងការវាយតម្លៃទ្រព្យសកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩-ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ (Securities Transfer Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការផ្ទេរមូលបត្រ។

១០-ភ្នាក់ងារទូទាត់ (Paying Agent) សំដៅដល់បុគ្គលដែលទទួលស្គាល់ដោយ **គ.ម.ក.** ដើម្បីផ្តល់សេវានានាពាក់ព័ន្ធនឹងការទូទាត់ជំនួសឱ្យក្រុមហ៊ុនបោះផ្សាយ។

១១-មូលបត្រកម្មសិទ្ធិ សំដៅដល់ផលប្រយោជន៍ ឬសិទ្ធិស្របច្បាប់លើមូលបត្រនៃក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត រួមទាំងនីតិបុគ្គលបរទេសប្រហាក់ប្រហែល ហើយរាប់បញ្ចូលទាំងភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត និងគ្មានសិទ្ធិបោះឆ្នោត ភាគហ៊ុនមិនបង់ថ្លៃគ្រប់ និងភាគហ៊ុនបុរិមា។

១២-សិទ្ធិបរិវត្តន៍ (Conversion Rights) សំដៅដល់សិទ្ធិក្នុងការផ្ទេរពីភាគហ៊ុនបុរិមាទៅជាមូលបត្រកម្មសិទ្ធិធម្មតា។

**ប្រការ ៣.-**

សំណើលក់មូលបត្រកម្មសិទ្ធិ អាចជាសំណើលក់ជាឯកជន ឬសំណើលក់ជាសាធារណៈ។

សំណើលក់មូលបត្រកម្មសិទ្ធិដែលបំពេញលក្ខខណ្ឌដូចខាងក្រោម ត្រូវចាត់ទុកថាជាសំណើលក់មូលបត្រកម្មសិទ្ធិជាឯកជន÷

១-សំណើលក់មូលបត្រដែលធ្វើឡើងចំពោះបុគ្គលដែលមានចំនួនមិនលើសពី ៣០ (សាមសិប) រូប និង

២-សំណើលក់មូលបត្រមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ទោះបីតាមមធ្យោបាយណាក៏ដោយ រួមទាំងការផ្សព្វផ្សាយក្នុងគោលបំណងគ្រាន់តែឱ្យមកសាកសួរព័ត៌មាន ឬសុំពិគ្រោះយោបល់អំពីការធ្វើវិនិយោគលើមូលបត្រ។

បុគ្គលដែលមានបំណងធ្វើសំណើលក់មូលបត្រជាឯកជន ត្រូវផ្តល់ឯកសារពាក់ព័ន្ធនឹងសំណើលក់នោះមក **គ.ម.ក.** ហើយនៅពេលដែលសំណើលក់ជាឯកជននោះបានបញ្ចប់ បុគ្គលត្រូវវាយការណ៍ពីលទ្ធផល

ឱ្យបានឆាប់ជូន **គ.ម.ក.**។ ចំពោះបុគ្គលដែលបានចុះបញ្ជីបោះផ្សាយលក់មូលបត្រជាសាធារណៈ ហើយមានសំណើធ្វើប្រតិបត្តិការដាក់លក់ជាឯកជន បុគ្គលត្រូវរាយការណ៍ពីលទ្ធផលភ្លាមជូន **គ.ម.ក.**។

សំណើលក់មូលបត្រកម្មសិទ្ធិទាំងឡាយណាដែលខុសពីលក្ខខណ្ឌខាងលើ គឺជាសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដែលតម្រូវឱ្យអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ អនុក្រឹត្យ និងក្នុងប្រកាសនេះ។

## ជំពូកទី ២
## ការអនុញ្ញាតការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

### ប្រការ ៤.-

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម÷

១- ត្រូវអនុវត្តតាមលក្ខខណ្ឌអភិបាលកិច្ចសាជីវកម្មដែលកំណត់ដោយ **គ.ម.ក.**។

២- ត្រូវមានសកម្មភាពធុរកិច្ចសមស្របនឹងផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា រួមទាំងផ្តល់ផលប្រយោជន៍ដល់សេដ្ឋកិច្ច សង្គម និងធានានិរន្តរភាពប្រតិបត្តិការធុរកិច្ច។

៣- ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Statements) និង/ឬរបាយ-ការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Statements) រយៈពេល ២ (ពីរ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត និងរយៈពេល ១ (មួយ) ឆ្នាំនៃឆ្នាំសារពើពន្ធចុងក្រោយ សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់ និងបទ-ប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ ករណីបុគ្គលដាក់ពាក្យស្នើសុំដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ នៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស បុគ្គលដាក់ពាក្យស្នើសុំនោះត្រូវផ្តល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា។

៤- ត្រូវទទួលបានការបញ្ជាក់ជាមុនពីទីផ្សារមូលបត្រប្រតិស្រុតពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ។

៥- ត្រូវមានឯកសារផ្តល់ព័ត៌មានដូចមានកំណត់ក្នុងប្រការ ៧ នៃប្រកាសនេះ។

### ប្រការ ៥.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ត្រូវ÷

១- ដាក់ពាក្យស្នើសុំតាមទម្រង់កំណត់ដោយ **គ.ម.ក.**។

២- ដាក់ឯកសារផ្តល់ព័ត៌មានតាមការកំណត់របស់ **គ.ម.ក.**។

៣- ដាក់ឯកសារភ្ជាប់ដូចមានកំណត់ក្នុងប្រកាសនេះ។

**ប្រការ ៦.-**

ក្រុមហ៊ុនបោះផ្សាយត្រូវសុំការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនៅ **គ.ម.ក.** ដោយអនុលោមតាមមាត្រា១២ នៃច្បាប់ និងមាត្រា ៩ មាត្រា ១០ មាត្រា ១១ និងមាត្រា ១៣ នៃអនុក្រឹត្យ។

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចមានកំណត់ពីប្រការ ៧ ដល់ប្រការ ២៦ នៃប្រកាសនេះ។ ឯកសារផ្តល់ព័ត៌មានត្រូវមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល អភិបាល នាយកប្រតិបត្តិរបស់ក្រុមហ៊ុនបោះផ្សាយ និងនាយកហិរញ្ញវត្ថុ។

**ប្រការ ៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានដូចខាងក្រោម÷

១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងសំណើបោះផ្សាយ

២- ព័ត៌មានស្តីពីកត្តាហានិភ័យ

៣- ការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

៤- ផែនការវិនិយោគ

៥- ការពិពណ៌នាអំពីធុរកិច្ច

៦- ការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ

៧- ការពិពណ៌នាអំពីអចលកម្មបរិរបស់ក្រុមហ៊ុនបោះផ្សាយ

៨- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ

៩- ព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក

១០- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

១១- ទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

១២- ប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

១៣- សិទ្ធិទិញមូលបត្រកម្មសិទ្ធិដែលបានផ្តល់ទៅឱ្យអភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត

១៤- ប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក

១៥- ទ្រព្យសកម្មសុទ្ធ និងប្រាក់ចំណេញក្នុងមួយឯកតានៃមូលបត្រកម្មសិទ្ធិ

១៦- កម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ

១៧- ការដាក់តម្លៃមូលបត្រកម្មសិទ្ធិដើម្បីធ្វើសំណើលក់

១៨- សិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

១៩- ព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម។

**ប្រការ ៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវពណ៌នាអំពីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ រួមទាំងព័ត៌មានទូទៅរបស់ក្រុមហ៊ុនបោះផ្សាយដូចខាងក្រោម÷

១- ឈ្មោះក្រុមហ៊ុនបោះផ្សាយ

២- ចំនួន និងប្រភេទមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយ

៣- តម្លៃលក់មូលបត្រកម្មសិទ្ធិក្នុងមួយឯកតា និងតម្លៃសរុប

៤- ឈ្មោះ និងអាសយដ្ឋានក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញ

៥- ថ្ងៃបើក និងថ្ងៃបិទការធ្វើបរិវិសកម្ម

៦- កាលបរិច្ឆេទចុះបញ្ជីឯកសារផ្តល់ព័ត៌មាន

៧- សេចក្តីបញ្ជាក់ថា "ព័ត៌មានដែលមាននៅក្នុងឯកសារផ្តល់ព័ត៌មានត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវទាំងស្រុងរបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងបុគ្គលពាក់ព័ន្ធ និងបុគ្គលពាក់ព័ន្ធក្នុងការរៀបចំឯកសារផ្តល់ព័ត៌មាននេះ"។

**ប្រការ ៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីកត្តាហានិភ័យដូចខាងក្រោម÷

១- ហានិភ័យហិរញ្ញវត្ថុ

២- ហានិភ័យសេដ្ឋកិច្ច

៣- ហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

៤- ហានិភ័យផ្សេងៗតាមការតម្រូវរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ១០.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

ប្រសិនបើសាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវប្រើប្រាស់សម្រាប់ធានាចំណាយលើកិច្ចសន្យានៃសកម្មភាពណាមួយរបស់ក្រុមហ៊ុនបោះផ្សាយ ឯកសារផ្ដល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនោះ។

**ប្រការ ១១.-**

ករណីសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពាក់ព័ន្ធនឹងផែនការវិនិយោគ ឬមានពាក់ព័ន្ធនឹងផែនការវិនិយោគលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នាជាទម្រង់ពេញលេញក្នុងឯកសារផ្ដល់ព័ត៌មាន។

**ប្រការ ១២.-**

ឯកសារផ្ដល់ព័ត៌មានត្រូវមានការពិពណ៌នាអំពីធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដូចជា÷

១-កាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម និងកាលបរិច្ឆេទចាប់ផ្ដើមប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខណៈនៃធុរកិច្ចដែលក្រុមហ៊ុនបោះផ្សាយ និងសាខាក្រុមហ៊ុនបោះផ្សាយបានចូលរួម ឬនឹងចូលរួម។

២-ផលិតផលដែលជាទំនិញ ឬសេវាស្នូលរបស់ក្រុមហ៊ុនបោះផ្សាយ និងទីផ្សាររបស់ផលិតផលទាំងនោះនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា។

៣-ទំហំនៃការលក់ផលិតផលផ្សេងទៀតដែលមិនមែនជាផលិតផលស្នូល ហើយទទួលបានប្រាក់ចំណូលលើសពី ១០ (ដប់) ភាគរយនៃប្រាក់ចំណូលសរុបរបស់ក្រុមហ៊ុនបោះផ្សាយ។

៤-ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ បុត្រសម្ព័ន្ធនៃក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងធុរកិច្ចស្នូលរបស់ក្រុមហ៊ុនទាំងនោះ។

៥-វិធីសាស្ត្រចែកចាយផលិតផល។

៦-ស្ថានភាពប្រកួតប្រជែងនៃធុរកិច្ចក្នុងទីផ្សារ។

៧-វត្ថុធាតុដើម ឬធាតុចូលផ្សេងៗដែលធានាដល់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងប្រភព និងអ្នកផ្គត់ផ្គង់។

៨-តម្រូវការថាមពល ឧស្ម័ន ទឹក ឬសម្ភារៈប្រើប្រាស់ផ្សេងៗទៀតដែលចាំបាច់សម្រាប់ដំណើរការផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុន ដោយបញ្ជាក់ពីប្រភព។

៩-ឈ្មោះអតិថិជនដែលទិញផលិតផល ឬសេវារបស់ក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃផលិតផល ឬសេវាសរុប ដោយបញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើរួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១០-ឈ្មោះអ្នកផ្គត់ផ្គង់ដែលលក់ផលិតផល ឬសេវាឱ្យក្រុមហ៊ុនបោះផ្សាយចាប់ពី ១០ (ដប់) ភាគរយឡើងទៅនៃចំនួនទឹកប្រាក់សរុបលើផលិតផល ឬសេវាទាំងអស់ដែលបានទិញដោយក្រុមហ៊ុនបោះផ្សាយ ដោយ

បញ្ជាក់ពីកិច្ចសន្យាដែលបានធ្វើ រួមមានចំនួនទឹកប្រាក់សរុប បរិមាណនៃប្រតិបត្តិការ និងរយៈពេលនៃកិច្ចសន្យា។

១១- ការពិពណ៌នាពីប្រកាសនីយបត្រតក្កកម្ម ម៉ាក ពាណិជ្ជនាម សិទ្ធិអាជីវកម្ម ឬកិច្ចព្រមព្រៀងផ្សេងទៀតពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិបញ្ញា។

១២- ចំនួនបុគ្គលិកសរុប និងចំនួនបុគ្គលិកធ្វើការពេញម៉ោង។

១៣- សក្តានុពលនៃសមត្ថភាពផលិតកម្ម ឬសេវាកម្មរបស់ក្រុមហ៊ុនបោះផ្សាយ និងបញ្ជាក់ពីកម្រិតសមត្ថភាពដែលកំពុងប្រើប្រាស់នាពេលបច្ចុប្បន្ន។

១៤- ប្រសិនបើក្រុមហ៊ុនបោះផ្សាយជាក្រុមហ៊ុនហូលឌីង ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពេញលេញស្តីពីប្រតិបត្តិការសំខាន់រវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីង ដោយបញ្ជាក់ពីលក្ខណៈនៃប្រតិបត្តិការ និងចំនួនទឹកប្រាក់ដែលបានធ្វើក្នុងរយៈពេល ៣ (បី) ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ១៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវពិពណ៌នាអំពីការពិនិត្យឡើងវិញ និងការព្យាករណ៍លើប្រតិបត្តិការ និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

១- លទ្ធផលប្រតិបត្តិការ។

២- សន្ទនីយភាព និងប្រភពទុន។

៣- ការស្រាវជ្រាវ និងការអភិវឌ្ឍ។

៤- ព័ត៌មាននិន្នាការ និងការព្យាករណ៍ប្រាក់ចំណេញ និងលំហូរសាច់ប្រាក់ សម្រាប់រយៈពេល ១ (មួយ) ឆ្នាំ។

**ប្រការ ១៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ពាក់ព័ន្ធនឹងអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដូចខាងក្រោម÷

១- ទីតាំងប្រតិបត្តិការ និងទីតាំងអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ព្រមទាំងលក្ខខណ្ឌនៃអចលកម្មសិទ្ធិទាំងនោះ។

២- សេចក្តីបញ្ជាក់អំពីកម្មសិទ្ធិលើអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ។ ប្រសិនបើអចលកម្មសិទ្ធិទាំងនោះទទួលបានមកតាមរយៈការជួល ត្រូវមានការបញ្ជាក់ពីកាលបរិច្ឆេទផុតកំណត់នៃការជួល ព្រមទាំងឈ្មោះម្ចាស់អចលកម្មសិទ្ធិ។

៣- ការវាយតម្លៃលើអចលកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយធ្វើឡើងដោយភ្នាក់ងារវាយតម្លៃដែលទទួល

បានការទទួលស្គាល់ពី **គ.ម.ក.** ដោយភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ ប្រសិនមាន។

៤-ប្រសិនបើអចលកម្មរូបីដែលក្រុមហ៊ុនបោះផ្សាយកំពុងប្រើប្រាស់ជាប់នូវប្រាតិភោគភណ្ឌិក ក្រុមហ៊ុនបោះផ្សាយត្រូវបញ្ជាក់ពីអត្តសញ្ញាណរបស់ម្ចាស់ទ្រព្យនោះ ព្រមទាំងតម្លៃដើម និងតម្លៃបច្ចុប្បន្នរបស់ប្រាតិ-ភោគភណ្ឌិក។

**ប្រការ ១៥.-**

ករណីមានការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានសំខាន់ស្ដីពីការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ ដោយបង្ហាញនូវ÷

១-ព័ត៌មានសង្ខេបពីការវាយតម្លៃ ឬការវាយតម្លៃឡើងវិញរួមមានតម្លៃទ្រព្យសកម្មមុនពេលធ្វើការវាយតម្លៃឡើងវិញ សមាសធាតុនៃទ្រព្យដែលបានវាយតម្លៃឡើងវិញ ដោយត្រូវដាក់ដោយឡែកក្នុងលក្ខណៈមួយដែលជួយសម្រួលដល់ការប្រៀបធៀបរវាងតម្លៃចារឹក និងតម្លៃដែលបង្ហាញក្រោយពីបានវាយតម្លៃឡើងវិញ និងត្រូវភ្ជាប់មកជាមួយនូវរបាយការណ៍វាយតម្លៃ។

២-ហេតុផលនៃការវាយតម្លៃ ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ។

៣-អត្តសញ្ញាណ និងគុណវុឌ្ឍិរបស់ភ្នាក់ងារវាយតម្លៃ។

**ប្រការ ១៦.-**

ឯកសារផ្ដល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងអភិបាល បុគ្គលិកជាន់ខ្ពស់ និងភាគហ៊ុនិក ដូចខាងក្រោម÷

១-ជីវប្រវត្តិសង្ខេប ដោយមានបញ្ជាក់ពីឈ្មោះ អាយុ គុណវុឌ្ឍិ បទពិសោធន៍ និងតំណែងរបស់អភិបាលម្នាក់ៗរបស់ក្រុមហ៊ុនបោះផ្សាយ និងបុគ្គលដែលត្រូវបានតែងតាំងជាអភិបាល ដោយបង្ហាញពីអណត្តិនៃការតែងតាំង និងស្ថាប័នដែលបានតែងតាំងអភិបាលនោះ។

២-កាលបរិច្ឆេទក្លាយជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយជាលើកដំបូង និងកាលបរិច្ឆេទបញ្ចប់អណត្តិបច្ចុប្បន្ន។

៣-ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬជាសហកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត ត្រូវបង្ហាញឈ្មោះក្រុមហ៊ុនពាក់ព័ន្ធទាំងនោះ។

៤-ទំនាក់ទំនងសាច់ញាតិ ក្នុងចំណោមអភិបាល និងបុគ្គលិកជាន់ខ្ពស់។

៥-ឈ្មោះ រួមទាំងតំណែង គុណវុឌ្ឍិអប់រំ កាលបរិច្ឆេទចូលរួមជាមួយក្រុមហ៊ុនបោះផ្សាយ បទពិសោធន៍ ៥ (ប្រាំ) ឆ្នាំចុងក្រោយរបស់អគ្គនាយក អគ្គនាយករង នាយកប្រតិបត្តិ នាយកហិរញ្ញវត្ថុ លេខាធិការក្រុមហ៊ុន អ្នកប្រឹក្សាយោបល់ និងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

៦- សេចក្តីបញ្ជាក់អំពីអសាធនភាពរបស់ភាគហ៊ុនិករបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ភាគហ៊ុន ចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ។

ឯកសារផ្តល់ព័ត៌មានត្រូវភ្ជាប់នូវឯកសារដូចខាងក្រោម៖

១- ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ។

២- របាយការណ៍របស់អភិបាលស្តីពីការវាយតម្លៃស្ថានភាពរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៧.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់ដែលបានកើតឡើងនៅក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយ ដូចខាងក្រោម៖

១- បណ្តឹងពាក់ព័ន្ធនឹងក្ស័យធនធ្វើឡើងចំពោះក្រុមហ៊ុនដែលបុគ្គលិកជាន់ខ្ពស់ ឬអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់ជាអភិបាល បុគ្គលិក ឬជាសហកម្មសិទ្ធិករ។

២- ការផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬកំពុងស្ថិតនៅក្នុងនីតិវិធីតុលាការចំពោះអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៣- ការសម្រេចជាស្ថាពរ ឬជាបណ្តោះអាសន្នរបស់តុលាការមានសមត្ថកិច្ចចំពោះអភិបាល បុគ្គលិកជាន់ខ្ពស់ ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នោះ នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

៤- ការសម្រេចរបស់គណៈកម្មការមូលបត្រកម្ពុជា ឬគណៈកម្មការមូលបត្របរទេស ឬនិយ័តករនៃវិស័យផ្សេងទៀត ដោយហាមឃាត់មិនឱ្យចូលរួម ឬដោយរារាំង ឬដោយព្យួរ ឬដោយដាក់កំហិតទៅលើអភិបាល ឬបុគ្គលិកជាន់ខ្ពស់នៅក្នុងសកម្មភាពមូលបត្រ ឬសកម្មភាពធុរកិច្ចណាមួយ។

**ប្រការ ១៨.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីទំនាក់ទំនង និងប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ ដោយពិពណ៌នាអំពីប្រតិបត្តិការសំខាន់ៗ ក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ ដោយផ្តល់ឈ្មោះ ទំនាក់ទំនង ទំហំ និងប្រភេទនៃផលប្រយោជន៍ដែលកើតចេញពីទំនាក់ទំនងរវាងក្រុមហ៊ុនបោះផ្សាយជាមួយនឹងបុគ្គលជាប់ពាក់-ព័ន្ធ ដូចខាងក្រោម៖

១- អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាមួយ រួមទាំងអភិបាលដែលកាន់មុខតំណែងណាមួយនៅក្នុងសមាគម ឬអង្គភាពមិនស្វែងរកប្រាក់ចំណេញ ឬនៅក្នុងក្រុមហ៊ុនណាមួយផ្សេងទៀត ក្រៅពីក្រុមហ៊ុនបោះ-ផ្សាយ និងអភិបាលដែលទទួលបានផលប្រយោជន៍ពីក្រុមហ៊ុនបោះផ្សាយ ទោះជាហិរញ្ញវត្ថុ ឬមិនមែនហិរញ្ញវត្ថុ។

២- បុគ្គលមានភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅនៃមូលបត្រកម្មសិទ្ធិកំពុងធ្វើចរាចរនៅក្នុងទីផ្សារ។

៣- សមាជិកគ្រួសារផ្ទាល់របស់បុគ្គលដែលចែងក្នុងចំណុចទី ១ និងទី ២ ខាងលើ។

៤- បុគ្គលមានទំនាក់ទំនងជាមួយអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនេះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយ ដែលបានធ្វើឡើងដោយក្រុមហ៊ុនបោះផ្សាយ។

៥- បុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទំនាក់ទំនងកើតឡើងក្នុងក្របខ័ណ្ឌប្រតិបត្តិការរបស់ក្រុមហ៊ុនបោះផ្សាយ។

**ប្រការ ១៩.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងប្រាក់បំណាច់ ឬលាភការសម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដូចខាងក្រោម÷

១- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបានបើកឱ្យបុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូបរបស់ក្រុមហ៊ុនបោះផ្សាយ នៅឆ្នាំសារពើពន្ធចុងក្រោយ ដោយមានរាយនាម និងមុខតំណែងរបស់បុគ្គលិកជាន់ខ្ពស់បំផុតនោះ។

២- ចំនួនប្រាក់បំណាច់ ឬលាភការសរុបដែលបើកឱ្យអភិបាលមិនប្រតិបត្តិ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៣- ចំនួនប្រាក់បំណាច់ ឬលាភការជាកញ្ចប់ដែលបានបើកឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់ នៅក្នុងឆ្នាំសារពើពន្ធចុងក្រោយ។

៤- ចំនួនប្រាក់បំណាច់ ឬលាភការសរុបសម្រាប់រយៈពេល ១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៥- ប្រសិនបើក្រុមហ៊ុនបោះផ្សាយមានបំណងបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើនដល់អភិបាល ឬបុគ្គលិករបស់ក្រុមហ៊ុន នៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់ព័ត៌មានពាក់ព័ន្ធក្នុងការបង្កើននោះ។

**ប្រការ ២០.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានពាក់ព័ន្ធនឹងសិទ្ធិទិញមូលបត្រកម្មសិទ្ធិរបស់អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិត ដោយត្រូវបញ្ជាក់នូវ÷

១- កាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

២- ថ្លៃនៃមូលបត្រដែលត្រូវអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៣- ចំនួនមូលបត្រកម្មសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

៤- ថ្លៃទីផ្សាររបស់មូលបត្រកម្មសិទ្ធិនៅកាលបរិច្ឆេទដែលសិទ្ធិទិញមូលបត្រកម្មសិទ្ធិត្រូវបានផ្តល់ឱ្យ។

៥-កាលបរិច្ឆេទអស់សុពលភាពនៃសិទ្ធិទិញមូលបត្រកម្មសិទ្ធិ។

**ប្រការ ២១.-**

ករណីក្រុមហ៊ុនបោះផ្សាយមានប្រតិបត្តិការជាមួយអភិបាល និងភាគហ៊ុនិក ក្រុមហ៊ុនបោះផ្សាយត្រូវពិពណ៌នាក្នុងឯកសារផ្តល់ព័ត៌មាននូវឈ្មោះរបស់អភិបាល និងភាគហ៊ុនិក ប្រភេទ និងតម្លៃនៃទ្រព្យសកម្ម សេវាកម្ម ប្រាក់បំណាច់ ឬលាភការដែលបានទទួល ឬផ្តល់ឱ្យក្រុមហ៊ុនបោះផ្សាយ ដោយផ្ទាល់ ឬដោយប្រយោលក្នុងរយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

ប្រសិនបើក្រុមហ៊ុនបោះផ្សាយបានទិញ ឬនឹងទិញចលនទ្រព្យ និងអចលនទ្រព្យពីអភិបាល ឬភាគហ៊ុនិក ឯកសារផ្តល់ព័ត៌មានត្រូវមានបញ្ជាក់ពីវិធីសាស្ត្រនៃការកំណត់ថ្លៃ និងចំនួនទឹកប្រាក់ទូទាត់។

**ប្រការ ២២.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីទ្រព្យសកម្មសុទ្ធក្នុងមួយឯកតាមុន និងក្រោយការបោះផ្សាយ និងប្រាក់ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលត្រូវបោះផ្សាយលក់ នៅកាលបរិច្ឆេទនៃតារាងតុល្យការចុងក្រោយ។

**ប្រការ ២៣.-**

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញអំពីកម្មសិទ្ធិនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ក្រោមទម្រង់ជាតារាង នូវឈ្មោះរបស់បុគ្គលដែលកាន់កាប់ចាប់ពី ៥ (ប្រាំ) ភាគរយនៃមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយ ដោយត្រូវបញ្ជាក់ពីចំនួន និងភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់។

ឯកសារផ្តល់ព័ត៌មានត្រូវមានតារាងដែលបង្ហាញពីចំនួនមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនបោះផ្សាយដែលកាន់កាប់ដោយអភិបាលម្នាក់ៗ បុគ្គលិកដែលទទួលបានប្រាក់បំណាច់ ឬលាភការខ្ពស់បំផុតចំនួន ៥ (ប្រាំ) រូប ដោយបញ្ជាក់ឈ្មោះ និងអាសយដ្ឋាន ព្រមទាំងបុគ្គលិកផ្សេងទៀត ក្រោមរូបភាពជាសរុប ដោយត្រូវបញ្ជាក់ជាភាគរយនៃមូលបត្រកម្មសិទ្ធិដែលបានកាន់កាប់ធៀបនឹងចំនួនមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរនៅលើទីផ្សារ។

**ប្រការ ២៤.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានការកំណត់នូវកត្តាដែលយកមកប្រើប្រាស់ ក្នុងការដាក់តម្លៃមូលបត្រកម្មសិទ្ធិ ដើម្បីធ្វើសំណើលក់។

**ប្រការ ២៥.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានស្តីពីសិទ្ធិរបស់កម្មសិទ្ធិករលើមូលបត្រកម្មសិទ្ធិដែលធ្វើសំណើ

លក់ ដូចខាងក្រោម÷

១-ពិពណ៌នាពីសិទ្ធិទទួលភាគលាភ និងសិទ្ធិបោះឆ្នោតនៃមូលបត្រកម្មសិទ្ធិដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

២-ពិពណ៌នាសិទ្ធិទទួលភាគលាភ សិទ្ធិបោះឆ្នោត សិទ្ធិបរិវត្តន៍ និងសិទ្ធិជំរះបញ្ជី ព្រមទាំងមូលនិធិសម្រាប់ទូទាត់សងភាគហ៊ុនបុរិមាដែលកំពុងចរាចរនៅលើទីផ្សារ ឬត្រូវបោះផ្សាយលក់។

៣-ប្រសិនបើមានការដាក់កំហិតណាមួយលើការបង់ភាគលាភទៅឱ្យអ្នកកាន់កាប់មូលបត្រកម្មសិទ្ធិដោយសារកិច្ចសន្យាបំណុលពាក់ព័ន្ធ ត្រូវពន្យល់ពីការដាក់កំហិតនោះ។

៤-ពិពណ៌នាពីសិទ្ធិសំខាន់ផ្សេងៗទៀតរបស់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិ។

**ប្រការ ២៦.-**

ឯកសារផ្តល់ព័ត៌មានត្រូវមានព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្រ (Historical Financial Information) និង/ឬព័ត៌មានហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួម (Consolidated Historical Financial Information) ដែលបំពេញតាមទម្រង់កំណត់ដោយ **គ.ម.ក.** ហើយត្រូវភ្ជាប់របាយការណ៍ហិរញ្ញវត្ថុដែលបានរៀបចំ និងធ្វើសវនកម្មស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២៧.-**

អនុលោមតាមមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យ អ្នកជំនាញ ឬភាគីពាក់ព័ន្ធដែលបានផ្តល់នូវការយល់ព្រមជាលាយលក្ខណ៍អក្សរលើសេចក្តីថ្លែង ឬរបាយការណ៍ ឬយោបល់ឱ្យធ្វើការផ្សព្វផ្សាយនៅក្នុងឯកសារផ្តល់ព័ត៌មាន ត្រូវទទួលខុសត្រូវលើសេចក្តីថ្លែង របាយការណ៍ ឬយោបល់ដែលបានផ្តល់ឱ្យនោះ។

**ប្រការ ២៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវទទួលខុសត្រូវទាំងស្រុងចំពោះភាពត្រឹមត្រូវ ភាពគ្រប់គ្រាន់ និងភាពអាចជឿជាក់បាន នូវរាល់ព័ត៌មានដែលបានបង្ហាញនៅក្នុងឯកសារផ្តល់ព័ត៌មាន។

ក្រុមហ៊ុនមូលបត្រ និងបុគ្គលពាក់ព័ន្ធដទៃទៀត ដែលផ្តល់យោបល់ ឬព័ត៌មាន និងចូលរួមក្នុងការរៀបចំឯកសារផ្តល់ព័ត៌មានត្រូវទទួលខុសត្រូវចំពោះយោបល់ ឬព័ត៌មាន និងការចូលរួមនោះ។

**ប្រការ ២៩ .-**

ក្រុមហ៊ុនបោះផ្សាយត្រូវភ្ជាប់មកជាមួយពាក្យស្នើសុំ នូវឯកសារដូចខាងក្រោម÷

១-លក្ខន្តិកៈរបស់ក្រុមហ៊ុនបោះផ្សាយថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

២-វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មថតចម្លងដោយមានការបញ្ជាក់ត្រឹមត្រូវ។

៣- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ទៅតាមការសម្រេចរបស់មហាសន្និបាតភាគហ៊ុនិក។

៤-លិខិតប្រគល់សិទ្ធិឱ្យអភិបាល ឬនាយកប្រតិបត្តិនៃក្រុមហ៊ុនបោះផ្សាយ ដែលចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល និងអភិបាលទាំងអស់។

៥-កិច្ចព្រមព្រៀងពាក់ព័ន្ធនឹងកម្ចីផ្សេងៗដែលមាន។

៦-កិច្ចសន្យាដែលត្រូវប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ប្រសិនមាន។

៧-ផែនការធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយសម្រាប់រយៈពេលយ៉ាងតិច ១ (មួយ) ឆ្នាំ។

៨- លិខិតបញ្ជាក់ពីធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ស្តីពីការបើកគណនីដាច់ដោយឡែកសម្រាប់គោលបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៩-កិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១០-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence Report) ដែលចេញដោយក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្រ។

១១-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារបញ្ជិកាមូលបត្រ។

១២-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

១៣-កិច្ចព្រមព្រៀងជាមួយភ្នាក់ងារទូទាត់។

១៤-កិច្ចព្រមព្រៀងសំខាន់ៗវិនិយោគចម្រុះ ប្រសិនមាន។

១៥-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់ពាក់ព័ន្ធនឹងកិច្ចការគណនេយ្យ ចេញដោយក្រុមហ៊ុនគណនេយ្យជំនាញដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ករណីរបាយការណ៍ហិរញ្ញវត្ថុដូចមានចែងក្នុងចំណុចទី ៣ នៃប្រការ ៤ ខាងលើ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនគណនេយ្យដែលមិនមានការទទួលស្គាល់ពី **គ.ម.ក.** ។

១៦-របាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់បំពេញ ចេញដោយមេធាវីដែលមានគុណវុឌ្ឍិទទួលស្គាល់ដោយ **គ.ម.ក.** ។

១៧-ឯកសារបញ្ជាក់លេខអត្តសញ្ញាណសារពើពន្ធ និងឯកសារបញ្ជាក់ពីការបំពេញកាតព្វកិច្ចបង់ពន្ធ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយផ្តល់ឯកសារផ្តល់ព័ត៌មានបន្ថែម ឬឯកសារផ្តល់ព័ត៌មានជំនួស ឬសេចក្តីបញ្ជាក់ ឬសេចក្តីបំភ្លឺ។ ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញតាមសំណើនេះ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ ឬក្នុងរយៈពេលជាក់លាក់ណាមួយដែលកំណត់ដោយអគ្គនាយកនៃ

**គ.ម.ក.** គិតចាប់ពីថ្ងៃជូនដំណឹងជាលាយលក្ខណ៍អក្សរ។ ករណីក្រុមហ៊ុនបោះផ្សាយមិនបំពេញបានទៅតាមសំណើខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៣១.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈរបស់ក្រុមហ៊ុនបោះផ្សាយ ដោយផ្អែកលើមូលហេតុដូចខាងក្រោម÷

១-ក្រុមហ៊ុនបោះផ្សាយមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

២-ព័ត៌មាន ឬឯកសារដែលបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៣-ក្រុមហ៊ុនបោះផ្សាយស្ថិតនៅក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ធុរកិច្ច ឬការរំលាយ។

៤-ការមិនអនុវត្តតាមទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការដែលតម្រូវឱ្យក្រុមហ៊ុនបោះផ្សាយទូទាត់សងបំណុល។

៥-ក្រុមហ៊ុនបោះផ្សាយ ឬអភិបាលណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ ស្របតាមអនុក្រឹត្យ។

ខ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

គ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ឃ-ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ង-ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ ឬការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ ឬយុត្តិធម៌។

៦-អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយ ធ្លាប់កាន់មុខតំណែងទាំងនេះនៅក្នុងក្រុមហ៊ុនដែលត្រូវបានប្រកាសក្ស័យធន នៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៧-ស្ថានភាពហិរញ្ញវត្ថុឬវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមិនទាន់មានលក្ខណៈគ្រប់គ្រាន់

ដើម្បីធានានូវដំណើរការនៃធុរកិច្ចប្រកបដោយចីរភាព និងភាពទុកចិត្ត។

៨- នៅពេលកើតមានហេតុការណ៍ណាមួយដែលនាំឱ្យ÷

ក- អភិបាល នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់ក្រុមហ៊ុនបោះផ្សាយមិនអាចដំណើរការអាជីវកម្មបានត្រឹមត្រូវ។

ខ- មានភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយ។

៩- ការផ្តល់ការអនុញ្ញាតដល់ក្រុមហ៊ុនបោះផ្សាយ នឹងនាំឱ្យមានផលប៉ះពាល់ដល់ប្រយោជន៍សាធារណៈ ដោយត្រូវពិចារណាលើលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១៤ នៃច្បាប់។

**ប្រការ ៣២.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ក្រុមហ៊ុនបោះផ្សាយ ពីការមិនយល់ព្រម ឬការយល់ព្រមជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្នុងរយៈពេល ២(ពីរ) ខែគិតចាប់ពីថ្ងៃទទួលបានឯកសារពេញលេញ។

## ជំពូកទី ៣
## ការដាក់លក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

**ប្រការ ៣៣.-**

ក្រុមហ៊ុនបោះផ្សាយដែលទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចចាប់ផ្តើមធ្វើសំណើលក់មូលបត្រជាសាធារណៈបាន បន្ទាប់ពី÷

១- បានរៀបចំលក្ខខណ្ឌនៃសំណើលក់ រួមទាំងការកំណត់ថ្លៃលក់មូលបត្រដែលការកំណត់ថ្លៃលក់មូលបត្រនេះត្រូវមានការបញ្ជាក់យល់ព្រមពីប្រតិបត្តិករទីផ្សារមូលបត្រ។

២- បានទទួលការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈដូចក្នុងចំណុចទី ១ ខាងលើពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១២ នៃអនុក្រឹត្យ។

៣- បានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានរបស់ក្រុមហ៊ុនបោះផ្សាយពី **គ.ម.ក.**។

**ប្រការ ៣៤.-**

បន្ទាប់ពីបានទទួលការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ការធ្វើបរិវិសកម្មត្រូវចាប់ផ្តើមក្នុងអំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាព សម្រាប់រយៈពេលដូចកំណត់ក្នុងចំណុចទី ៣ នៃមាត្រា ៧ នៃអនុក្រឹត្យ។ នៅពេលការធ្វើបរិវិសកម្មត្រូវបានបញ្ចប់ពេញលេញ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍ស្តីពីការធ្វើបរិវិសកម្មនោះភ្លាមមក **គ.ម.ក.**។

ការធ្វើបរិវិសកម្មត្រូវធ្វើឡើងតាមរយៈក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ដូចមានចែងក្នុងមាត្រា ១៦ និងមាត្រា ១៧ នៃអនុក្រឹត្យ។ ក្រុមហ៊ុនមូលបត្រត្រូវតែរក្សាទុកប្រាក់ដែលទទួលបានពីការធ្វើបរិវិសកម្មក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យ។ ចំនួន និងបញ្ជីឈ្មោះរបស់អ្នកធ្វើបរិវិសកម្មត្រូវតែរក្សាទុកនៅភ្នាក់ងារបញ្ជិកាមូលបត្រ។

ទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវកំណត់ដោយ **គ.ម.ក.**។ ការធ្វើបរិវិសកម្មនីមួយៗត្រូវចាត់ទុកថាបានបញ្ចប់ នៅពេលអ្នកធ្វើបរិវិសកម្មដែលបានបំពេញត្រឹមត្រូវតាមទម្រង់នៃពាក្យស្នើសុំធ្វើបរិវិសកម្ម បានបង់ប្រាក់គ្រប់ចំនួន និងទទួលបានបង្កាន់ដៃដែលចេញដោយក្រុមហ៊ុនមូលបត្រ។ អ្នកធ្វើបរិវិសកម្មមិនអាចដកប្រាក់ដែលបានធ្វើបរិវិសកម្មនោះវិញបានទេ លើកលែងតែករណីដូចមានចែងក្នុងចំណុចទី ៤“ខ” នៃមាត្រា ៧ និងចំណុចទី ២ នៃមាត្រា ១៨ នៃអនុក្រឹត្យ និងប្រការ ៣៨ និងប្រការ ៣៩ នៃប្រកាសនេះ។

**ប្រការ ៣៥.-**

ក្រោយពេលបញ្ចប់កាលបរិច្ឆេទធ្វើបរិវិសកម្ម ករណីមូលបត្រកម្មសិទ្ធិធ្វើបរិវិសកម្មមិនអស់ ក្រុមហ៊ុនមូលបត្រធ្វើអាជីវកម្មធានាទិញមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់ទាំងអស់ ឬតាមការព្រមព្រៀង និងទូទាត់គ្រប់ចំនួនជាសាច់ប្រាក់ ឬឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតដូចដែលមានចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យ ឱ្យក្រុមហ៊ុនបោះផ្សាយក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការបិទការដាក់ពាក្យស្នើសុំធ្វើបរិវិសកម្ម។ ក្រុមហ៊ុនបោះផ្សាយត្រូវផ្តល់របាយការណ៍អំពីការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិដែលនៅសល់មក **គ.ម.ក.** ភ្លាម។

**ប្រការ ៣៦.-**

ការធ្វើបរិវិសកម្មត្រូវបានកំណត់ដូចខាងក្រោម÷

១-២០ (ម្ភៃ) ភាគរយនៃសំណើលក់ជាសាធារណៈសរុប ត្រូវបានបម្រុងសម្រាប់អ្នកវិនិយោគសញ្ជាតិខ្មែរ។

២-៨០ (ប៉ែតសិប) ភាគរយដែលនៅសល់ត្រូវបើកចំហចំពោះអ្នកវិនិយោគសញ្ជាតិខ្មែរ និងអ្នកវិនិយោគមិនមែនសញ្ជាតិខ្មែរ។

ករណីការធ្វើបរិវិសកម្មមិនអាចសម្រេចបានតាមការកំណត់ខាងលើ អគ្គនាយកនៃ **គ.ម.ក.** អាចធ្វើការកំណត់នូវការបែងចែកឡើងវិញ ដើម្បីធានាភាពជោគជ័យនៃសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៣៧.-**

ក្រុមហ៊ុនមូលបត្រត្រូវចែកចាយលក់មូលបត្រកម្មសិទ្ធិក្នុងថ្ងៃដែលបានកំណត់នៅក្នុងឯកសារផ្តល់-

ព័ត៌មានដែលបានចុះបញ្ជីរួចនៅ **គ.ម.ក.**។

ក្រុមហ៊ុនបោះផ្សាយ ឬភ្នាក់ងារបញ្ជិកាមូលបត្រ ត្រូវបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្ម ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីកាលបរិច្ឆេទបញ្ចប់ការធ្វើបរិវិសកម្ម។

**ប្រការ ៣៨.-**

អនុលោមតាមមាត្រា ២១ នៃច្បាប់ ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចអាចត្រូវបានព្យួរដោយអគ្គនាយកនៃ **គ.ម.ក.**។ ករណីនេះក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ឈប់ទទួលពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រ និងជូនដំណឹងអំពីការព្យួរនេះភ្លាមដល់អ្នកធ្វើបរិវិសកម្ម និងសាធារណជន។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ ត្រូវបញ្ជាក់ជូនអ្នកធ្វើបរិវិសកម្មថាអាចមានសិទ្ធិដកស្ទីការដែលបានធ្វើចំពោះសំណើលក់មូលបត្រជាសាធារណៈ និងអាចទទួលប្រាក់ដែលបានបង់នោះមកវិញ។ ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនមូលបត្រ អាចបន្តទទួលពាក្យស្នើសុំធ្វើបរិវិសកម្មឡើងវិញ បន្ទាប់ពីបញ្ហាដែលបណ្តាលឱ្យមានការព្យួរត្រូវបានដោះស្រាយ និងមានការអនុញ្ញាតឡើងវិញពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៣៩.-**

ក្រុមហ៊ុនបោះផ្សាយត្រូវផ្សព្វផ្សាយភ្លាមៗអំពីការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មានដល់សាធារណជន តាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដែលទទួលស្គាល់ពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបញ្ជាក់នូវចំណុចដូចខាងក្រោម÷

១-លេខស៊េរី និងកាលបរិច្ឆេទនៃការសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

២-មូលហេតុនៃការលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៣-ពេលវេលា ទីកន្លែង និងរបៀបទូទាត់នៃការបង្វិលប្រាក់សងដល់អ្នកបានធ្វើបរិវិសកម្មដែលបានបង់ ឬបានតម្កល់សម្រាប់ការធ្វើបរិវិសកម្ម។ ពេលវេលានៃការបង្វិលសងនេះត្រូវធ្វើឡើងយ៉ាងយូរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទសម្រេចលុបចោលនូវការចុះបញ្ជីឯកសារផ្តល់ព័ត៌មាន។

៤-ព័ត៌មានផ្សេងទៀតតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤០.-**

ការចុះបញ្ជីឯកសារផ្តល់ព័ត៌មានអាចត្រូវបានលុបចោលផងដែរ ក្នុងករណីដែលការធ្វើបរិវិសកម្មមិនបានជោគជ័យ។

**ប្រការ ៤១.-**

ក្រុមហ៊ុនបោះផ្សាយត្រូវរាយការណ៍ពីលទ្ធផលនៃការបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារ-

ណៈដែលត្រូវធ្វើឡើងក្នុងទម្រង់ដែលកំណត់ដោយ **គ.ម.ក.** ដោយត្រូវភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខណ៍អក្សររបស់ធនាគារពាណិជ្ជ អំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក ដែលបង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយនេះ នៅធនាគារពាណិជ្ជដែលជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤២.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបំពេញនីតិវិធីនៅទីផ្សារមូលបត្រប្រតិស្រុត ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការនៅទីផ្សារមូលបត្រប្រតិស្រុត ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៤៣.-**

ក្រុមហ៊ុនបោះផ្សាយត្រូវអនុវត្តឱ្យបានពេញលេញនូវកាតព្វកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់ និងអនុក្រឹត្យ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

## ជំពូកទី ៤
## ការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយជាសាធារណៈ

**ប្រការ ៤៤.-**

ការផ្សាយពាណិជ្ជកម្ម ឬការផ្សព្វផ្សាយព័ត៌មាន ឬការផ្សព្វផ្សាយសេចក្តីថ្លែងទាំងឡាយណាដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលទៅនឹងសំណើបោះផ្សាយ និងលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវធ្វើឡើងស្របតាមលក្ខខណ្ឌតម្រូវដូចមានចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យ និងត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអគ្គនាយកនៃ **គ.ម.ក.** ស្របតាមមាត្រា ១៥ នៃអនុក្រឹត្យ។

មុននឹងទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចធ្វើសកម្មភាពទំនាក់ទំនងជាមួយអ្នកវិនិយោគសក្តានុពលដោយផ្ទាល់ ឬតាមរយៈក្រុមហ៊ុនមូលបត្រ អំពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវភ្ជាប់មកជាមួយបញ្ជីឈ្មោះអ្នកវិនិយោគទាំងនោះ ព្រមទាំងឯកសារពាក់ព័ន្ធ។

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងឯកសារផ្តល់ព័ត៌មាន ក្រុមហ៊ុនបោះផ្សាយអាចផ្សាយពាណិជ្ជកម្ម ឬផ្សព្វផ្សាយព័ត៌មាន រួមទាំងរ៉ូដស្ញូ (Road Show) និងប្រកាសផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានពាក់ព័ន្ធនឹងការកំណត់ថ្លៃលក់មូលបត្រ ដោយត្រូវមានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីអគ្គនាយកនៃ **គ.ម.ក.** និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ។

ក្រុមហ៊ុនបោះផ្សាយត្រូវត្រៀមឯកសារផ្តល់ព័ត៌មានសម្រាប់ផ្តល់ឱ្យសាធារណជន នៅក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ប្រតិបត្តិករទីផ្សារមូលបត្រ និងនៅ **គ.ម.ក.** ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលបានការអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពីអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៤៥.-**

រយៈពេលយ៉ាងតិច ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការមុនថ្ងៃចាប់ផ្តើមធ្វើបរិវិសកម្ម ក្រុមហ៊ុនបោះផ្សាយត្រូវជូនដំណឹងជាផ្លូវការតាមរយៈសារព័ត៌មាន និងឧបករណ៍ផ្សព្វផ្សាយដែលទទួលស្គាល់ដោយអគ្គនាយកនៃ **គ.ម.ក.** ដោយបញ្ជាក់នូវព័ត៌មានដូចខាងក្រោម÷

១-ឈ្មោះ និងប្រទេស ឬស្ថាប័នដទៃទៀត របស់ក្រុមហ៊ុនបោះផ្សាយ។

២-ចំនួន និងឈ្មោះមូលបត្រកម្មសិទ្ធិដែលនឹងត្រូវធ្វើសំណើលក់។

៣-ទីកន្លែងដែលសាធារណជនអាចទទួលបានឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្ម។

៤-កាលបរិច្ឆេទនៃការផ្សព្វផ្សាយជាសាធារណៈនៃការជូនដំណឹងអំពីការធ្វើបរិវិសកម្មជាផ្លូវការ។

៥-សេចក្តីថ្លែង ដើម្បីឱ្យសាធារណជនដឹងថាសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិត្រូវបានទទួលការអនុញ្ញាតពី **គ.ម.ក.** រួចហើយ។

៦-សេចក្តីថ្លែងដើម្បីឱ្យសាធារណជនដឹងថា ការជូនដំណឹងជាផ្លូវការនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ មិនមែនដើម្បីអញ្ជើញឱ្យធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិឡើយ។

៧-កាលបរិច្ឆេទដែលការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនឹងចាប់ផ្តើម។

៨-សេចក្តីថ្លែងដែលបញ្ជាក់ថា អ្នកដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មត្រូវពិចារណាដោយផ្អែកទៅលើឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មដែលត្រូវផ្សព្វផ្សាយ ត្រូវធ្វើឡើងក្នុងទម្រង់បោះពុម្ព។ បន្ថែមពីនេះក្រុមហ៊ុនបោះផ្សាយអាចផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិច ប៉ុន្តែក្រុមហ៊ុនបោះផ្សាយត្រូវរក្សាខ្លឹមសារនៃឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់អេឡិចត្រូនិចឱ្យដូចគ្នានឹងឯកសារផ្តល់ព័ត៌មាន និងពាក្យស្នើសុំធ្វើបរិវិសកម្មក្នុងទម្រង់បោះពុម្ព។

## ជំពូកទី ៥
## កម្រៃសេវាក្នុងការចុះបញ្ជី

**ប្រការ ៤៦.-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន នៅពេលដាក់ពាក្យស្នើសុំ ឱ្យ **គ.ម.ក.** ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១២.០០០.០០០

(ដប់ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិ-ស្រុត ឬប្រាក់ចំនួន ៤.០០០.០០០(បួនលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៧.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួស ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ១.២០០.០០០ (មួយលានពីរសែន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធ-ភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែមត្រូវបង់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិ-ស្រុត ឬប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៨.-**

ក្រុមហ៊ុនបោះផ្សាយត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សា ឱ្យ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំពិនិត្យឡើងវិញលើឯកសារផ្តល់ព័ត៌មានដែលអស់សុពលភាព ដូចខាងក្រោម÷

១-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីជាសាធារណៈ ត្រូវបង់ប្រាក់ចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិ-ស្រុត ឬប្រាក់ចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

២-ករណីសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈបន្ថែម ត្រូវបង់ប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ក្រុមហ៊ុនដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារគោលនៃទីផ្សារមូលបត្រប្រតិស្រុត ឬប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ក្រុមហ៊ុនសក្តានុពលដែលមានលទ្ធភាពចុះបញ្ជីក្នុងទីផ្សារកំណើននៃទីផ្សារមូលបត្រប្រតិស្រុត។

**ប្រការ ៤៩.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាដូចមានចែងក្នុងប្រការ ៤៦ ប្រការ ៤៧ និងប្រការ ៤៨ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យក្រុមហ៊ុនបោះផ្សាយវិញឡើយ ទោះជាឯកសារផ្តល់ព័ត៌មានទទួលបានការអនុញ្ញាត និងចុះបញ្ជី ឬត្រូវបានបដិសេធក៏ដោយ។

## ជំពូកទី ៦

## ទោសប្បញ្ញត្តិ

**ប្រការ ៥០.-**

បុគ្គលដែលបំពានលើបញ្ញត្តិនៃប្រកាសនេះត្រូវទទួលរងនូវទណ្ឌកម្មរដ្ឋបាលពីអគ្គនាយកនៃ **គ.ម.ក.** ដូចខាងក្រោម÷

១- ការស្នើឱ្យដាក់អនុស្សារណៈ។

២- ការព្រមាន ឬដាស់តឿន។

៣- ការកត់សម្គាល់ជាសាធារណៈហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤- ការដាក់កំហិតលើការបោះផ្សាយមូលបត្រកម្មសិទ្ធិ។

៥- ការផ្តល់អនុសាសន៍លើការបណ្តេញអភិបាល ឬបុគ្គលិកជាន់ខ្ពស់។

៦- ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ឬការចែកចាយបន្ទាប់។

**ប្រការ ៥១.-**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ឬក្រុមហ៊ុនមូលបត្រដែលធ្វើអាជីវកម្មធានាទិញមូលបត្រ ឬអ្នកជំនាញ ឬភាគីពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាប្រាក់ពី ១៥.០០០.០០០ (ដប់ប្រាំលាន) រៀលដល់ ៣០.០០០.០០០ (សាមសិបលាន) រៀល។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**ប្រការ ៥២.-**

**គ.ម.ក.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួល

ដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធអ្នកចូលរួមក្នុងទីផ្សារមូលបត្រប្រតិស្រុត និងសាធារណជន។

**ប្រការ ៥៣.-**

ប្រកាសនេះត្រូវជំនួសប្រកាសលេខ ០០១/គមក/ប្រក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

**ប្រការ ៥៤.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៥៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ: ០០៦/១៥ គ.ម.ក/ប្រ.ក.

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

* * * * *

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញប្រកាសលេខ ០១១ គ.ម.ក.ប្រក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- បានឃើញប្រកាសលេខ ០០៤ គ.ម.ក.ប្រក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១០ ស្តីពីខ្លឹមសារគោលនៃវិធានប្រតិបត្តិការរបស់ទីផ្សារមូលបត្រ ប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងសេវារក្សាទុកមូលបត្រ

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99 Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh,
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@secc.gov.kh,

- បានឃើញប្រកាសលេខ ០០៨/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
- បានឃើញប្រកាសលេខ ០០១/១២ ស្នន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា
- យោងតាមសំណើសុំការពិនិត្យ វិសោធនកម្ម និងអនុម័ត លើវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥។

# ស ម្រេ ច

**ប្រការ ១.-**

ដាក់ឱ្យអនុវត្តនូវវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ ២.-**

ប្រកាសនេះ ត្រូវជំនួសប្រកាសលេខ ០០៨/១១ គ.ម.ក.ប្រ.ក. ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ និងប្រកាសលេខ ០០១/១២ ស្នន១ គ.ម.ក/ប្រ.ក. ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តនូវការកែប្រែថ្លៃសេវាក្នុងវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

**ប្រការ ៣.-**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន-អង្គភាពដទៃទៀតចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា សមាជិក និងអ្នកចូលរួមក្នុងទីផ្សារមូលបត្រកម្ពុជា ព្រមទាំងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ..00៦/១៥...
ស្តីពីការដាក់ឱ្យអនុវត្តវិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

# វិធានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ
# របស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

* * * * *

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

គោលបំណងនៃវិធាននេះ គឺដើម្បីកំណត់អំពីគោលការណ៍នានាដែលចាំបាច់សម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (សរសេរកាត់ថា ផ.ម.ក.) អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

### ប្រការ ២.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងវិធាននេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន÷

-បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ សំដៅដល់បុគ្គលដែលមានបំណងធ្វើសំណើចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) ដែលមិនធ្លាប់បានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-បុគ្គលចុះបញ្ជីលក់មូលបត្រសំដៅដល់បុគ្គលដែលបានបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ហើយបានចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ សំដៅដល់ភាគហ៊ុនិក និងបុគ្គលពាក់ព័ន្ធពិសេសនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេរបស់បុគ្គលស្នើសុំចុះបញ្ជីនេះ។ ក្នុងករណីនេះ ភាគហ៊ុនដែលកាន់កាប់ក្នុងគោលបំណងវិនិយោគជាកញ្ចប់ដោយវិនិយោគិនស្ថាប័ន ត្រូវបានដកចេញពីការគណនាចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនជាងគេ។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ៣០ (សាមសិប) ភាគរយ ឡើងទៅ នៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ សំដៅដល់ភាគហ៊ុនិក ឬក្រុមបុគ្គល ដែលកាន់កាប់ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ ឡើងទៅនៅក្នុងបុគ្គលចុះបញ្ជីលក់មូលបត្រ ហើយដែលសិទ្ធិនោះអាចកើតឡើងដោយផ្ទាល់តាមរយៈការកាន់កាប់ភាគហ៊ុន ឬដោយប្រយោល។

-ភាគហ៊ុនិកយុទ្ធសាស្ត្រ (Strategic Shareholders) សំដៅដល់ភាគហ៊ុនិកដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់នៃបុគ្គលចុះបញ្ជីលក់មូលបត្រ និងសមាជិកគ្រួសារផ្ទាល់របស់បុគ្គលទាំងនេះ។

-មូលធនភាគហ៊ុនិក (Shareholders Equity) សំដៅដល់មូលធនសរុបរបស់ក្រុមហ៊ុនដែលវិនិយោគដោយភាគហ៊ុនិក រួមទាំងប្រាក់ចំណេញរក្សាទុក។

## ជំពូកទី ២

## លក្ខខណ្ឌ និងនីតិវិធីនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

### ប្រការ ៣.- ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវឆ្លងកាត់ការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងមានលទ្ធភាពអាចបំពេញលក្ខខណ្ឌនៃការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក.។

### ប្រការ ៤.- ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងត្រូវភ្ជាប់ជាមួយឯកសារដូចខាងក្រោម មក ផ.ម.ក. ៖

១- ព័ត៌មានទូទៅ៖

ក- ឈ្មោះរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រជាភាសាខ្មែរ និងអក្សរឡាតាំង។

ខ- អាសយដ្ឋានរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

គ- កាលបរិច្ឆេទបង្កើតបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ឃ- កម្មវត្ថុអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ង- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម។

ច- លិខិតអនុញ្ញាតធ្វើអាជីវកម្មពីអាជ្ញាធរពាក់ព័ន្ធ។

២- ព័ត៌មានអំពីបុគ្គលតំណាងឱ្យបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ÷ អត្តសញ្ញាណបុគ្គលតំណាងនៃបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

៣- ព័ត៌មានអំពីភាគហ៊ុនិក÷ អត្តសញ្ញាណភាគហ៊ុនិក។

៤- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ប្រភេទមូលបត្រកម្មសិទ្ធិទាំងអស់របស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ។

ខ- ព័ត៌មានអំពីស្ថានភាពហិរញ្ញវត្ថុ និងលទ្ធភាពក្នុងការទទួលបានប្រាក់ចំណេញ។

គ- ការវាយតម្លៃទ្រព្យសកម្ម និង/ឬការវាយតម្លៃទ្រព្យសកម្មឡើងវិញ (ប្រសិនបើមាន)។

ឃ- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម និងដែលស្របតាមលក្ខខណ្ឌតម្រូវរបស់ប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

៥- ព័ត៌មានអំពីស្ថានភាពអាជីវកម្មរបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលរួមមាន÷

ក- ព័ត៌មានអំពីធុរកិច្ច និងអភិបាលកិច្ច។

ខ- ព័ត៌មានអំពីហានិភ័យ។

៦- ផែនការក្នុងការប្រើប្រាស់សាច់ប្រាក់បានមកពីការបោះផ្សាយលក់មូលបត្រ។

៧- ព័ត៌មានផ្សេងទៀតដែលពាក់ព័ន្ធនឹងការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ។

## ប្រការ ៥.- ការជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលទ្ធភាពអាចចុះបញ្ជី

ផ.ម.ក. ត្រូវជូនដំណឹងអំពីលទ្ធផលនៃការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រទៅបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រក្នុងរយៈពេលយ៉ាងយូរបំផុតត្រឹម ១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលបានពាក្យស្នើសុំពេញលេញ។

ករណី ផ.ម.ក. បដិសេធលទ្ធភាពអាចចុះបញ្ជីលក់មូលបត្ររបស់បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ផ.ម.ក. ត្រូវពន្យល់ពីមូលហេតុនៃការបដិសេធឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ ហើយបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រអាចស្នើសុំការបំភ្លឺពី ផ.ម.ក.។ បុគ្គលដែលត្រូវបានបដិសេធ អាចធ្វើការតវ៉ាមក គ.ម.ក. ចំពោះការបដិសេធនោះ ដើម្បីពិនិត្យ និងសម្រេច។

## ប្រការ ៦.- ការដាក់ផ្ញើមូលបត្រ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រដែលទទួលបានការអនុញ្ញាតលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ផ្ញើមូលបត្រដែលមានស្រាប់នៅប្រតិបត្តិកររក្សាទុកមូលបត្រ បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ពី គ.ម.ក. លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ និងមុនដំណើរការនៃការកំណត់ថ្លៃលក់មូលបត្រ។

## ជំពូកទី ៣
## លក្ខខណ្ឌ និងនីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

### ប្រការ ៧.- នីតិវិធីនៃការចុះបញ្ជីលក់មូលបត្រ

បន្ទាប់ពីមូលបត្រត្រូវបានបញ្ជូនទៅអ្នកធ្វើបរិវិសកម្ម បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ៨.- លក្ខខណ្ឌតម្រូវជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១. លក្ខខណ្ឌសម្រាប់ទីផ្សារគោល (Main Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ៣០.០០០.០០០.០០០ (សាមសិបពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវមានប្រាក់ចំណេញសុទ្ធយ៉ាងតិចចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល នៃឆ្នាំសារពើពន្ធមុនការដាក់ពាក្យស្នើសុំ និងប្រាក់ចំណេញសរុបចំនួន ៣.០០០.០០០.០០០ (បីពាន់លាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំចុងក្រោយ។

គ- ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ២០០ (ពីររយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

ឃ- ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ៧ (ប្រាំពីរ) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមការស្នើសុំរបស់ ផ.ម.ក.។

២. លក្ខខណ្ឌសម្រាប់ទីផ្សារកំណើន (Growth Board)

ក- ត្រូវមានមូលធនភាគហ៊ុនិកសរុបយ៉ាងតិច ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំចុះបញ្ជីនៅ ផ.ម.ក.។

ខ- ត្រូវបំពេញលក្ខខណ្ឌប្រាក់ចំណេញណាមួយ ដូចខាងក្រោម÷

- ត្រូវមានប្រាក់ចំណេញសុទ្ធនៅឆ្នាំសារពើពន្ធចុងក្រោយ ឬ
- ត្រូវមានលំហូរសាច់ប្រាក់មកពីសកម្មភាពប្រតិបត្តិការវិជ្ជមាន (Positive Operating Cashflow) និងត្រូវមានអត្រាប្រាក់ចំណេញដុលយ៉ាងហោចណាស់ ១០ (ដប់) ភាគរយ។

គ-ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ដែលកាន់កាប់ភាគហ៊ុនចាប់ពី ១០ (ដប់) ភាគហ៊ុនឡើងទៅ ត្រូវមានចំនួនយ៉ាងតិច ១០០ (មួយរយ) នាក់ គិតត្រឹមថ្ងៃបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមសំណើរបស់ ផ.ម.ក.។

ឃ-ភាគហ៊ុនមានសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតតិចជាង ១ (មួយ) ភាគរយ ត្រូវមានចំនួនសរុបយ៉ាងតិច ១០ (ដប់) ភាគរយ នៃចំនួនភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុប លើកលែងតែមានការសម្រេចផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក. តាមសំណើរបស់ ផ.ម.ក.។

## ប្រការ ៩.- លក្ខខណ្ឌតម្រូវមិនមែនជាតួលេខ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ អាចចុះបញ្ជីលក់មូលបត្រជាផ្លូវការបាននៅ ផ.ម.ក. ដោយត្រូវបំពេញលក្ខខណ្ឌតម្រូវមិនមែនជាតួលេខ ដូចខាងក្រោម៖

១-មិនត្រូវមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតច្រើនជាងគេក្នុងរយៈពេល ១ (មួយ) ឆ្នាំចុងក្រោយ រហូតដល់កាលបរិច្ឆេទចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

២-មូលបត្រទាំងអស់ដែលបានបោះផ្សាយ ត្រូវដាក់ផ្ញើនៅប្រតិបត្តិកររក្សាទុកមូលបត្រដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

## ប្រការ ១០.- ឯកសារដែលត្រូវផ្តល់ជូន ផ.ម.ក.

ក្នុងការបំពេញនីតិវិធីចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ជូន ផ.ម.ក. នូវឯកសារ ដូចខាងក្រោម៖

១-ឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជីរួចនៅ គ.ម.ក.។

២-ឯកសារបញ្ជាក់អំពីការទូទាត់បរិវិសកម្មមូលបត្រ។

៣-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

៤-ច្បាប់ចម្លងនៃកិច្ចសន្យាដែលធ្វើឡើងជាមួយភ្នាក់ងារទូទាត់។

៥-របាយការណ៍បែងចែកមូលបត្រ។

៦-លិខិតបញ្ជាក់អំពីការដាក់ផ្ញើមូលបត្រនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

## ប្រការ ១១.- ការចុះបញ្ជីលក់មូលបត្រជាផ្លូវការ

បន្ទាប់ពីទទួលបានឯកសារត្រឹមត្រូវ និងពេញលេញដូចមានចែងក្នុងប្រការ១០នៃវិធាននេះ ផ.ម.ក. ត្រូវពិនិត្យ និងចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃនៃថ្ងៃធ្វើការ។

### ប្រការ ១២.- កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ

មុននឹងត្រូវបានអនុញ្ញាតឱ្យចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅ ផ.ម.ក. បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រ តាមគំរូដែលទទួលបានការអនុញ្ញាតពី គ.ម.ក.។

កិច្ចព្រមព្រៀងចុះបញ្ជីលក់មូលបត្រដូចមានចែងក្នុងកថាខណ្ឌទី ១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

### ប្រការ ១៣.- ការមិនសងត្រលប់នៅវិញនូវឯកសារពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជី និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រ

រាល់ឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រដែលតម្រូវដោយវិធាននេះ មិនត្រូវប្រគល់ជូនបុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រវិញនោះទេ ទោះបីពាក្យស្នើសុំនោះត្រូវបានបដិសេធ ឬត្រូវដកទៅវិញក៏ដោយ។

## ជំពូកទី ៤

## លក្ខខណ្ឌ និងនីតិវិធីនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

### ប្រការ ១៤.- លក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

ផ.ម.ក ត្រូវដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការនូវមូលបត្ររបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ក្នុងករណីណាមួយដូចខាងក្រោម លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.÷

១- បុគ្គលចុះបញ្ជីលក់មូលបត្រមិនបានដាក់របាយការណ៍ប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធចុងក្រោយក្នុងអំឡុងពេល ៣ (បី) ខែ បន្ទាប់ពីកាលវសានដែលកំណត់ដោយ គ.ម.ក.។

២- យោបល់របស់សវនករនៅក្នុងរបាយការណ៍សវនកម្មរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ មានយោបល់ជំទាស់ ឬបដិសេធ សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំ។

៣- របាយការណ៍ប្រចាំឆ្នាំបានបង្ហាញថា មូលធនភាគហ៊ុនិករបស់បុគ្គលចុះបញ្ជីលក់មូលបត្របានថយចុះក្នុងរយៈពេល ២ (ពីរ) ឆ្នាំជាប់គ្នា ច្រើនជាង ៥០ (ហាសិប) ភាគរយ។

៤- បុគ្គលចុះបញ្ជីលក់មូលបត្របានបំពានលើកាតព្វកិច្ចផ្តល់ព័ត៌មានជាញឹកញាប់។

៥- បុគ្គលចុះបញ្ជីលក់មូលបត្រមិនអាចទូទាត់ជាស្ថាពរលើផលបត្រពាណិជ្ជកម្ម ឬមូលប្បទានបត្រដែលខ្លួនបានចេញ ឬប្រតិបត្តិការរបស់ខ្លួនជាមួយធនាគារពាណិជ្ជត្រូវបានព្យួរ។

៦-បុគ្គលចុះបញ្ជីលក់មូលបត្រស្ថិតក្រោមករណីណាមួយនៃមូលហេតុរំលាយ ដោយយោងតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

៧-បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវបានដាក់កំហិតក្នុងការផ្ទេរកម្មសិទ្ធិភាគហ៊ុន។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវបានអនុវត្តនោះទេ ចំពោះករណីដែលការដាក់កំហិតត្រូវបានចាត់ទុកថាមិនប៉ះពាល់ដល់ការជួញដូរនៅលើទីផ្សារ ពីព្រោះការដាក់កំហិតនេះត្រូវធ្វើឡើងដោយច្បាប់ផ្សេងទៀតដែលមិនពាក់ព័ន្ធដល់វិស័យមូលបត្រ។

## ប្រការ ១៥.- ការជូនដំណឹងជាសាធារណៈ និងការអនុញ្ញាតលើការជួញដូរលើមូលបត្រដែលដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការ

នៅពេលដកចេញពីបញ្ជីនូវមូលបត្រចុះបញ្ជីលក់មូលបត្រជាផ្លូវការណាមួយ ផ.ម.ក. ត្រូវផ្សព្វផ្សាយជាសាធារណៈអំពីការដកពីបញ្ជីនូវមូលបត្រដែលពាក់ព័ន្ធ។

ករណីដកចេញពីបញ្ជីនូវមូលបត្រណាមួយ ផ.ម.ក. អាចអនុញ្ញាតឱ្យមានការជួញដូរបន្តលើមូលបត្រនោះ សម្រាប់រយៈពេល ១០ (ដប់) ថ្ងៃ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ គ.ម.ក.។

# ជំពូកទី ៥
# ការគ្រប់គ្រងលើមូលបត្រដែលបានចុះបញ្ជីលក់

## ប្រការ ១៦.- ភាតព្វកិច្ច និងនីតិវិធីផ្តល់ព័ត៌មាន

បុគ្គលចុះបញ្ជីលក់មូលបត្រ ត្រូវដាក់ជូន ផ.ម.ក. ឱ្យទាន់ពេលវេលានូវឯកសារផ្តល់ព័ត៌មានជាប្រចាំនិងឯកសារផ្សេងទៀតពាក់ព័ន្ធនឹងការអនុវត្តកាតព្វកិច្ចផ្តល់ព័ត៌មានរបស់ខ្លួន ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

## ប្រការ ១៧.- កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុន

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រ ត្រូវភ្ជាប់មកជាមួយនូវកិច្ចសន្យា ដូចខាងក្រោម÷

១. ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុន ដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែដំបូង នៃរយៈពេល ១ (មួយ) ឆ្នាំ។ សម្រាប់រយៈពេលនៅសល់ ៦ (ប្រាំមួយ) ខែទៀត ភាគហ៊ុនិកនេះ អាចធ្វើការលក់ភាគហ៊ុនរបស់ខ្លួនក្នុងកម្រិតអតិបរមា ៥០ (ហាសិប) ភាគរយ នៃភាគហ៊ុនដែលខ្លួនកាន់កាប់។

២.ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចាប់ពី ១៥ (ដប់ប្រាំ) ភាគរយ និងភាគហ៊ុនិកយុទ្ធសាស្ត្រ មិនត្រូវលក់ ឬផ្ទេរភាគហ៊ុនដែលខ្លួនកាន់កាប់យ៉ាងហោចណាស់សម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ ។

កិច្ចព្រមព្រៀងមិនផ្ទេរភាគហ៊ុនដូចមានចែងក្នុងកថាខណ្ឌទី១ មានសុពលភាពចាប់ពីថ្ងៃចុះបញ្ជីលក់មូលបត្រជាផ្លូវការ។

## ប្រការ ១៨.- ការព្យួរការជួញដូរ និងការចាប់ផ្តើមជួញដូរជាថ្មី

ផ.ម.ក អាចព្យួរការជួញដូរមូលបត្រក្នុងករណីណាមួយដូចខាងក្រោម÷

១-ករណីភាគហ៊ុនចុះបញ្ជីលក់មួយផ្នែក ឬទាំងស្រុង មានការក្លែងបន្លំ។

២-ករណីដែលស្ថិតក្រោមលក្ខណៈវិនិច្ឆ័យនៃការដកចេញពីបញ្ជីលក់មូលបត្រជាផ្លូវការណាមួយនៃប្រការ ១៤ ដែលវិធានការនៃការដកចេញពីបញ្ជីលក់មូលបត្រមិនទាន់បានអនុវត្ត។

៣-ករណីមានការបំបែក ឬការបង្រួមមូលបត្រកម្មសិទ្ធិ ឬតាមសំណើរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៤-ករណីមានការសម្រេចពីអគ្គនាយកនៃ គ.ម.ក.។

ការព្យួរការជួញដូរមូលបត្រ ស្របតាមកថាខណ្ឌទី ១ ត្រូវបានអនុវត្តរហូតដល់មូលហេតុនៃការព្យួរការជួញដូរត្រូវបានដោះស្រាយរួច លើកលែងតែមានការសម្រេចបន្ថែមពីអគ្គនាយកនៃ គ.ម.ក.។

## ប្រការ ១៩.- ពាក្យស្នើសុំចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិបន្ថែម ត្រូវអនុវត្តនីតិវិធីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិដូចមានចែងក្នុងវិធាននេះ។

## ប្រការ ២០.- ពាក្យស្នើសុំកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

ករណីមានការកែប្រែឈ្មោះបុគ្គលចុះបញ្ជីលក់មូលបត្រ តម្លៃចារឹករបស់មូលបត្រកម្មសិទ្ធិចុះបញ្ជីលក់ ឬចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបំពេញនីតិវិធីកែប្រែការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅ ផ.ម.ក.។

## ប្រការ ២១.- ការផ្លាស់ប្តូរទីផ្សារចុះបញ្ជី

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងផ្លាស់ប្តូរទីផ្សារចុះបញ្ជីពីទីផ្សារកំណើន ទៅទីផ្សារគោលត្រូវបំពេញតាមលក្ខខណ្ឌចុះបញ្ជីនៃទីផ្សារដែលបុគ្គលចុះបញ្ជីមានបំណងផ្ទេរទៅ និងត្រូវដាក់ពាក្យស្នើសុំផ្ទេរទីផ្សារមកកាន់ ផ.ម.ក ។

### ប្រការ ២២.- ការជូនដំណឹងអំពីការក្លែងបន្លំផ្ទេរមូលបត្រ

ករណីមានការជូនដំណឹងជាលាយលក្ខណ៍អក្សរមក គ.ម.ក. អំពីករណីមានការក្លែងបន្លំក្នុងការផ្ទេរមូលបត្រ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវជូនដំណឹងភ្លាមមកផ.ម.ក.។ ការជូនដំណឹងមកផ.ម.ក. នេះ អាចធ្វើឡើងតាមរយៈភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ។

## ជំពូកទី ៦
## ថ្លៃសេវាចុះបញ្ជីលក់មូលបត្រ

### ប្រការ ២៣.- ថ្លៃសេវាសម្រាប់ការពិនិត្យលើលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលស្នើសុំចុះបញ្ជីលក់មូលបត្រត្រូវបង់ថ្លៃសេវា ផ.ម.ក. លើការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល សម្រាប់ទីផ្សារគោល និង ចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់ទីផ្សារកំណើន ។

### ប្រការ ២៤.- ថ្លៃសេវាសម្រាប់ការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រដោយផ្អែកលើមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ១០.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០៣០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០២៥% |
| ពី | ២០០.០០០.០០០.០០១៛ | ដល់ | ៤០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ៤០០.០០០.០០០.០០០៛ | ០,០១០% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវា ផ.ម.ក. សម្រាប់ការចុះបញ្ជីលក់មូលបត្រចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃអប្បបរមា) ឬ ចំនួន ០,០២៥ (សូន្យក្បៀសសូន្យម្ភៃប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារសរុប គិតតាមថ្លៃបោះផ្សាយលក់មូលបត្រលើកដំបូងជាសាធារណៈ ដោយយកចំនួនណាមួយដែលធំជាងគេ។

**ប្រការ ២៥.- ថ្លៃសេវាចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិប្រចាំឆ្នាំ**

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារគោល ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំទៅតាមមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដែលត្រូវគណនាប្រដេញជាដំណាក់តាមតារាងដូចខាងក្រោម÷

| មូលធនូបនីយកម្មទីផ្សារសរុប | | | | ថ្លៃសេវា |
|---|---|---|---|---|
| ពី | ០៛ | ដល់ | ១២.០០០.០០០.០០០៛ | ៣.០០០.០០០៛ |
| ពី | ១២.០០០.០០០.០០១៛ | ដល់ | ៤០.០០០.០០០.០០០៛ | ០,០២០% |
| ពី | ៤០.០០០.០០០.០០១៛ | ដល់ | ២០០.០០០.០០០.០០០៛ | ០,០១៥% |
| | | លើសពី | ២០០.០០០.០០០.០០០៛ | ០,០០៥% |

បុគ្គលចុះបញ្ជីលក់មូលបត្រនៅទីផ្សារកំណើន ត្រូវបង់ថ្លៃសេវាប្រចាំឆ្នាំចំនួន ៤.០០០.០០០ (បួនលាន) រៀល (ថ្លៃសេវាប្រចាំឆ្នាំអប្បបរមា) ឬ ចំនួន ០,០១៥ (សូន្យក្បៀសសូន្យដប់ប្រាំ) ភាគរយ នៃមូលធនូបនីយកម្មទីផ្សារនៅចុងឆ្នាំសារពើពន្ធចុងក្រោយ ដោយយកចំនួនណាមួយដែលធំជាងគេ។

* * *